ISSN 1560-7615 / ISBN 978-99950-52-06-5

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៣ លេខ ៣ | កក្កដា - កញ្ញា ឆ្នាំ២០០៩ | តម្លៃ ១.៥០០៛

## ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលលើប្រជាជនក្រីក្រ និង ជនងាយរងគ្រោះក្នុងប្រទេសកម្ពុជា*

ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចសាកលកំពុងវិវត្តបន្តទៀតក្នុងពេលបច្ចុប្បន្ន ។ទោះបីសេណារីយ៉ូមហាវិនាស ដែលគេប្រមើលឃើញពីដំបូងមិនបានកើតមានជាក់ស្តែង ហើយក៏ប្រហែលមិនកើតមានទេ ក្នុងមួយរយៈពេលខាងមុខដែលគេអាចមើលឃើញ ប៉ុន្តែមកទល់ពេលនេះ វិបត្តិបានប៉ះពាល់ធ្ងន់ធ្ងរណាស់ទៅហើយលើជីវភាពរបស់គ្រួសារក្រីក្រ និងជនងាយរងគ្រោះនៅគ្រប់ទិសទី រួមទាំងប្រទេសកម្ពុជាផងដែរ ។ នៅកម្ពុជា ផលប៉ះពាល់វាស្តែងឡើង តាមរយៈការជះឥទ្ធិពលអាក្រក់ទៅលើបណ្តាសកម្មភាពសេដ្ឋកិច្ចស្នូល ដូចជា វិស័យកាត់ដេរ សាងសង់ និងទេសចរណ៍ ។ ដោយឡែក វិស័យកសិកម្មហាក់ដូចជាមិនរងផលប៉ះពាល់ធ្ងន់ធ្ងរទេ ព្រោះមានកំណើនល្អគួរសមក្នុងអំឡុងពេលនេះ ។



ឥទ្ធិពលមួយនៃវិបត្តិសេដ្ឋកិច្ចនាបច្ចុប្បន្នៈ មានអ្នកជិះស៊ីក្លូ និងម៉ូតូឌុបតិចតួចប៉ុណ្ណោះ នៅទីក្រុងភ្នំពេញ

ឫសគល់នៃវិបត្តិនេះ គឺវិបត្តិហិរញ្ញវត្ថុដែលផ្តើមចេញពីសហរដ្ឋអាមេរិក ដោយមានការពិភាក្សាវែកញែកជាច្រើនថា តើវាបានចាប់ផ្តើមនៅពេលណា ។ ក្របខ័ណ្ឌច្បាប់ធូររលុងនៅសហរដ្ឋអាមេរិក និងប្រទេសផ្សេងៗទៀត គួបផ្សំបណ្តាញពឹងផ្អែកគ្នាចុះឡើង រវាងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ បានធ្វើឱ្យវិបត្តិហិរញ្ញវត្ថុអាមេរិកនេះ ក្លាយទៅជាវិបត្តិហិរញ្ញវត្ថុសាកល ហើយក៏វិវត្តទៅជាវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរក្នុងរយៈពេលយ៉ាងខ្លី ។ ការរីករាលដាល នៃវិបត្តិហិរញ្ញវត្ថុវាប្រែប្រួលទៅតាមទំហំនៃការចូលរួមរបស់ប្រទេសនីមួយៗ នៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ។ ប្រទេសណាមានការពាក់ព័ន្ធតិចតួច ឬគ្មានសោះ ពុំមានការប៉ះពាល់ធ្ងន់ធ្ងរទេ ។ ទោះជាយ៉ាងនេះក្តី តែក្នុងមួយរយៈពេលខ្លីសោះ វិបត្តិហិរញ្ញវត្ថុបានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចក្នុងប្រទេសជាច្រើន ដែលធ្វើឱ្យធ្លាក់ចុះពាណិជ្ជកម្មអន្តរជាតិ និងលំហូរមូលធនអន្តរជាតិ ជាពិសេស វិនិយោគផ្ទាល់ពីបរទេស (FDI) និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស (ODA) ។ ដោយសារប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ជាច្រើនមានការពាក់ព័ន្ធ និងពឹងផ្អែកយ៉ាងខ្លាំង ទៅលើពាណិជ្ជកម្មអន្តរជាតិ FDI និង ODA ដូច្នេះផលប៉ះពាល់ទៅលើសេដ្ឋកិច្ច ក៏កាន់តែធ្ងន់ធ្ងរឡើង ។ សំរាប់ករណីដូចជានៅប្រទេសកម្ពុជា ដែលមានជាង ៨០% នៃប្រាក់ចំណូលលើការនាំចេញបានពីផលិតផលកាត់ដេរ ដូច្នេះការថយចុះក្នុងពាណិជ្ជកម្មផលិតផលកាត់ដេរនឹងប៉ះពាល់ធ្ងន់ធ្ងរដល់សកម្មភាពសេដ្ឋកិច្ចជាទូទៅ ជាពិសេស ផលិតកម្ម

(តទៅទំព័រ ៥)

* Hossein Jalilian នាយកផ្នែកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI ណែនាំបង្ហាញពីទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា លេខពិសេសនេះ ដែលផ្តោតលើផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចសាកល ទៅលើគ្រួសារក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា ។

## មាតិកា

ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលលើប្រជាជនក្រីក្រ និង ជនងាយរងគ្រោះក្នុងប្រទេសកម្ពុជា ........................ ១
អង្កេតលើកម្មករងាយរងគ្រោះនៅ រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ សៀមរាប និង បាត់ដំបង ........................................ ២
ការវាយតម្លៃរហ័សពីផលប៉ះពាល់នៃ វិបត្តិសេដ្ឋកិច្ចសាកល ទៅលើគ្រួសារនៅកម្ពុជាៈ ឥទ្ធិពល និង យុទ្ធសាស្ត្រដោះស្រាយ ... ៦
ការគ្រប់គ្រងមិនផ្លូវការលើហានិភ័យ និងការអនុវត្តប្រព័ន្ធសុវត្ថិភាពសង្គមៈ បទពិសោធន៍សិក្សាពីគ្រួសារ និង ពលករក្រីក្រ និងងាយរងគ្រោះ ........................................ ១១
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស........................ ១៦
— ស្ថានភាពក្នុងប្រទេស........................ ១៨
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ........................................ ២៤

# អង្កេតលើកម្មករងាយរងគ្រោះនៅ រាជធានីភ្នំពេញ ខេត្តកណ្ដាល កំពង់ស្ពឺ សៀមរាប និង បាត់ដំបង*

## ១. សេចក្ដីផ្ដើម

អត្ថបទនេះ ព្យាយាមវាយតម្លៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ចនៃវិបត្តិហិរញ្ញវត្ថុសាកល ទៅលើកម្មករងាយរងគ្រោះ នៅប្រទេសកម្ពុជា ។ ក្នុងនេះការសិក្សាបានផ្ដោតជាចំបងលើឥទ្ធិពលនៃវិបត្តិទៅលើ ចំណូលប្រចាំថ្ងៃពិត ចំណាយប្រើប្រាស់ប្រចាំថ្ងៃពិត និងការវិវត្តនៅឆ្នាំខាងមុខ ដោយប្រើទិន្នន័យបានពីអង្កេតធ្វើឡើងនៅ ទីក្រុងភ្នំពេញ ខេត្តកណ្ដាល និង កំពង់ស្ពឺ តាំងពីឆ្នាំ២០០៣ និងធ្វើនៅតំបន់ពីរផ្សេងទៀត (ខេត្តសៀមរាប និងបាត់ដំបង) កាលពីខែឧសភា ២០០៩ ព្រមទាំងការពិភាក្សាតាមក្រុមស្នូល ។

កន្លងមកមានការសិក្សាមួយចំនួនតូច បានព្យាយាមវាយតម្លៃពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលទៅលើសេដ្ឋកិច្ចកម្ពុជា នៅកំរិតម៉ាក្រូ កំរិតតាមវិស័យ (កសិកម្ម កាត់ដេរ ទេសចរណ៍ និងសំណង់) ទីផ្សារពលកម្ម និងកំរិតគ្រួសារ ។ ការសិក្សាទាំងនោះបានវាយតម្លៃរហ័ស (Kang et al. 2009; Jalilian et al. 2009) ដែលផ្សព្វផ្សាយហើយ បានបង្ហាញថា ផលប៉ះពាល់ខាងម៉ាក្រូសេដ្ឋកិច្ច នឹងរឹតតែធ្ងន់ធ្ងរឡើង ដោយសារការរួមចុះក្នុងវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ ។ វិស័យកាត់ដេររងផលប៉ះពាល់ធ្ងន់ធ្ងរបំផុត គឺពីខែកញ្ញា ២០០៨ ដល់ពាក់កណ្ដាលខែមីនា ២០០៩ មានការបញ្ឈប់កម្មករអស់ ១៤% ក្នុងចំណោមកម្មករសរុប ៣៥០.០០០នាក់ ដោយសារការនាំចេញធ្លាក់ចុះជាខ្លាំង ។ ចំនួនភ្ញៀវទេសចរមកកម្ពុជា បានធ្លាក់ចុះដោយមានអត្រាកំណើនប្រចាំឆ្នាំអវិជ្ជមាន អស់ ៦ខែជាប់ៗគ្នា ចាប់តាំងពីខែតុលា ២០០៨ មក ។ នៅខេត្តសៀមរាបដែលជាកន្លែងទទួលទេសចរសំខាន់បំផុតនៅកម្ពុជា សណ្ឋាគារជាច្រើនទទួលបានអត្រាស្នាក់នៅកំរិតទាប ហើយសណ្ឋាគារប្រណីតៗខ្លះ បានបញ្ឈប់ដំណើរការជាបណ្ដោះអាសន្ន ។ បុគ្គលិកនៅតាមសណ្ឋាគារទាំងនោះ ត្រូវឈប់សំរាកដោយគ្មានប្រៀវត្សរ៍ ឬក៏ត្រូវបញ្ឈប់ពីការងារជាបណ្ដោះអាសន្ន ។ អង្គការរូបិយវត្ថុអន្តរជាតិ (IMF) បានគន់គូរថា វិស័យទេសចរណ៍ នឹងធ្លាក់ចុះអស់ ៥% ដោយសារការថយចុះតំរូវការធ្វើដំណើរក្នុងពិភពលោក ។ វិស័យសំណង់ក៏ត្រូវធ្លាក់ចុះ ធ្ងន់ធ្ងរដែរ ពីព្រោះវិនិយោគិនបរទេសក្នុងវិស័យអចលនទ្រព្យ បានកាត់បន្ថយឬពន្យាពេលអនុវត្តគម្រោងធំៗ ដោយសារវិបត្តិឥណទាននៅឯប្រទេសដើមរបស់ពួកគេ ។ ប៉ុន្តែវិស័យកសិកម្មរំពឹងថានឹងមានកំណើនខ្លាំងក្លា ដែលនឹងជួយប៉ះប៉ូវដល់វិស័យដទៃៗទៀតនៃសេដ្ឋកិច្ច ។ Kang (2009) បានរាយការណ៍ពីការធ្លាក់ចុះចំណូលប្រចាំគ្រួសារ បង្កដោយការថយចុះនៃប្រាក់ផ្ញើទៅផ្ទះរបស់កម្មករចំណាកស្រុក ។

ការសិក្សាពីមុនៗ បានព្យាយាមវាយតម្លៃពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលទៅលើសេដ្ឋកិច្ចកម្ពុជា ដោយប្រើប្រាស់ការវិភាគបែបពណ៌នា និងការពិភាក្សាតាមក្រុមស្នូល ។ វិធីសាស្ត្រទាំងនេះទំនងមិនអាចបង្ហាញលទ្ធផលបានច្បាស់លាស់ទេ ដោយសារមានព្រឹត្តិការណ៍មួយចំនួនកើតឡើងដូចជា ការឡើងថ្លៃម្ហូបអាហារ ទំនាស់ព្រំដែនរវាងកម្ពុជា-ថៃ និងការប៉ះទង្គិចដោយឡែកៗមួយចំនួន ដែលកើតមាននៅក្នុងឆ្នាំ២០០៨ ។ ការសិក្សានេះនឹងអនុវត្តបច្ចេកទេសបែបបរិមាណយ៉ាងសាមញ្ញមួយ ដែលអាចប្រើប្រាស់បានយ៉ាងទូលំទូលាយ ដោយសារវាផ្អែកលើអង្កេតធម្មតាៗ ដើម្បីធ្វើការប៉ាន់ស្មានពីផលប៉ះពាល់នៃវិបត្តិទៅលើចំណូល និងចំណាយរបស់បុគ្គល ។

## ២. វិធីសាស្ត្រស្រាវជ្រាវ និង ដែនកំណត់

តាំងពីឆ្នាំ១៩៩៨ មក CDRI បានធ្វើអង្កេតប្រចាំត្រីមាសលើពលករងាយរងគ្រោះចំនួន ៤ក្រុម នៅក្នុងទីក្រុងភ្នំពេញ គឺមាន អ្នកធាក់ស៊ីក្លូ អ្នកលីសែង អ្នកលក់បន្លែតូចតាច និង អ្នករើសអេតចាយ ។ នៅឆ្នាំ២០០០ អង្កេតនេះបានពង្រីកទៅធ្វើលើពលករ ៦ក្រុមផ្សេងទៀត គឺ អ្នករត់ម៉ូតូឌុប កម្មករសំណង់គ្មានជំនាញ កម្មករសំណង់មានជំនាញ អ្នកបំរើភោជនីយដ្ឋាន កម្មកររោងចក្រកាត់ដេរ និងអ្នកស៊ីឈ្នួលធ្វើស្រែ (នៅខេត្តកណ្ដាល និងកំពង់ស្ពឺ) ។ គំរូតាងសរុបក្នុងអង្កេត មាន ៤៨០នាក់ ក្នុងនោះ កម្មករកាត់ដេរ មាន ១២០នាក់ និង កម្មករក្នុងក្រុមដទៃៗទៀត មាន ៤០នាក់/ក្រុម ។ នៅខែឧសភា ២០០៩ ដោយមានជំនួយមូលនិធិមួយភាគពីធនាគារពិភពលោក វិទ្យាស្ថាន CDRI បានបញ្ចូលពលករងាយរងគ្រោះ ២ក្រុមទៀត គឺ ពលករចំណាកស្រុក (២០សម្ភាសន៍ នៅខេត្តបាត់ដំបង) និង ពលករខាងទេសចរណ៍ (២០សម្ភាសន៍ នៅខេត្តសៀមរាប) ។ សរុបមក អង្កេតនេះមានប្រើគំរូតាង ចំនួន ៥២០នាក់ ។ ក្រៅពីអង្កេតជាលក្ខណៈវៀបរយ ក៏មានធ្វើការពិភាក្សាតាមក្រុមស្នូលជាមួយនឹងពលករខាងទេសចរណ៍ និង ពលករចំណាកស្រុក ដើម្បីកំណត់ពីផលប៉ះពាល់នៃវិបត្តិទៅលើគ្រួសារនានានៅខេត្តសៀមរាប និងបាត់ដំបង ។ គំរូតាងត្រូវបានជ្រើសរើសដោយមានគោលដៅនៅនឹងកន្លែងផ្ទាល់ ដែលភាគច្រើននៅតាមតំបន់ទីក្រុង ហើយក្នុងនេះមានទាំងពលករស៊ីឈ្នួល និងពលករប្រកបមុខរបរខ្លួនឯង ដូច្នេះលទ្ធផលបានពីការសិក្សានេះ មិនតំណាងឱ្យសកម្មភាពសេដ្ឋកិច្ចទីមួយៗទេ ហើយក៏មិនអាចកំណត់ថា វិស័យសេដ្ឋកិច្ចមួយណា ដែលបានស្រូបយក ពួកកម្មករត្រូវបញ្ឈប់ពីការងារ (ឧ. កម្មករកាត់ដេរ) នោះដែរ ។

ដើម្បីកំណត់ពីផលប៉ះពាល់នៃវិបត្តិ ទៅលើក្រុមជ្រើសរើសទាំង១០ខាងលើ មានការសន្មត់ថា ទិន្នន័យប្រមូលបានពី អង្កេតនៅខែកុម្ភៈ និង ឧសភា ២០០៧ វាឆ្លុះបញ្ចាំងពីអំឡុងពេលមុនវិបត្តិ ហើយទិន្នន័យនៅខែកុម្ភៈ និង ឧសភា ២០០៩ វាឆ្លុះបញ្ចាំងពីអំឡុងពេលក្រោយវិបត្តិ ពីព្រោះមិនអាចរកបានទិន្នន័យសំរាប់ខែកុម្ភៈ ឧសភា និង សីហា ២០០៨ ឡើយ ។ ការសិក្សានេះបានប្រើប្រាស់ simple regression technique (ordinary least squares) ដើម្បីប៉ាន់ស្មានពីផលប៉ះពាល់នៃវិបត្តិ ទៅលើចំណូលប្រចាំថ្ងៃពិត ចំណាយពិត និង បំណុលពិត ។ ដោយសារការសិក្សានេះ ចង់ស្វែងយល់ពីឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុសាកល ទៅលើកំរិតជីវភាពរបស់ពលករងាយរង

* អត្ថបទនេះ រៀបចំដោយ បណ្ឌិត តុង គឹមស៊ុន, លោក ឃៀង សុធី និង កញ្ញា ផាន់ ដាលីស ដោយមានការចូលរួមអំពី កញ្ញា ហែម មេត្តា និង អ្នកស្រី ប៉ុន ដូរីណា ។ ទស្សនៈលើកឡើងនៅក្នុងអត្ថបទនេះ គឺជារបស់អ្នកនិពន្ធផ្ទាល់ ។ អ្នកនិពន្ធសូមថ្លែងអំណរគុណ ដល់ បណ្ឌិត Hossein Jalilian, Neak Samsen, និង Tim Conway ចំពោះការជួយមតិជាច្រើនលើរបាយការណ៍ព្រាងពីដំបូង ។

គ្រោះ ដូច្នេះកត្តាផ្សេងទៀត ដូចជា អាយុ ភេទ កំរិតអប់រំ ទំហំគ្រួសារ និងបទពិសោធន៍ការងារ ត្រូវទុកឱ្យនៅថេរ បើមិនដូច្នោះទេ យើងមិនអាចដឹងពីឥទ្ធិពលនោះបានឡើយ ។ ដោយមូលហេតុនេះ វិធីសាស្ត្រដែលយកមកប្រើ គួរតែអាចផ្តល់លទ្ធផល បានត្រឹមត្រូវជាងការវិភាគបែបពណ៌នា ។ ទោះយ៉ាងណាក្តី ដោយសារមាន ព្រឹត្តិការណ៍កើតឡើងថ្មីៗដូចបានរៀបរាប់ខាងលើ វិធីសាស្ត្រក្នុងការសិក្សានេះ មិនអាចបំបែកឱ្យដាច់ពីគ្នាទេនូវ ឥទ្ធិពលនៃការប៉ះទង្គិចដែលជាករណីដោយឡែកៗ ឬជាករណីបែបសំបូរ ។

ដើម្បីបំប្លែងចំណូល ឬចំណាយប្រចាំថ្ងៃ ទៅជាតួលេខពិត យើងបានយកតួលេខចំណូល និងចំណាយប្រចាំថ្ងៃចារឹក ទៅចែកនឹងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ដែលចេញផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ សំរាប់ខែកុម្ភៈ ២០០៣ រហូតដល់ វិច្ឆិកា ២០០៨ និងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ដែលប៉ាន់ស្មានដោយ CDRI ផ្ទាល់សំរាប់ខែកុម្ភៈ និង ឧសភា ២០០៩ ។[1] មានការសន្មត់មួយទៀតថា អត្រាអតិផរណាប្រចាំឆ្នាំ គឺ ៦,៥% នៅខែកុម្ភៈ និង ៦,៤% នៅខែឧសភា ២០០៩ ។

## ៣. ការវិភាគផ្អែកលើការពិសោធឃើញជាក់ស្តែង

អង្កេតសំរាប់ខែឧសភា ២០០៩ បានរកឃើញថា ចំណូលប្រចាំថ្ងៃពិត របស់ពលករមិនកាត់ដេរទាំង ៩ក្រុម គឺ មានប្រហែល ៨១៩៥រៀល ឬធ្លាក់ចុះអស់ ១,៨% បើធៀបនឹង ខែឧសភា ២០០៧ ។ ប៉ុន្តែ ក្រុមអ្នករើសអេតចាយ កម្មករសំណង់មានជំនាញ កម្មករសំណង់គ្មានជំនាញ និង អ្នកស៊ីឈ្នួលធ្វើស្រែ មានចំណូលប្រចាំថ្ងៃពិត កើនឡើង ។

ការវិភាគបែបបរិមាណ បានបង្ហាញថា ចំណូលប្រចាំថ្ងៃពិត របស់ពលករទាំង ៩ក្រុមខាងលើ បានកើនឡើង ១២% បើធៀបនឹងអំឡុងពេលមុនវិបត្តិ ។ ក្នុងចំណោម ៩ក្រុមនេះ មានតែ អ្នកលីសែង អ្នករើសអេតចាយ កម្មករសំណង់គ្មានជំនាញ និង អ្នកស៊ីឈ្នួលធ្វើស្រែ ប៉ុណ្ណោះដែលមានចំណូលប្រចាំថ្ងៃកើនឡើង រីឯក្រុមដទៃទៀត គឺនៅដដែល ។ ក្នុងពេលជាមួយគ្នានេះ ចំណាយប្រចាំថ្ងៃពិតរបស់ពលករទាំង៩ក្រុម បានកើនឡើងរហូតដល់ ២៦% (កំណើនចំណាយនេះ វាធំជាង កំណើនចំណូលពិត ដល់ទៅ ១៤%) ។ កំណើននេះសមរម្យហើយ ពីព្រោះចំណែកនៃចំណាយប្រើប្រាស់នៅក្នុងប្រាក់ចំណូល កើនត្រឹមពី ៤៦% ទៅដល់ ៥១% ប៉ុណ្ណោះ ដូច្នេះនៅមានចំណូលសេសសល់សំរាប់ កែលំអសុខុមាលភាព ។ ដោយសារ ទាំងចំណូល និងចំណាយប្រចាំថ្ងៃពិត បានកើនឡើង ហើយចំនួនភាគរយនៃពលករងាយរងគ្រោះ ដែលមានជំពាក់បំណុលគេនៅក្រោយពេលកើតវិបត្តិ ក៏មានកំរិតទាប[2] ដូច្នេះផលប៉ះពាល់នៃវិបត្តិទៅលើពលករទាំង ៩ក្រុម នៅមិនទាន់ធ្ងន់ធ្ងរប៉ុន្មានទេ ។

ដើម្បីបានដឹងពីមតិយល់ឃើញរបស់ពលករងាយរងគ្រោះ ស្តីពីចំណូលប្រចាំថ្ងៃរបស់ពួកគេ ក្រុមអង្កេតបានសុំឱ្យអ្នកឆ្លើយសម្ភាសន៍មានយោបល់ថា តើចំណូលប្រចាំថ្ងៃរបស់ខ្លួននៅឆ្នាំ២០១០ នឹងមានការខុសប្លែកពីឆ្នាំ ២០០៨ ឬយ៉ាងណា ។ តាមនេះមានកម្មករ ២១% ឆ្លើយថា ចំណូលប្រចាំថ្ងៃរបស់ខ្លួននៅឆ្នាំ២០១០ នឹងកើនច្រើនជាង ឆ្នាំ២០០៨ និង ៣៥% ទៀតឆ្លើយថា ប្រហែលនៅដដែល ឬតិចជាងមុន ហើយអ្នកនៅសល់ ៤៣% ទៀតគ្មានយោបល់ទេ ។

ចំណូលប្រចាំថ្ងៃពិតរបស់ពលករពីរក្រុមបន្ថែម (ពលករខាងទេសចរណ៍ និងពលករចំណាកស្រុក) គឺ ៩៨៦៨រៀល និង ៦០០៩រៀល ។ ពលករខាងទេសចរណ៍ មានចំណាយប្រចាំថ្ងៃជាមធ្យម ៥៧៣៥រៀល រីឯពលករចំណាកស្រុក មានត្រឹមតែ ១៥០៧រៀលប៉ុណ្ណោះ ដែលជាបរិមាណចំណាយទាបបំផុតក្នុងចំណោមពលករទាំង ១១ក្រុម ។ ពលករ ១០នាក់ ក្នុងចំណោមពលករខាងទេសចរណ៍ ២០នាក់ បានប្រាប់ថា ពួកគាត់មានជំពាក់បំណុលគេ ប៉ុន្តែមានពលករចំណាកស្រុកតែ ៤នាក់ប៉ុណ្ណោះដែលឆ្លើយដូច្នេះ ។ ពលករ ៧នាក់ ក្នុងចំណោមពលករចំណាកស្រុក ១៥នាក់ ដែលត្រលប់មកពីប្រទេសថៃវិញ បានប្រាប់ថា ពួកគាត់មិនអាចរកការងារធ្វើបានទេនៅប្រទេសថៃ ។ ការពិភាក្សា តាមក្រុមស្នូលនៅភូមិអណ្តូងត្រាច បានផ្តល់ព័ត៌មានថា អ្នកភូមិខ្លះត្រូវឱ្យកូនខានទៅរៀនខ្លះ ឬបោះបង់ការសិក្សាតែម្តង ដើម្បីអាចដើររកក្តាម ខ្យង កង្កែប និងត្រី ជាដើម នៅតាមស្រះ ឬស្រែជិតៗ ។ ម្យ៉ាងទៀត ៤២% នៃពលករខាងទេសចរណ៍ និងពលករចំណាកស្រុក រំពឹងថា នឹងមានចំណូលទាបជាងមុន ក្នុងរយៈពេលបីខែខាងមុខ ហើយមាន ៣៧% ទៀតនិយាយថា នៅឆ្នាំ២០១០ ចំណូលប្រចាំថ្ងៃរបស់ពួកគេ នឹងបានច្រើនជាងឆ្នាំ២០០៨ ។ ដូចមានបញ្ជាក់រួចមកហើយ គំរូតាងក្នុងការសិក្សានេះ មានទំហំតូច ដូច្នេះការយកលទ្ធផលរកឃើញនេះ ទៅអនុវត្តប្រើជាទូទៅនៅគ្រប់កន្លែងអាចនាំឱ្យមានការភ័ន្តច្រលំ ។

នៅខែឧសភា ២០០៩ ចំណូលប្រចាំថ្ងៃពិតរបស់កម្មករកាត់ដេរ បានធ្លាក់ចុះ ១៨% មកត្រឹម ៥៩២៩រៀល (កំរិតទាបបំផុតគិតតាំងពីខែកុម្ភៈ ២០០៣ មក) ធៀបនឹងចំណូល ៧២០៥រៀល កាលពីខែឧសភា ២០០៧ ។ ការធ្លាក់ចុះនេះ បង្កមកពីការថយចុះចំនួនម៉ោងធ្វើការតាំងពី ៦០ម៉ោង ក្នុងមួយសប្តាហ៍ នៅមុនពេលមានវិបត្តិ មកត្រឹម ៥២ម៉ោង បន្ទាប់ពីនោះមក ។ អង្កេតនៅខែកុម្ភៈ និង ឧសភា ២០០៩ បានរកឃើញថា ៤៧% នៃកម្មករកាត់ដេរ មិនមានធ្វើការម៉ោងបន្ថែមទេក្នុងរយៈ១សប្តាហ៍មុនពេលធ្វើសម្ភាសន៍ ធៀបនឹងកម្មករត្រឹមតែ ១១% ប៉ុណ្ណោះ ដែលបានរាយការណ៍ដូច្នេះ សំរាប់រយៈពេលដូចគ្នា ក្នុងឆ្នាំ២០០៧ ។ សរុបមក សកម្មភាពក្នុងវិស័យកាត់ដេរ បានរួមចុះ ដោយសារវិបត្តិសេដ្ឋកិច្ចសាកល ។

ការវិភាគបែបបរិមាណ បង្ហាញថា ចំណូលប្រចាំថ្ងៃពិតរបស់កម្មករកាត់ដេរ បានធ្លាក់ចុះ ២៤% បន្ទាប់ពីវិបត្តិ ។ ក្នុងពេលជាមួយគ្នា ប្រាក់សន្សំប្រចាំថ្ងៃពិតរបស់ពួកគេ បានធ្លាក់ចុះ ២៧% រីឯ ចំណាយប្រចាំថ្ងៃ

---

១ យោងតាមវិទ្យាស្ថានជាតិស្ថិតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅទីក្រុងភ្នំពេញ សំរាប់ខែធ្នូ ២០០៨ និងខែមុនៗនោះទៀត គឺផ្អែកលើខែធ្នូ ២០០០ ធ្វើជាមូលដ្ឋានស្មើ ១០០ ហើយ CPI សំរាប់ខែមករា ២០០៩ និងខែក្រោយៗទៀត គឺផ្អែកលើ ខែតុលា-ធ្នូ ២០០៦ ធ្វើជាមូលដ្ឋានស្មើ ១០០ ។ ដោយសារភាពមិនស៊ីគ្នានៃឆ្នាំមូលដ្ឋាននេះ ក្រុមស្រាវជ្រាវក៏បានធ្វើការប៉ាន់ស្មាននូវ CPI សំរាប់ខែកុម្ភៈ និង ឧសភា ២០០៩ ។ តម្លៃចារឹកសំរាប់ពលករងាយរងគ្រោះទាំងអស់ រួមបញ្ចូលទាំង អ្នកស៊ីឈ្នួលធ្វើស្រែផង ត្រូវបានធ្វើបរិត្តផរណា ដោយប្រើ CPI របស់វិទ្យាស្ថានជាតិស្ថិតិ និង CPI ប៉ាន់ស្មានដោយ CDRI ។

២ ការធ្វើតេស្តខាងស្ថិតិសាមញ្ញមួយ បញ្ជាក់ថា ចំនួនពលករងាយរងគ្រោះដែលកំពុងជាប់បំណុលគេ មានការកើនឡើង ៨% ហើយតួលេខរបស់វាមានសារៈសំខាន់ខាងស្ថិតិ នៅកំរិត ១% ។

តារាង: ចំណូលប្រចាំថ្ងៃពិតជាមធ្យម (ជារៀល គិតតាមកំរិតថ្លៃ នៅខែវិច្ឆិកា ២០០០)

| | | អ្នកធាក់ស៊ីក្លូ | អ្នកលីសែង | អ្នកលក់បន្លែ | អ្នករើសអេតចាយ | កម្មករសំណង់មានជំនាញ | កម្មករសំណង់គ្មានជំនាញ | អ្នករត់ម៉ូតូឌុប | អ្នកបំរើភោជនីយដ្ឋាន | អ្នកស៊ីឈ្នួលធ្វើស្រែ | ពលករខាងវិស័យទេសចរណ៍ | ពលករចំណាកស្រុក | កម្មករកាត់ដេរ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០០៣ | កុម្ភៈ | 8932 | 7378 | 7039 | 3762 | 12.135 | 5983 | 11.068 | 4475 | 4053 | N/A | N/A | 8634 |
| | ឧសភា | 9281 | 7713 | 6471 | 3495 | 12.929 | 6920 | 9583 | 4233 | 3599 | N/A | N/A | 7825 |
| | សីហា | 9075 | 7007 | 6636 | 4749 | 12.332 | 7369 | 10.592 | 4374 | 4498 | N/A | N/A | 8692 |
| | វិច្ឆិកា | 9494 | 6286 | 6393 | 3774 | 16.345 | 6020 | 9671 | 4290 | 4304 | N/A | N/A | 8634 |
| ២០០៤ | កុម្ភៈ | 9168 | 8527 | 7166 | 4645 | 13.297 | 6998 | 10.864 | 4723 | 4582 | N/A | N/A | 8045 |
| | ឧសភា | 8000 | 7452 | 7241 | 4387 | 11.822 | 6505 | 8534 | 4257 | 4095 | N/A | N/A | 8066 |
| | សីហា | 7632 | 6625 | 6650 | 4770 | 13.527 | 6095 | 8950 | 4591 | 4310 | N/A | N/A | 7986 |
| | វិច្ឆិកា | 5670 | 5094 | 6755 | 4024 | 12.117 | 5967 | 8688 | 4185 | 3944 | N/A | N/A | 8098 |
| ២០០៥ | កុម្ភៈ | 8529 | 6965 | 6386 | 5382 | 14.367 | 5712 | 11.790 | 4538 | 4174 | N/A | N/A | 7983 |
| | ឧសភា | 7726 | 7067 | 8575 | 5315 | 12.304 | 8374 | 11.411 | 4295 | 4269 | N/A | N/A | 6365 |
| | សីហា | 7857 | 6004 | 5939 | 4335 | 10.274 | 6069 | 9407 | 4647 | 4291 | N/A | N/A | 7613 |
| | វិច្ឆិកា | 8229 | 6092 | 10058 | 5636 | 11.253 | 6692 | 9774 | 3893 | 4746 | N/A | N/A | 7475 |
| ២០០៦ | កុម្ភៈ | 7873 | 6520 | 6187 | 4984 | 11.750 | 5974 | 8885 | 4670 | 4790 | N/A | N/A | 7990 |
| | ឧសភា | 8546 | 7375 | 6492 | 4512 | 9834 | 6407 | 8791 | 4243 | 5577 | N/A | N/A | 6814 |
| | សីហា | 6064 | 5239 | 5197 | 4266 | 9467 | 6029 | 6744 | 4292 | 5111 | N/A | N/A | 8029 |
| | វិច្ឆិកា | 7394 | 7046 | 7682 | 3903 | 10.215 | 5263 | 8386 | 4443 | 5747 | N/A | N/A | 7762 |
| ២០០៧ | កុម្ភៈ | 6535 | 7996 | 6514 | 4530 | 10.355 | 5094 | 9144 | 4078 | 5011 | N/A | N/A | 8211 |
| | ឧសភា | 9246 | 9798 | 8949 | 5533 | 11.892 | 6075 | 12.887 | 5151 | 5236 | N/A | N/A | 7205 |
| | សីហា | 7128 | 7705 | 9116 | 6063 | 11.410 | 5901 | 8979 | 4193 | 5578 | N/A | N/A | 7828 |
| | វិច្ឆិកា | 9393 | 8853 | 8303 | 5560 | 10.957 | 7550 | 11.525 | 4508 | 6239 | N/A | N/A | 7029 |
| ២០០៨ | កុម្ភៈ | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A |
| | ឧសភា | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A |
| | សីហា | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A | N/A |
| | វិច្ឆិកា | 12.628 | 9005 | 9926 | 4652 | 12.710 | 8779 | 15.691 | 4327 | 8697 | N/A | N/A | 6554 |
| ២០០៩ | កុម្ភៈ | 8506 | 10.442 | 7589 | 5153 | 11.732 | 6095 | 11.613 | 4268 | 7021 | N/A | N/A | 6732 |
| | ឧសភា | 7884 | 9144 | 8652 | 5881 | 12.129 | 8823 | 10.765 | 3851 | 6315 | 9868 | 6009 | 5929 |
| | សីហា | | | | | | | | | | | | |
| | វិច្ឆិកា | | | | | | | | | | | | |

ប្រភព: ទិន្នន័យបានពីអង្កេតរបស់ CDRI

ពិតវិញ កើនឡើង ៧% (តួលេខទាំង២នេះ មានសារៈសំខាន់ខាងស្ថិតិ នៅកំរិត ១%) ។ ទាំងចំណូលប្រចាំថ្ងៃពិត និងប្រាក់សន្សំ នឹងបន្តធ្លាក់ចុះ ប្រសិនបើវិបត្តិនៅតែកើតមានជាបន្ត ។ កាលពីខែឧសភា ២០០៩ ក្នុងចំណោមកម្មករកាត់ដេរ ១២០នាក់ ដែលបានឆ្លើយសម្ភាសន៏ មានតែ ២១% ប៉ុណ្ណោះ ដែលរំពឹងថា ចំណូលរបស់ខ្លួននៅឆ្នាំ២០១០ នឹងមានបរិមាណច្រើនជាងឆ្នាំ២០០៨ ប៉ុន្តែមាន ៤២% បានប្រាប់ថា ប្រាក់ចំណូលរបស់ខ្លួនអាចនឹងនៅដដែល ឬធ្លាក់ទាបជាងនេះ ។

## ៤. សេចក្ដីសន្និដ្ឋាន

អត្ថបទនេះមានគោលដៅធ្វើការវាយតម្លៃពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល ទៅលើពលករងាយរងគ្រោះ នៅប្រទេសកម្ពុជា ។ ចាប់តាំងពីដើមឆ្នាំ២០០៩ នេះមក ការសិក្សាវាយតម្លៃរហ័សមួយចំនួន (Kang et al. 2009; Jalilian et al. 2009) ពីផលប៉ះពាល់ម៉ាក្រូសេដ្ឋកិច្ច បង្កពីវិបត្តិ បានបង្ហាញថា ផលប៉ះពាល់អាចកាន់តែធ្ងន់ធ្ងរ ដោយសារការរួមចុះនៃវិស័យកាត់ដេរ ទេសចរណ៏ និងសំណង់ ។ ការសិក្សានេះបានរកឃើញថា វិបត្តិបានប៉ះពាល់ធ្ងន់ធ្ងរបំផុតទៅលើកម្មករកាត់ដេរ ព្រោះវិស័យកាត់ដេរពឹងផ្អែកខ្លាំងលើតំរូវការពីសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ប៉ុន្តែប៉ះពាល់មិនសូវខ្លាំងប៉ុន្មានទេ ទៅលើពលករងាយរងគ្រោះ ៩ក្រុមផ្សេងទៀត ។ ចំពោះពលករខាងទេសចរណ៏ និងពលករចំណាកស្រុក ការវិភាគបែបគុណភាព បានបង្ហាញថា ជីវភាពរបស់ពួកគេកាន់តែយ៉ាប់យ៉ឺនខ្លាំងណាស់ ។ ដើម្បីឆ្លើយតបនឹងវិបត្តិសេដ្ឋកិច្ចសាកលនេះ រដ្ឋាភិបាលកម្ពុជាបានអនុវត្តគោលនយោបាយជាច្រើនសំរាប់វិស័យកាត់ដេរ ជាអាទិ ការផ្អាកការប្រមូលអាករលើផលរបរប្រចាំខែ ១% លើការចំណាយរបស់រោងចក្រ ការកាត់បន្ថយ ១០% លើប្រាក់កំរៃគ្រប់គ្រងការនាំចេញ និងចំណាយផ្សេងទៀត និង ការផ្ដល់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈរយៈពេលខ្លី ដល់ពលករដែលត្រូវបញ្ឈប់ពីការងារ និងពលករគ្មានការងារធ្វើ (សំរាប់ ព័ត៌មានលំអិត សូមមើលអត្ថបទរបស់ Jalilian et al. 2009) ។ ការប្រមើលមើលពីចំណូលប្រចាំថ្ងៃនៅឆ្នាំ២០១០ ក៏នៅឃើញអាប់អួរដែរ ៕

## ឯកសារយោង


Jalilian, Hossein et al. (April 2009), The Global Financial Crisis and Developing Countries: Cambodia (Phnom Penh: CDRI )

Kang Chandararot et al. (January 2009), Rapid Assessment on the Impact of the Financial Crisis in Cambodia (Phnom Penh: CIDS)


---

តពីទំព័រ ១ **ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច ...**

និងចំនួនការងារក្នុងវិស័យនេះ ។ ការធ្លាក់ចុះនេះ ជាបន្តមកទៀតក៏បានប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលទៅលើជីវភាពរបស់ពលករក្នុងវិស័យកាត់ដេរ និងអ្នកទទួលការផ្គត់ផ្គង់ពីពលករទាំងនេះ ។ គួបផ្សំនឹងការថយចុះចំនួនអ្នកទេសចរចូល និងការធ្លាក់ចុះសកម្មភាពសាងសង់ ដែលបង្កមួយចំណែកដោយការធ្លាក់ចុះ FDI ក៏ដូចជាផលប៉ះពាល់អាក្រក់នៃការធ្លាក់ចុះសេដ្ឋកិច្ចនៅតាមប្រទេសជាដៃគូពាណិជ្ជកម្មសំខាន់ៗផង សុខុមាលភាព និងជីវភាពរបស់ជនងាយរងគ្រោះ និងប្រជាជនក្រីក្រនៅកម្ពុជា បានទទួលការប៉ះពាល់ធ្ងន់ធ្ងរ ។

វិបត្តិហិរញ្ញវត្ថុសាកល និងវិបត្តិហិរញ្ញវត្ថុអាស៊ីនៅឆ្នាំ១៩៩៧ បានគូសរំលេចពីសារៈសំខាន់នៃការត្រួតពិនិត្យ និងបទបញ្ញត្តិគ្រប់គ្រងវិស័យហិរញ្ញវត្ថុ ។ ទទឹមគ្នានេះ វាក៏បានចោទជាសំណួរទៅលើវិធីសាស្ត្រ ដែលប្រទេសកំពុងអភិវឌ្ឍន៏ជាច្រើនបានអនុម័តប្រើ ដោយមានការជំរុញពីស្ថានប័នពាក់ព័ន្ធសំខាន់ៗ ដូចជា មូលនិធិរូបិយវត្ថុអន្តជាតិ ធនាគារពិភពលោកជាដើម គឺបានព្យាយាមចំលងយកគំរូអភិវឌ្ឍទីផ្សារមូលធន និងហិរញ្ញវត្ថុនៅបណ្ដាប្រទេសមានការអភិវឌ្ឍន៏ជឿនលឿន ដោយពុំទាន់ទាំងបំពេញបាននូវលក្ខខណ្ឌដ៏ចាំបាច់ផ្សេងៗនៅឡើយ ។ ឧទាហរណ៏ ប្រទេសទាំងនោះមិនបានព្យាយាមអភិវឌ្ឍវិស័យហិរញ្ញវត្ថុមួយសាមញ្ញ ស្របតាមតំរូវការក្នុងស្រុកទេ ប៉ុន្តែទៅពឹងផ្អែកយ៉ាងខ្លាំងលើបណ្ដាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដែលមានអត្រាបំណុលកំរិតខ្ពស់ ហើយខំប្រឹងបង្កើតទីផ្សារមូលធនបែបទំនើបស្មុគស្មាញ ដូចជា ផ្សារហ៊ុន ជាដើម ដោយមិនបានពិចារណាល្អិតល្អន់ពីតំរូវការអភិវឌ្ឍន៏ក្នុងស្រុក ព្រមទាំងកត្តាចំណេញខាតជាប់ទាក់ទិននានា ។ ប្រទេសកម្ពុជាកំពុងត្រូវការជាខ្លាំងនូវ ស្ថាប័នហិរញ្ញវត្ថុសម្រាប់ដំណើរការក្នុងស្រុក ដែលអាចសំរបសំរួលរវាងអ្នកសន្សំប្រាក់ និងអ្នកខ្ចីប្រាក់ ជាពិសេសនៅតាមតំបន់ជនបទ ដោយមិនមានពាក់ព័ន្ធនិងអន្តរកម្មហិរញ្ញវត្ថុបែបទំនើប និងស្មុគស្មាញនោះទេ ។ ក្នុងដំណាក់កាលអភិវឌ្ឍន៏សព្វថ្ងៃនេះ គេមិនច្បាស់ទេថា ប្រទេសកម្ពុជាអាចបានចំណេញអ្វីខ្លះពីការបង្កើតទីផ្សារភាគហ៊ុនតាមការគ្រោងទុកនោះទេ ។ ពិតហើយ ទីផ្សារភាគហ៊ុន និងទីផ្សារមូលធនផ្សេងទៀតនឹងមានតំរូវការក្នុងរយៈពេលវែង ប៉ុន្តែតំរូវការក្នុងអនាគតដ៏ខ្លីខាងមុខ គឺជាសំនួរមួយយ៉ាងធំ ។

ក្នុងពេលថ្មីៗនេះ វិទ្យាស្ថាន CDRI បានអនុវត្តឱ្យ ធនាគារពិភពលោកនូវការវាយតំលៃរហ័សមួយស្ដីពីផលប៉ះពាល់នៃវិបត្តិទៅលើជីវភាពរបស់ជនងាយរងគ្រោះ និងប្រជាជនក្រីក្រនៅកម្ពុជា ។ អត្ថបទនានាដែលចុះផ្សាយក្នុងទស្សនាវដ្ដីអភិវឌ្ឍន៏កម្ពុជា លេខនេះ បានផ្អែកលើប្រធានបទមួយចំនួននៃការសិក្សាស្រាវជ្រាវដែលធ្វើឡើង នៅខែឧសភា ២០០៩ ។ ដូចការរំពឹងទុក លទ្ធផលរកឃើញមួយចំនួនដែលផ្អែកលើការវិភាគបែបបរិមាណ មិនបានបញ្ជាក់គាំទ្រដល់លទ្ធផលរកឃើញតាមការវិភាគបែបគុណភាព ជាពិសេស លទ្ធផលបានមកពីការពិភាក្សាតាមក្រុមស្នូលនោះទេ ។ ចំណុចនេះបានជួយបង្ហាញពី ដែនកំណត់នៃការវាយតម្លៃរហ័សដែលមានរយៈពេល និងធនធានមានកំណត់ ព្រមទាំងពីតំរូវការធ្វើអង្កេតលំអិតបន្ថែមទៀត ៕

# ការវាយតម្លៃរហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល ទៅលើគ្រួសារនៅកម្ពុជា: ឥទ្ធិពល និង យុទ្ធសាស្ត្រដោះស្រាយ*

## ១. សេចក្តីផ្តើម

កម្ពុជា ធ្លាប់រីកលូតលាស់យ៉ាងខ្លាំងដោយមានកំណើន ផសស ជាមធ្យម ប្រហែល ១១% ក្នុងរយៈពេលបីឆ្នាំបន្តបន្ទាប់ នៅមុនពេលវិបត្តិហិរញ្ញវត្ថុសាកល បានរាលដាលមកដល់កម្ពុជានៅចុងឆ្នាំ២០០៨ ។ កំណើននេះ ជំរុញឡើងជាសំខាន់ដោយវិស័យកាត់ដេរ ទេសចរណ៍ សំណង់ និង កសិកម្ម ប៉ុន្តែវាបានថយចុះមកវិញ ដោយសារការប៉ះទង្គិចមួយចំនួននៅឆ្នាំមុន ជាអាទិ៍ ការឡើងថ្លៃខ្ពស់នៃអាហារ និងថាមពល ជំលោះព្រំដែនជាមួយប្រទេសថៃ និង ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក នាពេលថ្មីៗនេះ ។ អាហារ និង ថាមពលដែលស្ទុះឡើងថ្លៃយ៉ាងខ្លាំង ចាប់ពីចុងឆ្នាំ២០០៧ រហូតដល់ពាក់កណ្តាលឆ្នាំ២០០៨ បានប៉ះពាល់ធ្ងន់ធ្ងរដល់អត្រាប្រាក់ចំណេញ ទទួលបានពីវិនិយោគ និង សុខុមាលភាពរបស់គ្រួសារនៅទូទាំងប្រទេសកម្ពុជា ។ ជំលោះព្រំដែនជាមួយថៃ បណ្តាលឱ្យមានការធ្លាក់ចុះចំនួនភ្ញៀវទេសចរ និង ការនាំចេញផលិតផលកសិកម្ម ។ រីឯ វិបត្តិសេដ្ឋកិច្ចសាកល បានប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចកម្ពុជា ដែលពឹងផ្អែកចំបងលើការនាំចេញផលិតផលទៅទីផ្សារពិភពលោក ។ ការគន់គូរសំរាប់ឆ្នាំ២០០៩ បានបង្ហាញពីការធ្លាក់ចុះកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ (ចុះដល់ត្រឹម ២% បើតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) រឺក៏ -0,៥% បើតាមមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)) ដោយសារវិបត្តិសេដ្ឋកិច្ចសាកល ។

មានការសិក្សាមួយចំនួនតូចបានប្រឹងប្រែងវាយតម្លៃពី ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល មកលើសេដ្ឋកិច្ចកម្ពុជា និង ផ្តល់ជាជំរើសគោលនយោបាយមួយចំនួនដែលសមស្របសំរាប់កាត់បន្ថយឥទ្ធិពលវិបត្តិ ។ ជាក់ស្តែង លោក Kang et al. (2009) បានព្យាយាមវាយតម្លៃនៅកំរិតម៉ាក្រូសេដ្ឋកិច្ច និងកំរិតតាមវិស័យ (កាត់ដេរ សំណង់ ទេសចរណ៍ និងកសិកម្ម) ព្រមទាំងស្រាវជ្រាវលំអិតពីទីផ្សារពលកម្ម និងសេដ្ឋកិច្ចតាមគ្រួសារ ។ ហើយលោក Jalilian et al. (2009) បានធ្វើការសិក្សាផ្តោតតែលើ កំរិតម៉ាក្រូសេដ្ឋកិច្ច ។ ការសិក្សាទាំងពីរបានបង្ហាញថា វិបត្តិសេដ្ឋកិច្ចសាកលបានប៉ះពាល់ធ្ងន់ធ្ងរបំផុតដល់វិស័យកាត់ដេរ (កម្មករ ៥១.000នាក់ ត្រូវបានបញ្ឈប់ពី ការងារ) បន្ទាប់មក គឺវិស័យសំណង់ (កម្មករ ១៥.000នាក់ បញ្ឈប់ពីការងារ) និងបន្ទាប់មកទៀត គឺ វិស័យទេសចរណ៍ (កំណើនធ្លាក់ដល់ -៥% នៅឆ្នាំ២០០៩) ។ វិបត្តិសេដ្ឋកិច្ចតែមួយមុខ ទំនងមិនអាចធ្វើឱ្យវិស័យកសិកម្មខូចខាតធ្ងន់ធ្ងរទេ (Jalilian et al. 2009; Kang et al. 2009) ប៉ុន្តែវិបត្តិទាំងបីខាងលើគួបផ្សំគ្នាពិតជាអាច (Theng 2009 a, b; Jalilian et al. 2009) ។

ថ្វីបើការសិក្សាមួយចំនួនពីមុននេះ ព្យាយាមស្វែងយល់ស៊ីជម្រៅពីទីផ្សារពលកម្ម និងសេដ្ឋកិច្ចតាមគ្រួសារ ប៉ុន្តែការងារភាគច្រើនផ្តោតតែលើកំរិតម៉ាក្រូសេដ្ឋកិច្ច ដោយមិនបានពិនិត្យមើលថា តើប្រជាជនត្រូវប៉ះពាល់បែបណាដោយសារវិបត្តិនានាក្រៅពីវិបត្តិសាកល និង តើពួកជនងាយរងគ្រោះបានទប់ទល់បែបណា ជាលក្ខណៈបុគ្គល គ្រួសារ និងសមូហភាព ។ គោលបំណងជាក់លាក់នៃ ការវាយតម្លៃរហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល ដែលផ្តល់ថវិកាដោយធនាគារពិភពលោក និងសម្របសម្រួលដោយក្រុមស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI គឺ បង្ហាញពីផលប៉ះពាល់ផ្សេងៗនៃវិបត្តិសេដ្ឋកិច្ចសាកល ចំពោះបុគ្គលម្នាក់ៗ និង ចំពោះគ្រួសារ ដែលមានរួមចំណែកទាំងនៅក្នុងវិស័យរៀបរយ និងមិនរៀបរយ នៃសេដ្ឋកិច្ចកម្ពុជា ។ ការសិក្សានេះ ក៏មានបំណងផ្តល់ជូនអ្នកធ្វើផែនការ និងអ្នកកសាងគោលនយោបាយក្នុងជួររដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍ នូវព័ត៌មានសំខាន់ៗស្តីពី បែបបទដែលជនក្រីក្រ និងជនងាយរងគ្រោះ កំពុងប្រើប្រាស់ដើម្បីទប់ទល់នឹងវិបត្តិ ក្នុងពេលដែលមិនទាន់មានប្រព័ន្ធសុវត្ថិភាពសង្គមរបស់រដ្ឋាភិបាល ។

## ២. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីស៊ើបសួរពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល ទៅលើបុគ្គល និង គ្រួសារ ការសិក្សានេះបានប្រើវិធីសាស្ត្របែបគុណភាព ដោយធ្វើសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ ឬសម្ភាសន៍ពាក់កណ្តាលរៀបរយ (Semi-Structured Interview—SSIs) និងការពិភាក្សាតាមក្រុមស្នូល (FGD) និង បានប្រើឧបករណ៍ ខ្សែបន្ទាត់ពេល (time-line) ដើម្បីស្វែងយល់ស៊ីជម្រៅពីបទពិសោធន៍ដែលអ្នកផ្តល់ព័ត៌មានបានឆ្លងកាត់ក្នុងរយៈពេល ១២ខែ និង ៦ខែ មុនពេល ធ្វើការវាយតម្លៃនេះ (ខែឧសភា ២០០៩) ។ SSIs ត្រូវបានធ្វើឡើងជាមួយបុគ្គលពីររូប ដែលជ្រើសរើសដោយមានគោលដៅចេញពីក្រុមជនងាយរងគ្រោះ[១] (បូកនឹងកម្មករកាត់ដេរ ចំនួន ៥នាក់) និង

---

* អត្ថបទនេះ រៀបចំដោយ បណ្ឌិត ថេង វុទ្ធី និង លោក គីម សុធន ។ បណ្ឌិត ថេង វុទ្ធី ជាអ្នកសម្របសម្រួលកម្មវិធី ភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៅ CDRI ហើយ លោក គីម សុធន ជាអ្នកស្រាវជ្រាវក្នុងកម្មវិធីជាមួយគ្នា ។ អត្ថបទនេះ ជាសេចក្តីសង្ខេបនូវលទ្ធផលរកឃើញជាក់ស្តែង ក្នុងការវាយតម្លៃរហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល ទៅលើគ្រួសារនៅកម្ពុជា ដែលធ្វើឡើយដោយក្រុមស្រាវជ្រាវ របស់ CDRI កាលពីខែឧសភា ២០០៩ ដោយទទួលថវិកាពីធនាគារពិភពលោក ។

១ កម្មករងាយរងគ្រោះ គឺមាន អ្នកធាក់ស៊ីក្លូ អ្នករត់ម៉ូតូឌុប អ្នកលីសែង កម្មករសំណង់មានជំនាញ និងគ្មានជំនាញ អ្នកបំរើតុភោជនីយដ្ឋាន កម្មករកាត់ដេរ អ្នករើសអេតចាយ និងអ្នកលក់បន្លែតូចតាច (ក្នុងទីក្រុងភ្នំពេញ) កសិករ (ភូមិប៉ៃលហែល ខេត្តកំពង់ស្ពឺ និង ភូមិដូនវង្ស ខេត្តកណ្តាល) អ្នករត់ម៉ូតូទុកទុក បុគ្គលិកភោជនីយដ្ឋាននិងសណ្ឋាគារ (ខេត្តសៀមរាប) និង ជនចំណាកស្រុក (ភូមិអណ្តូងត្រាច និង ក្រសាំង ខេត្តបាត់ដំបង) ។

គ្រួសារក្រីក្រនៅតាមជនបទក្នុងការសិក្សាពីឌីណាមិកនៃភាពក្រីក្រ[២] (PDS) និង មេភូមិ ៩នាក់ ដែលសរុបមកបាន ៥៦ SSIs ។ រីឯ FGDs វិញ ត្រូវបានធ្វើឡើងជាមួយ ១៣ ក្រុមពលករងាយរងគ្រោះ គឺមាន អ្នកធាក់ស៊ីក្លូ អ្នករត់ម៉ូតូទុកទុក និងអាជីវករតូចតាច, កម្មករសំណង់មានជំនាញ និងគ្មានជំនាញ កម្មករកាត់ដេរ អ្នកស៊ីឈ្នួលធ្វើស្រែនៅភូមិដូនវង្ស និង គ្រួសារក្រីក្រនៅភូមិអណ្តូងត្រាច ក្រសាំង ត្រពាំងព្រៃ កំពង់ត្នោត និង បាបោង ។ របកគំហើញនៃការសិក្សា បង្ហាញត្រឹមតែបទពិសោធន៍របស់ក្រុមគំរូតាងទាំងនេះប៉ុណ្ណោះ ដូច្នេះ ត្រូវប្រុងប្រយ័ត្ននៅពេលយកទិន្នន័យនេះទៅប្រើប្រាស់ជារួមសំរាប់ក្រុមដទៃទៀត ។

## ៣. របកគំហើញផ្អែកលើពិសោធន៍ជាក់ស្តែង

### ៣.១. ឥទ្ធិពលនៃវិបត្តិ ទៅលើ បុគ្គល និង គ្រួសារ

*ការងារ ប្រាក់ចំណូល និង ប្រាក់ផ្ញើទៅផ្ទះ*

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យរៀបរយដែលជំរុញ កំណើនសេដ្ឋកិច្ច (កាត់ដេរ សំណង់ និងទេសចរណ៍) បានផ្តល់ការងារដល់ពលកររាប់រយពាន់នាក់ ដែលធ្វើចំណាកស្រុក មកពីតំបន់ជនបទផ្សេងៗនៅកម្ពុជា និង បានជួយកែលំអជីវភាពរស់នៅរបស់ពួកគេ ។ ប៉ុន្តែ សុខុមាលភាពរបស់ពលករ និងគ្រួសាររបស់អ្នកទាំងនេះ មិនមាំទាំទេ នៅពេលមានការប៉ះទង្គិចមិនអាចដឹងមុន ។ ពលករក្នុងវិស័យ សេដ្ឋកិច្ចមិនរៀបរយ ក៏ងាយរងគ្រោះដូចពលករក្នុងវិស័យរៀបរយដែរ នៅចំពោះមុខស្ថានភាពមិនប្រាកដប្រជានៃការងារ និងប្រាក់ចំណូល ។

ព័ត៌មានទទួលបានពី SSIs និង FGDs បង្ហាញពីនិន្នាការជាទូទៅមួយនៃការថយចុះចំនួនការងារ ទាំងនៅទីក្រុងភ្នំពេញ និងតំបន់ជនបទ ប្រហែលពី ៣០%-៤០% ក្នុងរយៈពេល ៦ខែចុងក្រោយ និងថយចុះប្រហែល ៧០% ក្នុងផ្នែកសាងសង់ ។ ការធ្លាក់ចុះសេដ្ឋកិច្ច បានប៉ះពាល់ច្បាស់ណាស់ទៅលើវិស័យកាត់ដេរ សំណង់ និងទេសចរណ៍ និងប៉ះពាល់មួយកំរិតទៅលើវិស័យកសិកម្ម ។ ឧទាហរណ៍ កម្មករកាត់ដេរកំពុងបំរើការងារ បានរាយការណ៍ពីការបាត់បង់ការងារម៉ោងបន្ថែម ឬ ការកាត់បន្ថយចំនួនថ្ងៃធ្វើការ ដែលជាបញ្ហាបារម្ភធំមួយ ព្រោះវាប៉ះពាល់យ៉ាងខ្លាំងទៅលើចំណូលប្រចាំខែរបស់កម្មករ ។ ក្នុងរយៈពេល ៦ខែកន្លងទៅនេះ ពួកកម្មករមិនអាចសន្សំប្រាក់ផ្ញើទៅផ្ទះបានទេ ដោយសារចំណូលប្រចាំខែរបស់ពួកគេ ស្ទើរតែមិនគ្រប់សំរាប់ដោះស្រាយចំណាយប្រចាំថ្ងៃរបស់ខ្លួនបានផង ។

ចំនួនការងារដែលមានសំរាប់កម្មករសំណង់ (កម្មករមានជំនាញ និងគ្មានជំនាញ) នៅរាជធានីភ្នំពេញ និងខេត្តបាត់ដំបង បានធ្លាក់ចុះយ៉ាងច្រើនក្នុង ៦ខែមុននេះ ។ ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ នៅទីក្រុងភ្នំពេញ មានលក្ខណៈមិនទៀងទាត់ឡើយ ដោយនៅថ្ងៃខ្លះអាចរកចំណូលបាន និងថ្ងៃខ្លះទៀត គ្មានការងារធ្វើទេ ។ ជាលទ្ធផល ទោះបីជាអត្រាប្រាក់កំរៃការងារនៅថេរក៏ដោយ ក៏ប្រាក់ចំណូលរបស់ពួកគេ ស្ទើរតែមិនគ្រប់សំរាប់ដោះស្រាយចំណាយ លើការរស់នៅប្រចាំថ្ងៃក្នុងទីក្រុងផង ហើយពួកគេមិនអាចសន្សំប្រាក់សំរាប់ផ្ញើទៅជួយក្រុមគ្រួសារបានទេ ។ ចំណូលប្រចាំខែរបស់កម្មករសំណង់មានជំនាញ ក៏បានថយចុះដែរ ដោយសារការថយចុះចំនួនការងារដែលមាន ។ ប៉ុន្តែកម្មករមានជំនាញ មិនសូវងាយរងគ្រោះដូចកម្មករគ្មានជំនាញទេ (កម្មករទូទៅដែលធ្វើការនៅតាមការដ្ឋានសំណង់កំពុងដំណើរការ) ដោយសារទីផ្សារនៅមានតំរូវការពលកម្មរបស់ពួកគេ ។ កម្មករមានជំនាញក៏ទទួលប្រាក់កំរៃ ច្រើនជាង កម្មករគ្មានជំនាញដែរ ហើយពួកគេអាចសន្សំប្រាក់ បានច្រើនជាង ពួកកម្មករទូទៅ (១០០.០០០-១៥០.០០០៛ ក្នុង១ខែ) ។

ចំនួនថ្ងៃធ្វើការរបស់បុគ្គលិក សណ្ឋាគារ និងភោជនីយដ្ឋាន នៅខេត្តសៀមរាប បានធ្លាក់ចុះ ៣០-៤០% ដោយសារការធ្លាក់ចុះចំនួនអតិថិជនអស់ ២០-៣០% ។ បុគ្គលិកទាំងនេះ ត្រូវធ្វើការខ្លាំងជាងមុន ដោយសារបុគ្គលិកបណ្តែតជាច្រើនត្រូវបានបញ្ឈប់ពីការងារ ។ ទោះបីក្នុងរយៈពេល ៦ខែកន្លងទៅនេះ ពួកគេត្រូវធ្វើការច្រើនជាងមុនក៏ដោយ ប៉ុន្តែពួកគេទទួលបានចំណូលដដែល គឺ បានជាមធ្យម ៦៥-១០០ដុល្លារអាមេរិក បូកទាំងប្រាក់ទឹកតែបានពីភ្ញៀវផង ។ ពួកគេមិនអាច ឬអាចសន្សំប្រាក់បានតិចតួចសំរាប់ផ្ញើទៅឱ្យឪពុកម្តាយ រឺក្រុមគ្រួសារនៅផ្ទះ ហើយប្រាក់នេះមិនបានទៀងទាត់ដូចកាលពីមុនឡើយ ។

កម្មករចំណាកស្រុក ដែលបំរើការក្នុងចំការដំឡូងឈើ ពោត សណ្តែក ផ្លែឈើផ្សេងៗ និង ចំការកៅស៊ូ បានជួបនឹងការធ្លាក់ចុះតម្រូវការពលកម្មទាំងនៅប្រទេសថៃ និងនៅប្រទេសកម្ពុជា ដោយសារទំនាស់ព្រំដែន និងការថយចុះកំរិតថ្លៃ និងបរិមាណនាំចេញកសិផល ។ ក្នុងរយៈពេល ៦ខែកន្លងទៅនេះ ប្រាក់ចំណូលរបស់ពួកគេ ធ្លាក់ចុះជាខ្លាំង ដោយសារមានការងារតិច និងការថយចុះប្រាក់កំរៃពលកម្ម ពី ៣០០បាត/ថ្ងៃ (៣៩៦៥០៛/ថ្ងៃ) មកត្រឹម ១២០បាត/ថ្ងៃ (១៤២៦០៛/ថ្ងៃ) ហើយ ប្រាក់ផ្ញើទៅផ្ទះក៏ថយចុះអស់ពាក់កណ្តាលដែរ ។

ការងារដែលមានសំរាប់កម្មករ និងអាជីវករតូចតាច ក្នុងវិស័យសេដ្ឋកិច្ចមិនរៀបរយ បានធ្លាក់ចុះយ៉ាងខ្លាំង ។ ប្រាក់ចំណូលរបស់អ្នករត់ម៉ូតូទុកទុក នៅខេត្តសៀមរាប បច្ចុប្បន្នបានធ្លាក់ចុះមកត្រឹម ១០.០០០-៣០.០០០៛ ធៀបនឹងចំណូលរហូតដល់ ៦០.០០០៛/ថ្ងៃ កាលពីមុន ដោយសារការធ្លាក់ចុះយ៉ាងខ្លាំងនៃចំនួនភ្ញៀវទេសចរបរទេស និងក្នុងស្រុក គួបផ្សំនឹងកំណើនចំនួនអ្នករត់ម៉ូតូទុកទុក ក្នុងរយៈពេល ៦ខែកន្លងទៅនេះ ។ ចំណូលប្រចាំថ្ងៃរបស់អ្នកធាក់ស៊ីក្លូ ក៏បានធ្លាក់ចុះអស់ជិត ៣០% ដែរ គឺពី ៧.០០០៛/ថ្ងៃ មកត្រឹមប្រហែល ៥.០០០៛/ថ្ងៃ ដោយសារការថយចុះចំនួនអតិថិជន ។ អ្នករត់ម៉ូតូទុកទុក និងអ្នកធាក់ស៊ីក្លូភាគច្រើន បានធ្វើចំណាកស្រុកមកពីទីជនបទ ដូច្នេះការធ្លាក់ចុះប្រាក់ចំណូលប្រចាំថ្ងៃបានប៉ះពាល់យ៉ាងខ្លាំងដល់ទឹកប្រាក់ផ្ញើទៅផ្ទះ ។ អាជីវករតូចតាចនៅខេត្តសៀមរាប បានរាយការណ៍ពីការធ្លាក់ចុះប្រាក់ចំណូលយ៉ាងខ្លាំង (លើសពី ៥០% ក្នុងរយៈពេល៦ខែ

---

២ ភូមិដែលជាគោលដៅនៃ PDS មាន : ភូមិអណ្តូងត្រាច និង ក្រសាំង (ខេត្តបាត់ដំបង) ភូមិខ្សាច់ជីរស់ និង ដងក្តារ (ខេត្តកំពង់ធំ) ភូមិកញ្ជរ (ខេត្តក្រចេះ) ភូមិព្រៃកក្មេង (ខេត្តកណ្តាល) ភូមិបាបោង (ខេត្តព្រៃវែង) ភូមិត្រពាំងព្រៃ (ខេត្តកំពង់ស្ពឺ) និង ភូមិកំពង់ត្នោត (ខេត្តកំពត) ។

ចុងក្រោយ) ពី ១០០.០០០៛/ថ្ងៃ មកត្រឹម ៤០.០០០-៥០.០០០៛/ថ្ងៃ ដោយសារការថយចុះភ្ញៀវទេសចរ និងកំណើនចំនួនអាជីវករ ពីព្រោះពួកកម្មករដែលបាត់បង់ការងារក្នុងវិស័យផ្លូវការ បានមកប្រកបរបរនេះដែរ ។ អ្នកលក់បន្លែតូចតាច នៅរាជធានីភ្នំពេញ បានរាយការណ៍ដូចគ្នាពីការធ្លាក់ចុះប្រាក់ចំណូលយ៉ាងខ្លាំង ដោយសារមានអតិថិជនតិចជាងមុន ហើយពួកអ្នកទិញស្វែងរកទំនិញថោកៗ និងតថ្លៃខ្លាំងជាងមុន ។ អ្នកលីសែងនៅតាមទីផ្សារបានធ្លាក់ចុះប្រាក់ចំណូលអស់ ២០-៤០% ដោយសារការថយចុះ តំរូវការសេវាកម្មរបស់ពួកគេ ។ ការផ្លាស់ប្តូរឥរិយាបថក្នុងការចាយវាយរបស់ប្រជាជនទីក្រុង និងជនបទ កំពុងបង្កបំរែបំរួលក្នុងប្រាក់ចំណូលរបស់អ្នករើសអេតចាយនៅកន្លែងចាក់សំរាមស្ទឹងមានជ័យ និងកន្លែងឯទៀតៗ ។ ប្រាក់ចំណូលរបស់ក្រុមនេះ ស្ទើរតែមិនគ្រប់សំរាប់ដោះស្រាយចំណាយប្រចាំថ្ងៃផង ហើយពួកគេមិនមានលទ្ធភាព ឬមានលទ្ធភាពតិចតួចបំផុតក្នុងការសន្សំប្រាក់សំរាប់ផ្ញើទៅផ្ទះនៅតាមទីជនបទ ។

## *ការងារនៅជនបទ និងចំណូលគ្រួសារ*

ការលក់ដីនៅតាមតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា នៅអំឡុងពេលដីឡើងថ្លៃខ្ពស់ រហូតមកទល់ឆ្នាំ២០០៧ គឺជាកត្តាចំបងមួយនៃការថយចុះចំនួនការងារក្នុងវិស័យកសិកម្ម ប៉ុន្តែវិបត្តិសាកល ក៏មានចំណែកក្នុងបញ្ហានេះដែរ ។ ចាប់តាំងពីវិបត្តិបានផ្ទុះឡើងនៅចុងឆ្នាំ២០០៨ តំរូវការកំលាំងពលកម្មក្នុងវិស័យកសិកម្ម (ជាពិសេស ពលករស៊ីឈ្នួលធ្វើស្រែ) នៅតាមភូមិបានធ្លាក់ចុះអស់ ៣០-៤០% ហើយប្រាក់កំរៃប្រចាំថ្ងៃរបស់ពលករស៊ីឈ្នួលធ្វើស្រែ បានថយចុះអស់ប្រហែល ៣០-៥០% ។ កសិករដំណាំស្រូវ ត្រូវធ្វើការដាំដុះលើដីរបស់ខ្លួនឯងផ្ទាល់ ពីព្រោះពុំមានប្រាក់សំរាប់ជួលពលករផ្សេងទៀត ដោយសារការថយចុះប្រាក់ផ្ញើមកពីសមាជិកគ្រួសារទៅធ្វើការខាងកាត់ដេរ និងសំណង់ និងដែលបានត្រលប់មកផ្ទះមួយរយៈ ដើម្បីជួយការងារក្នុងរដូវធ្វើស្រែ ។ អ្នកភូមិដែលបានលក់ដីដាំដុះនៅអំឡុងពេលមានកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងឆ្នាំ២០០៧-២០០៨ បានផ្លាស់ប្តូរពីការងារធ្វើស្រែ ទៅធ្វើជាអ្នកលក់ពលកម្មនៅក្នុងភូមិរបស់ខ្លួន ឬក៏ធ្វើចំណាកស្រុកទៅរកការងារនៅទីក្រុង ។ អ្នកទាំងនេះភាគច្រើនជាគ្រួសារគ្មានដីធ្លី ឬមានដីតិចតួច ដែលពឹងពាក់ខ្លាំងលើប្រាក់ផ្ញើពីសមាជិកគ្រួសារចេញទៅបំរើការ ក្នុងវិស័យកាត់ដេរ ឬសំណង់ ។ ជាភ័ព្វអាក្រក់ ប្រាក់ផ្ញើមកផ្ទះបានថយចុះអស់ប្រហែល ៥០% ដោយមានការងារតិច ហើយចំណូលដែលរកបានក្នុងភូមិស្រុក ក៏ថយចុះយ៉ាងខ្លាំងដែរដោយសារការប្រកួតប្រជែងខ្លាំងក្នុងចំណោមអ្នកភូមិ ។ អ្នកទាំងនេះជាក្រុមងាយរងគ្រោះខ្លាំងជាងគេដោយសារវិបត្តិសេដ្ឋកិច្ចសាកល ដូចជា ពួកគ្រួសារក្រីក្រនៅជនបទក្នុងភូមិត្រពាំងព្រៃ និង ប៉ែលហែល ក្នុងខេត្តកំពង់ស្ពឺ និង ភូមិដូនវង្សក្នុងខេត្តកណ្តាល ជាដើម ។

ចំពោះអ្នកភូមិមានដីស្រែវិញ វិបត្តិសាកលហាក់ដូចគ្រាន់តែជាកត្តាមួយក្នុងចំណោមកត្តាជាច្រើន ដែលជះឥទ្ធិពលទៅលើសេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់ ហើយដែលមិនសូវធំដុំដូចហានិភ័យផ្សេងៗទៀត ដូចជា គ្រោះរាំងស្ងួត ការបំផ្លិចបំផ្លាញដោយសត្វចង្រៃ ការរិចរិលធនធានធម្មជាតិ កំណើនចំណាយលើធាតុចូល និងការធ្លាក់ថ្លៃផលដំណាំ ជាដើម ។ ក្នុងរយៈពេល ៦ខែ កន្លងទៅនេះ នៅភូមិ បាបោង អណ្តូងត្រាច និង ក្រសាំង ប្រាក់ចំណូលរបស់គ្រួសារដែលទទួលបានជាចំបងពី ផលស្រូវប្រាំង ឬផលស្រូវវស្សា និងការងារចំណាកស្រុក បានធ្លាក់ចុះ ដោយសារការកើតសត្វចង្រៃបំផ្លាញផលដំណាំ និងភ្លៀងធ្លាក់ខ្លាំងនៅពេលច្រូតកាត់ គួបផ្សំនឹងអង្ករធ្លាក់ថ្លៃ ។ គ្រួសារដែលរកចំណូលពីការនេសាទ ការធ្វើស្រែ និងការងារចំណាកស្រុក ត្រូវបានប៉ះពាល់ធ្ងន់ធ្ងរ ដោយសារការរិចរិលធនធានសមុទ្រ គ្រោះរាំងស្ងួត និងការធ្លាក់ចុះសេដ្ឋកិច្ច ។ ឧទាហរណ៍ នៅភូមិកំពង់ត្នោតត្រីចាប់បានវាធ្លាក់ចុះយ៉ាងខ្លាំង ដោយសារសកម្មភាពនេសាទខុសច្បាប់ ហើយទិន្នផលស្រូវក៏បានធ្លាក់ចុះអស់ ៥០% ដោយសារគ្រោះរាំងស្ងួតនៅឆ្នាំ២០០៨។ ក្រុមគ្រួសារដែលមានដីស្រែ និងពឹងផ្អែកលើប្រាក់ផ្ញើពីសមាជិកគ្រួសារដែលធ្វើចំណាកស្រុក បានទទួលរងឥទ្ធិពលពីវិបត្តិសេដ្ឋកិច្ចក្នុងកំរិតមួយ ដោយសារការថយចុះចំនួនការងារនៅទីក្រុង ។

## *សន្តិសុខការងារ និងការប្រកួតប្រជែង*

ពលករងាយរងគ្រោះដែលឆ្លើយសម្ភាសន៍ បានសម្តែងការព្រួយបារម្ភជាខ្លាំងពីសន្តិសុខការងារ និង សមត្ថភាពប្រកួតប្រជែង ។ ពលករធ្វើស្រែដែលជាសមាជិកគ្រួសារក្រីក្រ ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើការលក់កំលាំងពលកម្ម ដូច្នេះសន្តិសុខការងារជាកត្តាសំខាន់បំផុត ពីព្រោះក្នុងរយៈពេល ៦ខែកន្លងមកនេះ ចំនួនការងារនៅក្នុង និងនៅក្រៅកសិដ្ឋាន បានថយចុះយ៉ាងច្រើនទាំងនៅក្នុងភូមិ និងនៅក្រៅភូមិ ។ អ្នកធាក់ស៊ីក្លូមានការបារម្ភណាស់ចំពោះការប្រកួតប្រជែងយ៉ាងខ្លាំងពីសំណាក់អ្នករត់ម៉ូតូទុកទុក និងអ្នករត់ម៉ូតូឌុប ដែលបានធ្វើឱ្យប្រាក់ចំណូលរបស់ពួកគាត់ធ្លាក់ចុះ ។ កម្មករកាត់ដេរ ក៏បារម្ភណាស់ដែរពីសន្តិសុខការងារ និងការប្រកួតប្រជែងនៅកន្លែងធ្វើការ ។ ក្នុងរយៈពេល៦ខែ កន្លងទៅ ពួកគេមិនអាចតវ៉ាពីការកាត់បន្ថយការងារម៉ោងបន្ថែម និងចំនួនថ្ងៃធ្វើការបានទេ ។ បើសិនចង់ធ្វើការបន្តទៀត គឺត្រូវបង្ខំចិត្តទទួលយកប្រាក់ចំណូលប្រចាំខែតិចជាងមុន ។ កម្មករសំណង់មានជំនាញ និងគ្មានជំនាញ កំពុងបារម្ភថា អាចពិបាកនឹងរកការងារថ្មីធ្វើ នៅពេលការងារបច្ចុប្បន្នចប់អស់ទៅ ។ ក្នុងរយៈពេល ៦ខែនេះដែរ ចំនួនអ្នករត់ម៉ូតូទុកទុក និងអាជីវករតូចតាចនៅខេត្តសៀមរាប បានកើនឡើងយ៉ាងច្រើន ដោយសារពលករដែលបាត់បង់ការងារ និងបុគ្គលិកសណ្ឋាគារ និងភោជនីយដ្ឋាននៅក្រោយម៉ោងធ្វើការ បាននាំគ្នាចាប់យករបរទាំងនេះដែរ ។ សភាពការណ៍នេះគួបផ្សំនឹងការធ្លាក់ចុះយ៉ាងច្រើននៃចំនួនភ្ញៀវទេសចរបរទេស និងក្នុងស្រុក បានបង្កជាការប្រកួតប្រជែងគ្នាយ៉ាងខ្លាំង ហើយជាលទ្ធផល ប្រាក់ចំណូលប្រចាំថ្ងៃ និងប្រាក់ផ្ញើទៅផ្ទះរបស់ពួកគេ បានធ្លាក់ចុះគួរឱ្យកត់សំគាល់ ។

## *ការជាប់បំណុល*

អសមត្ថភាពក្នុងការសងបំណុល ជាបញ្ហាមួយដែល ជនក្រីក្រ និងងាយរងគ្រោះ កំពុងព្រួយបារម្ភជាខ្លាំង ។ អ្នកឆ្លើយសំភាសន៍ បានរាយការណ៍គ្រប់គ្នាពីការជាប់បំណុលយ៉ាងក្រាស់ក្រែល ជាមួយប្រភពផ្តល់កំចីផ្សេងៗ ដូចជា អ្នកផ្តល់កំចីឯកជន សាច់ញាតិ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) ជាដើម ។ ការធ្វើសម្ភាសន៍ បានឱ្យដឹងថា បំណុលភាគច្រើនបានខ្ចីគេ

លើសពី៦ខែទៅហើយ ហើយវាបានកើនឡើងថែមទៀតក្នុងរយៈពេល ៦ខែកន្លងទៅនេះ ។ ពួកគេបានយកប្រាក់កំចីទាំងនោះ ទៅចំណាយលើការថែទាំសុខភាព ឬធ្វើបុណ្យសព្វ សាងសង់ឬជួសជុលផ្ទះសម្បែង ទិញម្ហូបអាហារ ទិញធាតុចូលកសិកម្ម សងបំណុលចាស់ៗ ឬប្រើជាសោហ៊ុយនៅពេលធ្វើចំណាកស្រុក ។ ដោយសារប្រាក់ចំណូលបានធ្លាក់ចុះ ជនក្រីក្រ និងពលករងាយរងគ្រោះដែលឆ្លើយសម្ភាសន៍ មិនអាចសងបំណុលបានទេ ដូច្នេះក៏ត្រូវបង្ខំចិត្តលក់ដោះទ័លនូវទ្រព្យសម្បត្តិ ដូចជា ដីស្រែ ឬ ផ្ទះ ជាដើម (ករណីនេះកើតមានធ្ងន់ធ្ងរ នៅភូមិដូនវង្ស ត្រពាំងព្រៃ និងកំពង់ត្នោត) ។ ឧទាហរណ៍ ប្រធានភូមិត្រពាំងព្រៃបានប្រាប់ថា ចំនួនអ្នកខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុ កើនឡើង ៥០% ក្នុងរយៈពេល ៦ខែកន្លងទៅ ។ មានគ្រួសារតិចតួចណាស់ដែលអាចសងបំណុលគេវិញ និងមានប្រជាជនមួយចំនួនបានបាត់ខ្លួនពីភូមិ ។ ករណីស្រដៀងគ្នានេះ ក៏ឃើញមានរាយការណ៍ដែរនៅភូមិបាបោង និង ក្រសាំង ដែលនៅទីនោះ ការធ្វើចំណាកស្រុក បានក្លាយជាប្រភពរកការងារ និងប្រាក់ចំណូល ដើម្បីសងបំណុល ។

### *ការភ័យខ្លាចបទល្មើសព្រហ្មទណ្ឌ*

ភាពភ័យខ្លាចបទល្មើសព្រហ្មទណ្ឌ និងការព្រួយបារម្ភពីសុវត្ថិភាព នៅតែជាឧបសគ្គរារាំងដល់លទ្ធភាពរបស់អ្នកជនបទ និងជនចំណាកស្រុកនៅទីក្រុងក្នុងការប្រកបរបរចិញ្ចឹមជីវិត ។ បទព្រហ្មទណ្ឌ រួមមាន ការលួចឆក់ ការប្លន់ម៉ូតូ និងការបោកប្រាស់ដែលមានដូចជា ការមិនឱ្យប្រាក់ឈ្នួល ជាពិសេសចំពោះកម្មករសំណង់គ្មានជំនាញ និង មានជំនាញ ។ ការព្រួយបារម្ភនេះមានខ្លាំង ឬតិចទៅតាមភូមិស្រុក ទីកន្លែងធ្វើការ និងប្រភេទពលករ ប៉ុន្តែពួកមេភូមិ FGDs និងពលករងាយរងគ្រោះ បាននិយាយដល់វាជារឿយៗ ។ ចាប់ពីចុងឆ្នាំ២០០៨ ករណីលួចប្លន់ បានកើតមានកាន់តែញឹកញាប់ចំពោះកម្មករកាត់ដេរ ។ ពលករគ្មានជំនាញ អ្នកធាក់ស៊ីក្លូ និងអ្នកលីសែង ច្រើនតែនៅផ្តុំគ្នាជាក្រុមធំៗ ក្នុងនេះពួកកម្មករសំណង់គ្មានជំនាញតែងមានអារម្មណ៍សុខសប្បាយជាង បើសិនគេអនុញ្ញាតឱ្យស្នាក់នៅក្នុងការដ្ឋានសាងសង់ ។ ដោយឡែកពួកអ្នករត់ម៉ូតូឌុប និងអ្នករត់ម៉ូតូទុកទុក នៅតែងាយរងគ្រោះដោយសារបទល្មើសទាំងនេះនៅឡើយ ។

## ៣.២. យុទ្ធសាស្ត្រដោះស្រាយ

នៅពេលជីវភាពរស់នៅរបស់ខ្លួនត្រូវជួបនឹងការប៉ះទង្គិច ឬករណីអសន្តិសុខផ្សេងៗ ពលករងាយរងគ្រោះ និងគ្រួសារនៅតាមជនបទ បានប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយច្រើនបែបយ៉ាង ។ យុទ្ធសាស្ត្រជាទូទៅមួយចំនួនដែលទទួលបានពី SSIs និង FGDs មានដូចតទៅ ។

### *ការកាត់បន្ថយចំណាយប្រើប្រាស់*

ពលករងាយរងគ្រោះដែលត្រូវប្រើកំលាំងកាយដើម្បីធ្វើការ ដូចជា អ្នកធាក់ស៊ីក្លូ ពលករចំណាកស្រុក និង កម្មករសំណង់ ជាដើម គឺមិនបានកាត់បន្ថយបរិមាណអាហារទេ ប៉ុន្តែបានបន្ថយគុណភាពអាហារវិញ ពីព្រោះម្ហូបអាហារបានឡើងថ្លៃខ្លាំង[៣] ។ កម្មករសំណង់មានជំនាញ មិនបានបង្ហាញពីការកាត់បន្ថយអ្វីច្បាស់លាស់ នូវចំណាយប្រើប្រាស់លើទំនិញមិនមែនម្ហូបអាហារនោះទេ ប៉ុន្តែបានបង្កើនចំណាយលើការធ្វើដំណើរ ដោយពួកគេតែងធ្វើដំណើរទៅផ្ទះញឹកញាប់ជាងមុន នៅពេលមិនសូវមានការងារធ្វើនៅទីក្រុង ព្រោះពួកគេនៅសល់ប្រាក់ច្រើនគួរសម សម្រាប់ការធ្វើដំណើរ ។ ចំពោះកម្មករសំណង់គ្មានជំនាញ ពលករចំណាកស្រុក និងអ្នកធាក់ស៊ីក្លូវិញ ពួកគេបានកាត់បន្ថយចំណាយធ្វើដំណើរ ដើម្បីសំចៃប្រាក់ ព្រោះពុំមានលទ្ធភាពដោះស្រាយសោហ៊ុយធ្វើដំណើរ ដោយសារប្រាក់ចំណូលធ្លាក់ចុះខ្លាំងណាស់ ។ ពួកគេក៏បានកាត់បន្ថយច្រើនដែរ នូវចំណាយលើទំនិញមិនមែនអាហារ ដូចជា សំលៀកបំពាក់ ស្រា បារី ជាដើម ។ ក្រុមពលករងាយរងគ្រោះដទៃទៀត ក៏បានរាយការណ៍ដូចគ្នា ពីការកាត់បន្ថយចំណាយប្រើប្រាស់ ទាំងលើទំនិញ ជាអាហារ និងមិនមែនអាហារ ដែលជាមធ្យោបាយទី១សំរាប់ទប់ទល់នឹងវិបត្តិ ។

គ្រួសារក្រីក្រនៅជនបទ បានកាត់បន្ថយចំណាយលើអាហារ និងទំនិញមិនមែនអាហារ ដោយសារចំណូលរបស់ គ្រួសារធ្លាក់ចុះជាខ្លាំង ក្នុងរយៈពេល ៦ខែកន្លងមកនេះ ។ បម្រែបម្រួលចំណាយប្រើប្រាស់លើម្ហូបអាហារ អាចមើលឃើញច្បាស់ ទាំងតាមចំនួនទឹកប្រាក់បានចំណាយ និង គុណភាព ឬប្រភេទអាហារដែលបានទិញ (ឧ. ការផ្លាស់ប្តូរពី ទិញសាច់ជ្រូក ឬត្រីធំៗ ទៅទិញកូនត្រីតូចៗវិញ) ។ ក្នុងគ្រួសារនៅតាមជនបទ និងគ្រួសាររបស់ពលករងាយរងគ្រោះ ការកាត់បន្ថយចំណាយប្រើប្រាស់នេះប៉ះពាល់ខ្លាំងជាងគេទៅលើឪពុកម្តាយ និង តិចជាងគេទៅលើកុមារតូចៗ ។

### *កំណើនបន្ទុកការងារ*

វិបត្តិសេដ្ឋកិច្ចសាកល បានពាល់ធ្ងន់ធ្ងរដល់ពលករងាយរងគ្រោះ និងគ្រួសារនៅជនបទ តាមរយៈការថយចុះចំនួនការងារ ប្រាក់ចំណូល ប្រាក់ផ្ញើមកផ្ទះ និងសន្តិសុខការងារ ។ អ្នកឆ្លើយសម្ភាសន៍ជាច្រើននាក់រាយការណ៍ថា ពួកគេត្រូវធ្វើការងារមិនរៀបរយថែមទៀត បន្ទាប់ពីចប់ម៉ោងការងារផ្លូវការ ដើម្បីរកប្រាក់ចំណូលបន្ថែម ឬត្រូវធ្វើការខ្លាំងជាងមុនទៀតដើម្បីជៀសវាងការបាត់បង់ការងារ ។ លើសពីនេះទៀត សមាជិកគ្រួសាររបស់ពួកគេក៏ត្រូវបង្កើនបន្ទុកការងារដែរ ហើយពេលខ្លះ ត្រូវបង្កើនចំនួនសមាជិកគ្រួសារដែលចូលរួមក្នុងការរកចំណូល ។ សមាជិកគ្រួសារគ្រប់គ្នា បានបង្កើនបន្ទុកការងាររបស់ខ្លួន ដូចជា ការដាំដំណាំតាមផ្ទះ ការស្វែងរកម្ហូបអាហារពីធនធានទ្រព្យរួម ឬការងារផ្សេងៗទៀតដែលអាចធ្វើទៅបាន ។

### *ចំណាកស្រុក ពលកម្មកុមារ និងវត្តមាននៅសាលា*

នៅមិនទាន់មានភស្តុតាងបញ្ជាក់ច្បាស់ទេ ចំពោះការសន្មត់ថា កម្មករដែលបាត់បង់ការងារនៅទីក្រុង កំពុងនាំគ្នាទាំងហ្វូងវិលត្រលប់ទៅធ្វើការងារកសិកម្មនៅតាមទីជនបទវិញ ។ ជាក់ស្តែង ការពិភាក្សាតាមក្រុមស្នូល និងបទសម្ភាសពាក់កណ្តាលរៀបរយជាមួយគ្រួសារនៅជនបទ បានបង្ហាញពីកំណើនចំនួន

---

៣ នៅត្រីមាសទី៤ ឆ្នាំ២០០៨ និង ត្រីមាសទី១ ឆ្នាំ២០០៩ ផលិតផលកសិកម្ម និងថាមពល បានធ្លាក់ថ្លៃខ្លាំង ប៉ុន្តែម្ហូបអាហារប្រចាំថ្ងៃមិនបានចុះថ្លៃទេ ទាំងនៅជនបទ និងទីក្រុង ។

អ្នកធ្វើចំណាកស្រុកទៅរកការងារនៅទីក្រុង បើទោះជាពួកគេដឹងថា ឱកាសរកបានការងារនៅទីក្រុង មានលក្ខណៈមិនប្រាកដប្រជាក៏ដោយ ។ រឿងនេះបង្ហាញថា ការងារធ្វើនៅជនបទ កាន់តែលំបាករកបានជាងនៅទីក្រុងទៅទៀត ។ ជាក់ស្តែង ក្នុងរយៈពេល ៦ខែមុននេះ ចំណាកស្រុកនៅភូមិកំពង់ត្នោតបានកើន ៣០-៤០% ហើយរំពឹងថា នឹងបន្តកើនឡើងនៅប៉ុន្មានខែខាងមុខ ។ ក្នុងករណីនេះ គេធ្វើចំណាកស្រុកទៅកាន់កំពង់សោម និងកោះកុង ដើម្បីរកចំណូលជួយផ្គត់ផ្គង់គ្រួសារ ។

ដើម្បីរស់រានបានក្នុងពេលដ៏លំបាកនេះ គ្រួសារងាយរងគ្រោះនៅជនបទបានអោយកូនៗដែលកំពុងរៀនសូត្រ ជួយធ្វើការនៅក្នុងភូមិដើម្បីរកប្រាក់ចំណូលបន្ថែម ហើយគ្រួសារខ្លះបានឱ្យកូនៗឈប់ទៅសាលារៀន ដើម្បីអោយពួកគេទៅរកការងារធ្វើនៅក្រៅភូមិ ។ ក្នុងរយៈពេល ៦ខែកន្លងមកនេះ មានកុមារក្នុងអាយុពី ១៣-១៨ឆ្នាំ កាន់តែច្រើននាក់បានបោះបង់ការសិក្សាទៅរកការងារធ្វើនៅតាមទីក្រុង (ក្រុងភ្នំពេញ កំពង់សោម កោះកុង ឬ កំពង់ចាម) ដោយធ្វើដូចជាអ្នកស៊ីឈ្នួលធ្វើការតាមផ្ទះ កម្មករកែច្នៃម្ហូបអាហារ កម្មករក្នុងចំការកសិកម្ម អ្នកបំរើតុភោជនីយដ្ឋាន ជាដើម ។ ការងារជាឧទាហរណ៍គួរកត់សម្គាល់មួយ គឺ ក្មេងស្រីជាច្រើនដែលធ្វើចំណាកស្រុកពីភូមិបាបោង ដូនវង្ស និង ប៉ៃលហែង បានទៅធ្វើការជាអ្នកស៊ីឈ្នួលតាមផ្ទះ ភាគច្រើននៅទីក្រុងភ្នំពេញ ហើយបានផ្ញើប្រាក់ទៅផ្ទះមួយចំនួន ។

### *ការខ្ចីបុល*

ក្រុមស្រាវជ្រាវរបស់ CDRI បានរកឃើញនូវកំណើនការខ្ចីប្រាក់សំរាប់ទិញអាហារ ដោយសារប្រាក់ចំណូលគ្រួសារ និងប្រាក់ផ្ញើពីកូនៗ បានធ្លាក់ចុះយ៉ាងខ្លាំង ។ មានគ្រួសារជាច្រើនបានធ្លាក់ខ្លួនយ៉ាងជ្រៅទៅក្នុងបំណុល ដោយសារការខ្ចីបុលពីអ្នករកស៊ីចងការប្រាក់ ឬអ្នកឱ្យខ្ចីស្រូវអង្ករ ក្នុងអត្រាការប្រាក់យ៉ាងខ្ពស់ដល់ ៥-៦% ក្នុង១ខែ ។ម្យ៉ាងវិញទៀត នៅតាមគ្រប់ភូមិ លទ្ធភាពរកបានកកម្ចីកាន់តែពិបាកឡើង ពីព្រោះអ្នកផ្តល់កម្ចី និងស្ថាប័នមីក្រូហិរញ្ញវត្ថុ បារម្ភថា ប្រជាជនមិនមានលទ្ធភាពសងបំណុលវិញ ។

## ៤. សន្និដ្ឋាន

គំរូតាងប្រើប្រាស់ក្នុងការវាយតម្លៃនេះ មានទំហំតូច ដូច្នេះគេពិបាកជាខ្លាំងនឹងធ្វើការសន្និដ្ឋានពី ផលប៉ះពាល់នៃ វិបត្តិសេដ្ឋកិច្ចសាកលទៅលើគ្រួសារជាទូទៅនៅកម្ពុជា ។ ទាក់ទងនឹងក្រុមគំរូតាងទាំងនេះ គេរកឃើញថា វិបត្តិសេដ្ឋកិច្ចសាកលមានផលប៉ះពាល់ធ្ងន់ធ្ងរ ទៅលើពលករងាយរងគ្រោះមិនថាក្នុងវិស័យសេដ្ឋកិច្ចរៀបរយ ឬមិនរៀបរយក្តី ។ ក្នុងរយៈពេល ១២ខែ និង ៦ខែ កន្លងមកនេះ ចំនួនការងារធ្លាក់ចុះអស់ ៣០-៤០% ហើយប្រាក់ចំណូលក្នុងគ្រួសារ និងប្រាក់ផ្ញើទៅផ្ទះ បានធ្លាក់ចុះអស់ជាង ៥០% ។

វិបត្តិសេដ្ឋកិច្ចសាកល ជាកត្តាមួយក្នុងចំណោមកត្តាជាច្រើនទៀត ដែលបង្កការធ្លាក់ចុះកំរិតជីវភាពគ្រួសារនៅជនបទ ។ កត្តាទាំងនេះមានជាអាទិ ទំនាស់ព្រំដែនជាមួយប្រទេសថៃ និងការធ្លាក់ថ្លៃផលិតផលកសិកម្មយ៉ាងគំហុក ដោយសារវិបត្តិហិរញ្ញវត្ថុសាកលដែលកើតមាននៅចុងឆ្នាំ២០០៨ បានធ្វើឱ្យធ្លាក់ចុះតំរូវការក្នុងពិភពលោក (Hossein 2009) ។ ការវាយតម្លៃរហ័សនេះបានបំពេញបន្ថែមលើការសិក្សាពីមុនៗ ដែលធ្វើឡើងដោយលោក Theng (2009 a, b) និងដែលបង្ហាញថា ការធ្លាក់ថ្លៃខ្លាំងនៃផលិតផលកសិកម្ម គឺជាកត្តាចំបងដែលរុញច្រានគ្រួសារនៅតាមជនបទ ឱ្យធ្លាក់ជ្រៅទៅក្នុងបំណុល និងភាពក្រីក្រ ក្នុងរយៈពេលពី ៦-១២ខែកន្លងទៅនេះ ។

គ្រួសារនានាបានប្រើយុទ្ធសាស្ត្រដោះស្រាយច្រើនបែបយ៉ាង ប៉ុន្តែចំនុចគួរឱ្យបារម្ភ គឺការប្រើកុមារក្នុងវ័យសិក្សា ឱ្យធ្វើការរកចំណូលនៅក្នុងភូមិ ។ កុមារទាំងនោះត្រូវខកខានទៅសាលាជាញឹកញាប់ នៅពេលត្រូវរកប្រាក់ចំណូល ហើយរឿងនេះបានប៉ះពាល់មិនល្អដល់ការសិក្សារបស់ពួកគេ ។ បញ្ហាអាក្រក់ជាងនេះទៀត គឺក្នុងអំឡុងពេល ៦ខែកន្លងមកនេះ មានកុមារជាច្រើន ត្រូវក្រុមគ្រួសារដកចេញពីសាលា ដើម្បីបញ្ជូនឱ្យទៅរកការធ្វើនៅក្រៅភូមិ ។ ជារឿយៗណាស់ ក្មេងស្រីៗត្រូវក្រុមគ្រួសារដកចេញពីសាលា ហើយបញ្ជូនទៅធ្វើជាអ្នកស៊ីឈ្នួលតាមផ្ទះ ឱ្យគ្រួសារអ្នកធូរធារ ដែលភាគច្រើននៅក្រុងភ្នំពេញ ។ ទង្វើបែបនេះនឹងជះឥទ្ធិពលមិនល្អដល់ជីវភាពរស់នៅរបស់ពួកកុមារនៅថ្ងៃអនាគត ។ ពួកគេមានកំរិតអប់រំទាប និងមិនមានជំនាញអ្វីសោះ សំរាប់ទៅរកការងារ ដែលផ្តល់ប្រាក់កំរៃសមរម្យ ហើយត្រូវជាប់ផុងក្នុងភាពក្រីក្រតកូនតចៅ ។ ការជួយសង្គ្រោះពួកគេឱ្យចាកផុតភាពក្រីក្រ គឺជាបញ្ហាប្រឈមមួយធំណាស់ ៕

## ឯកសារយោង

Jalilian Hossein, Chan Sophal, Glenda Reyes, Saing Chang Hang (2009), The Global Financial Crisis and Developing Countries: *Cambodia* (Phnom Penh: CDRI)

Jalilian Hossein (2009), Food Price Changes and Their Consequences for Vulnerable Groups: What Lessons Can Be Learned? *Annual Development Review* (Phnom Penh: CDRI)

Kang Chandararot, Sok Sina, Kim Sedara, Liv Dannet. (2009), Rapid Assessment on the Impact of the Financial Crisis in Cambodia (Phnom Penh: CIDS)

Theng Vuthy (2009a). "Food and Financial Crises—Impact on Agriculture and Policy Priorities for Pro-Poor Agricultural Growth", *Cambodia Development Review,* March (Phnom Penh: CDRI)

Theng Vuthy (March 2009b), Managing through the Crisis—Strengthening Key Sectors for Cambodia's Future Growth, Development and Poverty Reduction: Agriculture and Rural Development. *Cambodia Outlook Brief*, CDRI and ANZ Royal Bank

# ការគ្រប់គ្រងមិនផ្លូវការលើហានិភ័យ និងការអនុវត្តប្រព័ន្ធសុវត្ថិភាពសង្គម : បទពិសោធន៍សិក្សាពីគ្រួសារ និងពលករក្រីក្រ និងងាយរងគ្រោះ*

## ១. សេចក្តីផ្តើម

ការកាត់បន្ថយភាពក្រីក្រអាចធ្វើឡើងមួយផ្នែក តាមរយៈការបង្ការប្រជាជនមិនក្រីក្រ កុំឱ្យធ្លាក់ខ្លួនក្រីក្រ និងការលើកស្ទួយអ្នកក្រីក្រ ឱ្យចាកផុតពីភាពក្រីក្រ ។ កំណើនសេដ្ឋកិច្ច ជាកត្តាដ៏សំខាន់សំរាប់លើកស្ទួយប្រជាជនឱ្យចាកផុតពីភាពក្រីក្រ ប៉ុន្តែត្រូវមានគោលនយោបាយជាច្រើនទៀតដើម្បីធានាថា ទី១-អត្ថប្រយោជន៍ទទួលបានពីកំណើន ត្រូវចែករំលែកឱ្យបានធំទូលាយ (ជាពិសេស បានទៅដល់ប្រជាជនក្រីក្រ) និង ទី២-កុំឱ្យប្រជាជនមិនក្រីក្រ គេធ្លាក់ចុះទៅក្រោមបន្ទាត់ក្រីក្រ ។ ប្រព័ន្ធសុវត្ថិភាពសង្គម អាចជួយដោះស្រាយការព្រួយបារម្ភទាំងពីរនេះបាន ។ វាក៏ជួយឱ្យគ្រួសារក្រីក្រ និងគ្រួសារជិតក្រីក្រ អាចចូលរួមក្នុងដំណើរការរីកលូតលាស់ ដើម្បីឱ្យពួកគេតាមទាន់គ្រួសារនៅជិតខាងដែលធូរធារជាង ។ សង្គមជាតិក៏ទទួលបានអត្ថប្រយោជន៍ដែរ ដោយសារប្រជាជនក្រីក្រដែលមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធសុវត្ថិភាពសង្គម អាចចូលរួមចំណែកក្នុង ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចបានល្អប្រសើរជាង ទាំងតាមរយៈការបង្កើនផលិតភាព និងចំរុះកម្មផលិតកម្ម ហើយនិង ការបង្កើនតំរូវការ និងការប្រើប្រាស់ ។

ហានិភ័យមានជាប់ជានិច្ចក្នុងជីវភាពប្រចាំថ្ងៃនៅប្រទេសកម្ពុជា ។ ក្នុងករណីជាច្រើន ប្រជាជនបានធ្លាក់ចូល និងចាកផុតពីភាពក្រីក្រច្រើនដងចុះឡើងក្នុងឆាកជីវិតរបស់ខ្លួនដោយសារការប៉ះទង្គិច និងវដ្តនៃជីវិត (អាពាហ៍ពិពាហ៍កសាងផ្ទះសម្បែង មានកូនចៅចូលវ័យចំណាស់ មរណភាពក្នុងគ្រួសារ) ។ កំណើនសេដ្ឋកិច្ចនាពេលថ្មីៗ ជំនួយអភិវឌ្ឍន៍ និងអន្តរគមន៍ផ្សេងៗ បានជួយលើកកំពស់កំរិតជីវភាព ប៉ុន្តែសមត្ថភាពរបស់ជនក្រីក្រ ដើម្បីដោះស្រាយវិបត្តិមើលមិនឃើញក្នុងឆាកជីវិត ត្រូវតែកែលំអឡើងទៀត។

នៅប្រទេសកម្ពុជាមានកម្មវិធីគាំពារសង្គមជាផ្លូវការមួយចំនួន សំរាប់ជួយដល់ជនក្រីក្រ ស្ត្រី មនុស្សចាស់ និងជនងាយរងគ្រោះនៅតំបន់ជនបទ ដូចជា មូលនិធិសមធម៌ កម្មវិធីផ្តល់អាហារនៅសាលារៀន ការចាក់ថ្នាំបង្ការដល់មាតា និងទារក និង/ឬ កម្មវិធីផ្តល់អាហាររូបត្ថម្ភ ប្រាក់សោធននិវត្តន៍សំរាប់មន្ត្រីរាជការ និងក្រុមជួយខ្លួនឯងដែលបង្កើតឡើង ដោយអង្គការមិនមែនរដ្ឋាភិបាល (NGOs) (ធនាគារស្រូវ និងគ្រោងការសន្សំប្រាក់) ។ ប៉ុន្តែកម្មវិធីទាំងនេះ ហាក់ដូចមិនទាន់រឹងមាំគ្រប់គ្រាន់អាចប្រើជា ប្រព័ន្ធសុវត្ថិភាពសំរាប់ជនក្រីក្រនៅឡើយទេ ។ គ្រោងការណ៍នានាបានដាក់អនុវត្តន៍តាមបែប "អាវបំពាក់" ដោយគ្របដណ្តប់ជនងាយរងគ្រោះ ឬតំបន់ភូមិសាស្ត្រមួយចំនួន ជួនកាលជាន់គ្នា ជួនកាលរំលងចោលខ្លះ គ្រោងការខ្លះមានប្រសិទ្ធភាពជាងគ្រោងការខ្លះទៀត ហើយប្រព័ន្ធកំណត់មុខសញ្ញាត្រូវជួយក៏មានច្រើន និងប្រទាំងប្រទើសគ្នាជារឿយៗ ។

បច្ចុប្បន្នមានការជជែកវែកញែកកាន់តែច្រើននៅកម្ពុជា ស្តីពីផ្លែផ្កានៃការអភិវឌ្ឍសំរាប់ជនក្រីក្រ និងការគិតគូរបែបថ្មីក្នុងមជ្ឈដ្ឋានខាងគោលនយោបាយ ដើម្បីកសាងកម្មវិធី និងគោលនយោបាយប្រព័ន្ធសុវត្ថិភាពមួយថ្មីនៅកម្ពុជា ។ ការវាយតំលៃនេះបានធ្វើឡើងទាន់ពេលល្អ ដោយបានផ្តល់ជាគំនិត ដល់អ្នកកសាងគោលនយោបាយ និងអ្នកអនុវត្តការងារអភិវឌ្ឍន៍អំពីវិធីសាស្ត្រដែលជនក្រីក្រកំពុងប្រើ ដើម្បីដោះស្រាយហានិភ័យ ក្នុងពេលដែលប្រព័ន្ធសុវត្ថិភាពជាផ្លូវការរបស់រដ្ឋាភិបាលនៅខ្វះខាតជាទូទៅនៅឡើយ ។ គេសង្ឃឹមថា ការយល់ដឹងកាន់តែប្រសើរពី ប្រព័ន្ធសុវត្ថិភាពសង្គមក្រៅផ្លូវការដែលមានស្រាប់ អាចបានជាជំនួយដល់ការរចនារៀបចំប្រព័ន្ធសុវត្ថិភាពរបស់រដ្ឋាភិបាល ឱ្យកាន់តែមានប្រសិទ្ធភាព និងមិនប្រទាំងប្រទើសគ្នាជាមួយរបៀបរបបអនុវត្តក្រៅផ្លូវការ នៅពេលជួយបំពេញបន្ថែមចំនុចខ្វះខាតផ្សេងៗដែលរបៀបរបបក្រៅផ្លូវការមិនអាចដោះស្រាយបាន ។

## ២. វិធីសាស្ត្រ

ការវាយតំលៃនេះ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានរៀបចំឡើងជាផ្នែកមួយនៃ ការវាយតំលៃរហ័សទ្រង់ទ្រាយធំជាង អំពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច មកលើគ្រួសារនៅកម្ពុជា ដែលធនាគារពិភពលោកបានចុះកិច្ចសន្យាឱ្យអនុវត្តនៅខែឧសភា ២០០៩ ។ ការវាយតំលៃបានពិនិត្យឡើងវិញ ជាពិសេសពីរបៀបរបបក្រៅផ្លូវការដែលមានស្រាប់ និងដែលពលករ និងគ្រួសារក្រីក្រ និងងាយរងគ្រោះនៅកម្ពុជា អាចប្រើបានសំរាប់គ្រប់គ្រងហានិភ័យ និងជួយគ្នាទៅវិញទៅមក ។ ការវាយតំលៃនេះ បានស្រាវជ្រាវលើសំនួរមួយចំនួនដូចខាងក្រោម:

- តើបច្ចុប្បន្នមានប្រព័ន្ធសុវត្ថិភាពក្រៅផ្លូវការអ្វីខ្លះ? តើប្រជាជនទៅពឹងពាក់នរណា នៅពេលជួបកង្វះខាតប្រាក់ចំណូល ឬចំណាយប្រើប្រាស់? តើគ្រួសារខុសៗគ្នាមានប្រភពជំនួយគាំទ្រខុសៗគ្នា ឬយ៉ាងណា?
- តើរបៀបរបបអនុវត្តទាំងនេះមានផ្លាស់ប្តូរឬទេក្នុងអំឡុង ១៨ខែកន្លងទៅ? ប្រសិនបើមានផ្លាស់ប្តូរ តើផ្លាស់ប្តូរបែបណា?
- តើសព្វថ្ងៃនេះ សាមគ្គីភាពសង្គមរឹងប៉ឹងប៉ុណ្ណា? តើប្រជាជនអាចរកបានជំនួយគាំទ្របែបណាខ្លះ?
- តើកិច្ចប្រឹងប្រែងសម្បុរសធម៌ជាលក្ខណៈឯកជន មានច្រើនទូទៅប៉ុណ្ណា?
- តើកិច្ចខិតខំប្រឹងប្រែងសប្បុរសធម៌ជំរុញដោយ NGOs បានជួយពង្រឹង ឬប៉ះពាល់ដល់ ប្រព័ន្ធសុវត្ថិភាពក្រៅផ្លូវការជាប្រពៃណី ឬទេ?
- តើមានអន្តរកម្មអ្វីខ្លះ រវាងប្រព័ន្ធសុវត្ថិភាពក្រៅផ្លូវការ និងអាជ្ញាធរភូមិឃុំ/សង្កាត់?
- តើប្រជាជនប្រើប្រាស់វិធីដោះស្រាយអ្វីខ្លះ នៅពេលជួបនឹងវិបត្តិសេដ្ឋកិច្ច?

ក្រុមស្រាវជ្រាវបានធ្វើសម្ភាសន៍ពាក់កណ្តាលរៀបរយ (SSI) ជាមួយជនក្រីក្រនៅជនបទ និងពលករងាយរងគ្រោះ ចំនួន ៤៧នាក់ និងមេភូមិ

---

* សូ សុវណ្ណារិទ្ធិ អ្នកស្រាវជ្រាវនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ។ របាយការណ៍នេះ ផ្តល់លទ្ធផលសង្ខេបសំខាន់ៗពីការវាយតំលៃរហ័ស លើប្រព័ន្ធសុវត្ថិភាពសង្គមក្រៅផ្លូវការដែលធ្វើឡើងនៅខែឧសភា ២០០៩ ។ ឯកសារពេញលេញលើអត្ថបទនេះ ដែលមានចំណងជើងថា "ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចលើជីវភាពគ្រួសារនៅកម្ពុជា និងការអនុវត្តប្រព័ន្ធសុវត្ថិភាពសង្គមសំរាប់ជនក្រីក្រ" នឹងមានចុះក្នុងវេបសាយរបស់ CDRI ក្នុងពេលដ៏ខ្លី ។

៩នាក់ ដើម្បីស្រាវជ្រាវស៊ីជំរៅពីបទពិសោធន៍ ដែលពួកគេបានឆ្លងកាត់ក្នុងអំឡុង ១២ខែ និង ៦ខែ មុនពេលមានការប្រមូលទិន្នន័យនៅខែឧសភា ២០០៩ ។ អ្នកឆ្លើយសម្ភាសន៍ពីរនាក់ត្រូវបានជ្រើសរើសដោយមានគោលដៅចេញពីគ្រួសារដែលវិទ្យាស្ថាន CDRI បានធ្វើសម្ភាសន៍ក្នុងពេលធ្វើការសិក្សាពីឌីណាមិកភាពក្រីក្រ (PDS) ក្នុងឆ្នាំ២០០៨ (អង្កេតធ្វើបន្តពីអង្កេតគ្រួសារដែលបានធ្វើឡើងក្នុងភូមិ ចំនួន៩ កាលពីឆ្នាំ២០០៤-២០០៥)[១] និងចេញពីកន្លែងនានា ដែលបានធ្វើអង្កេតពលករងាយរងគ្រោះ កាលពីដើមឆ្នាំ ២០០៩[២] ។ លទ្ធផលដែលបានស្រាវជ្រាវឃើញ វាឆ្លុះបញ្ចាំងតែពីបទពិសោធន៍នៃក្រុមគំរូតាងប៉ុណ្ណោះ ដូច្នេះគួរប្រុងប្រយ័ត្ន នៅពេលយកទិន្នន័យទាំងនេះទៅប្រើលើក្រុមផ្សេងៗទៀត ។

## ៣. លទ្ធផលរកឃើញសំខាន់ៗ

### ៣.១. ហានិភ័យ និងលទ្ធផលចំពោះជីវភាពរបស់ជនក្រីក្រ

សំរាប់ការងារនេះ ហានិភ័យអាចកំណត់ថាជា ការប៉ះទង្គិចខាងសេដ្ឋកិច្ច និងសង្គមកិច្ច ដែលជារឿយៗនាំឱ្យមានការធ្លាក់ចុះសុខុមាលភាព ឬកំណើនអសន្តិសុខនៃជីវភាព (Devereux, 2001) ។ ទស្សនាទាននៃហានិភ័យ និងការប៉ះទង្គិច ឬការគំរាមកំហែងលើប្រាក់ចំណូល កន្លងមកគេបានប្រើវាជំនួសគ្នាចុះឡើងជារឿយៗ (ធនាគារពិភពលោក ២០០៦) ។ ហានិភ័យ រឺការប៉ះទង្គិច កើតចេញពីការផ្លាស់ប្តូរទាំងខាងក្នុង និងខាងក្រៅ ដែលប្រជាជនពិបាកនឹងសម្របខ្លួនតាម ដោយជារឿយៗវាបានប៉ះពាល់មិនល្អដល់ជីវភាពរស់នៅ ហើយប្រជាជនក្រីក្រអាចចំណាយពេលយូរ ដើម្បីស្តារជីវភាពមកវិញ (ibid) ។

ហានិភ័យអាចមានជាហូរហែតាំងពី "ករណីដោយឡែក (idiosyncratic)" ពោលគឺ វាប៉ះពាល់ដល់បុគ្គល ឬគ្រួសារខ្លះ ប៉ុន្តែមិនប៉ះដល់អ្នកឯទៀតទេ និង "ករណីបែបសំបូរ (covariant)" ពោលគឺ ប៉ះពាល់ដល់ប្រជាជនជាច្រើនក្នុងពេលជាមួយគ្នា ។ ករណីដោយឡែកដែលឧស្សាហ៍ជួប មានជាអាទិ គ្រោះថ្នាក់ ឬជំងឺមិនធ្ងន់, ការប៉ះទង្គិចដល់ប្រាក់ចំណូល ដោយសារភាពអត់ការងារធ្វើ ឬការថយចុះប្រាក់ចំណូលរកបាន, មរណៈភាពនៃសមាជិកគ្រួសារ នាំឱ្យមានចំណាយធ្វើបុណ្យសព និងការថយចុះកំលាំងពលកម្ម, ការបែកបាក់គ្រួសារ, ការខូចខាតផលដំណាំ ឬការរកស៊ីខាត ជាដើម ។ ឧទាហរណ៍នៃហានិភ័យបែបសំបូរ មានដូចជា គ្រោះធម្មជាតិក្នុងសហគមន៍ ឬតំបន់ (ឧ. ទឹកជំនន់ ឬគ្រោះរាំងស្ងួត) សង្គ្រាម, ជំលោះស៊ីវិល ឬអំពើហិង្សារបស់ក្រុមជនពាលជំងឺឆ្លងរាលដាល (ក្នុងមូលដ្ឋាន ឬគ្រប់កន្លែង) ឬវិបត្តិសេដ្ឋកិច្ចក្នុងប្រទេស ឬក្នុងតំបន់ (អតិផរណា សេដ្ឋកិច្ចរួមចុះ ការធ្លាក់ចុះប្រាក់ចំណូល និងភាពអត់ការងារធ្វើ) ។

ភូមិធូរធារនិងរីកលូតលាស់លឿន និង គ្រួសារធូរធារនៅក្នុងភូមិក្រីក្រ ហាក់ដូចមានសមត្ថភាពខ្ពស់ជាង ដើម្បីទប់ទល់នឹងការប៉ះទង្គិចផ្សេងៗ (Fitzgerald and So, 2007) ។ ជនក្រីក្រ និងក្រុមងាយរងគ្រោះឯទៀត ដូចជា ជនចាស់ជរា និងជនពិការ ជាដើម តែងងាយរងគ្រោះថ្នាក់ ពីព្រោះពួកគេមានប្រាក់ចំណូលសរុបតិចតួច មានប្រាក់សន្សំតិច មានទ្រព្យរបស់តិច និងមានធនធានមនុស្សតិច (Devereux, 2001) ដូច្នេះហើយគ្រោះថ្នាក់ផ្សេងៗ មានផលប៉ះពាល់លឿនជាង និងធ្ងន់ធ្ងរជាងទៅលើសុខុមាលភាពផ្លូវកាយ និងផ្លូវចិត្ត និងការរីកលូតលាស់របស់មនុស្សក្នុងរយៈពេលវែង ។ ដោយឡែកស្ត្រី និងកុមារ ច្រើនរងគ្រោះខ្លាំងជាងគេ នៅពេលក្រុមគ្រួសារជួបការលំបាក ។ សំរាប់ជនក្រីក្រ ការបាត់បង់ប្រាក់ចំណូលធ្វើឱ្យពួកគេត្រូវបង្ខំចិត្តលក់ដីធ្លី សត្វចិញ្ចឹម ឬទ្រព្យផលិតកម្មផ្សេងទៀត, បញ្ជូនកូនអោយទៅធ្វើការរកប្រាក់ជាជាងឱ្យកូនទៅសាលារៀន ឬបរិភោគអាហារតិច (CDRI, 2008) ។ វិធានការតឹងរឹងបែបនេះ អាចជួយគ្រួសារនានាឱ្យរស់រានបានពីមួយថ្ងៃទៅមួយថ្ងៃ ប៉ុន្តែធ្វើអោយគ្រួសារពិបាកចាកផុតពីភាពក្រីក្រនៅថ្ងៃអនាគត (Fitzgerald and So, 2007) ។ វាក៏អាចជាកត្តានាំឱ្យមានទំនាក់ទំនងអន់ខ្សោយខាងពលកម្ម និងអស្ថិរភាពសង្គមផងដែរ (Ballard et al., 2007) ។

ប្រជាជនក្រីក្រ និងងាយរងគ្រោះដែលមានទ្រព្យសម្បត្តិ ឬប្រាក់សន្សំតិចតួច តែងស្វែងរកជំនួយ (អង្ករ ឬប្រាក់កាស) ពីសាច់ញាតិ មិត្តភក្តិ ឬអ្នកជិតខាងដែលមានជីវភាពធូរធារ នៅពេលជួបការខ្វះខាត ឬក៏ទៅបេះប្រមូលផលដែលអាចហូប/លក់បាន ពីព្រៃឈើ បឹងបួរ និង ដីរួម ឬក៏ខ្ចីបុលពីអ្នកដទៃ ។ ទំលាប់អនុវត្តន៍បែបនេះដែលអាចចាត់ទុកជា ប្រព័ន្ធក្រៅផ្លូវការសំរាប់គ្រប់គ្រង និងចែករំលែកហានិភ័យ ជាប្រព័ន្ធសុវត្ថិភាពក្រៅផ្លូវការសំរាប់ប្រជាជនក្រីក្រ ហើយវាបានដំណើរការនៅក្នុងសង្គមកម្ពុជាជាច្រើនជំនាន់មកហើយ ។[៣] វាបានផ្លាស់ប្តូររូបភាពទៅតាមពេលវេលា ប៉ុន្តែនៅតែមានអនុវត្តជាទូទៅនៅក្នុង ក្រុមគ្រួសារធំទូលាយ ក្នុងចំណោមមិត្តភក្តិ និងក្នុងបណ្តាញសង្គម ។ សេដ្ឋកិច្ចប្រាក់កាសសព្វថ្ងៃ កំពុងធ្វើឱ្យខូចខាតដល់ប្រព័ន្ធសុវត្ថិភាពក្រៅផ្លូវការនេះហើយ ដោយសារកំណើនវិសមភាព និងបរាជ័យនៃអន្តរាគមន៍ជួយអភិវឌ្ឍមួយចំនួន (Devereux, 2001) ។[៤]

### ៣.២. ហានិភ័យ និងផលប៉ះពាល់ដល់ជនក្រីក្រ និងងាយរងគ្រោះ

សំរាប់ពួកអ្នកឆ្លើយសម្ភាសន៍ ការប៉ះទង្គិចភាគច្រើនមិនមែនជារឿងថ្មី ឬបណ្តាលមកពីនិន្នាការសេដ្ឋកិច្ចមិនល្អនាពេលថ្មីៗនេះទេ ។ ការប៉ះទង្គិចភាគ

---

១ ភូមិសិក្សាក្នុង PDS រួមមាន អណ្តូងត្រាច និង ក្រសាំង (បាត់ដំបង) ខ្សាច់ជីរស់ និង ដងក្ដារ (កំពង់ធំ) កញ្ជរ (ក្រចេះ) ព្រែកក្មេង (កណ្តាល) បាបោង (ព្រៃវែង) ត្រពាំងព្រៃ (កំពង់ស្ពឺ) និង កំពង់ត្នោត (កំពត) ។ មេភូមិនៃភូមិនិមួយៗក៏បានឆ្លើយសម្ភាសន៍ប្រាប់ពីការសង្កេតឃើញរបស់គាត់ លើការផ្លាស់ប្តូរសេដ្ឋកិច្ច និងការអនុវត្តប្រព័ន្ធសុវត្ថិភាពក្នុងអំឡុងពេល ១២ឆ្នាំកន្លងមក ។

២ បទសម្ភាសន៍ជាមួយពលករងាយរងគ្រោះ បានធ្វើឡើងប្រចាំត្រីមាសជាមួយៈ អ្នកធាក់ស៊ីក្លូ អ្នករត់ម៉ូតូឌុប អ្នកលក់បន្លែតូចតាច អ្នកលីសែង អ្នករើសអេតចាយ កម្មករសំណង់មានជំនាញ និងគ្មានជំនាញ កម្មកររោងចក្រកាត់ដេរនៅក្រុងភ្នំពេញ និងអ្នកស៊ីឈ្នួលធ្វើស្រែនៅភូមិដូនវង្សខេត្តកណ្តាល និងភូមិ ប៉ៃលហែល ខេត្តកំពង់ស្ពឺ ។ សំរាប់ការវាយតំលៃនេះ បានជ្រើសរើសដោយមានគោលដៅ មកធ្វើសម្ភាសន៍ផងដែរ នូវអ្នកបំរើតុភោជនីយដ្ឋាន ចំនួន ២នាក់ ព្រមទាំងបុគ្គលិកសណ្ឋាគារ និងអ្នករត់ម៉ូតូទុកទុក/អ្នកលក់ដូរតូចតាច នៅឯខេត្តសៀមរាប ។

៣ ព័ត៌មានអំពីការជួយគ្នាទៅវិញទៅមកនៅក្នុងប្រទេសកម្ពុជា មានបកស្រាយក្នុងឯកសាររបស់ Murshid (1998) និង McAndrew (1998)

**ប្រអប់១: ការលែងលះ និងការចែកផ្លូវគ្នា ជាមូលហេតុចំបងនៃភាពក្រីក្រសំរាប់ស្ត្រី និងកុមារ**

អ្នកស្រី មាស សំបូរ អាយុ ៤៣ឆ្នាំ ជាអ្នកស៊ីឈ្នួលធ្វើស្រែ និងជាមេគ្រួសារមានកូន ៤នាក់ នៅភូមិប៉ៃលហេល បានលែងលះគ្នាជិត ៦ឆ្នាំមកហើយ ។ គាត់ធ្លាប់មានជីវភាពធូរធារ ប៉ុន្តែបានធ្លាក់ខ្លួនក្របន្ទាប់ពីប្តីបានចាកចោលគាត់ទៅ យកប្រពន្ធមួយទៀតនៅភូមិផ្សេង ។ ដោយសារខ្វះខាតកំលាំងពលកម្ម និងសត្វអូសទាញ និងមានកូន ៤នាក់ ក្នុងបន្ទុក ( ស្រី ៣នាក់, ប្រុស ១នាក់) ដែលត្រូវចិញ្ចឹមបីបាច់ថែរក្សាផង គាត់បានសំរេចចិត្តលក់ដីស្រែទំហំ ១ហិកតា ក្នុងតំលៃ ៣០០០ដុល្លារ ។ គាត់ចង់យកប្រាក់នេះ ទៅសងបំណុលដែលកើតចេញពី ទំនាស់យ៉ាងយូរជាមួយប្តីនៅមុនពេលលែងលះគ្នា និងចំណូលរកបានតិចតួចពីការធ្វើស្រែ និងទុកខ្លះសំរាប់ទិញម្ហូបអាហារចិញ្ចឹមកូន ។ ដូច្នេះ គាត់ក៏ក្លាយជាអ្នកគ្មានដីធ្លី ហើយពឹងផ្អែក លើការលក់កំលាំងពលកម្មដកស្ទូង និងច្រូតកាត់ស្រូវ ដោយអាចរកប្រាក់បានពី ៨០០០-១០.០០០រៀលក្នុងមួយថ្ងៃ ។ ប្រាក់ចំណូលរបស់គាត់ក្នុងរយៈពេល ៦ខែមុន បានធ្លាក់ចុះអស់ប្រហែលពាក់កណ្តាល ដោយសារកូនប្រុសស្រីរបស់កសិករ ជាច្រើន បានត្រលប់មកជួយធ្វើស្រែឪពុកម្តាយវិញ បន្ទាប់ពីពួកគេបាត់បង់ការងារនៅភ្នំពេញ ។

ក្នុងរយៈពេល ៧ខែកន្លងមក គាត់បានទទួលជំនួយខ្លះពីអ្នកជិតខាង និងកាកបាទក្រហមកម្ពុជា ។ អ្នកជិតខាងធូរធារម្នាក់ បានអនុញ្ញាតឱ្យគាត់ប្រើប្រាស់ដោយឥតគិតថ្លៃនូវដីមួយក្បាលតូចរបស់គេ ដើម្បីដាំបន្លែសំរាប់ហូប និងលក់យកប្រាក់ខ្លះ ។ ជារឿយៗគាត់ក៏ទទួលបានចំណីអាហារ និងលុយខ្លះដែរ នៅពេលទៅជួយអ្នកជិតខាងរៀបចំពិធីមង្គលការ និងបុណ្យទានផ្សេងៗ ។ នៅពេលមានខ្យល់ព្យុះបំផ្លាញផ្ទះគាត់កាលពីខែមករា ២០០៩ លោកមេភូមិបានអនុញ្ញាតឱ្យរូបគាត់ និងកូនៗ ទៅស្នាក់នៅក្រោមផ្ទះរបស់លោកមេភូមិ ចំនួន ២ខែ នៅពេលកំពុងសាងសង់ផ្ទះឡើងវិញ ។ កាលណោះ ខ្យល់ព្យុះក៏បានបំផ្លាញផ្ទះអស់ជាច្រើនទៀតដែរ ហើយមេភូមិបានរាយការណ៍ពីគ្រោះថ្នាក់នេះតាមទូរទស្សន៍ប៉ុស្តិ៍លេខ ១១ និង កាកបាទក្រហមកម្ពុជា ។ កូនស្រីពីរនាក់មានអាយុ ៨ឆ្នាំ និង ១០ឆ្នាំ និង កូនប្រុសម្នាក់អាយុ ៧ឆ្នាំ មិនអាចទៅរៀនបានអស់ពីរ-បីសប្តាហ៍ ប៉ុន្តែបានទៅរៀនវិញហើយ បន្ទាប់ពីបានទទួលកញ្ចប់ជំនួយពីកាកបាទក្រហមកម្ពុជា ( អង្ករ ២៥គីឡូក្រាម, ប្រាក់ ៥០.០០០រៀល, ក្រមារ ២, សារុង ២, តង់ប្លាស្ទិក ១, សាប៊ូលាងចាន ១ដប និង ម្សៅសាប៊ូ ១កញ្ចប់) កាលពីខែកុម្ភៈ ២០០៩ ។ មុនពេលទទួលបានជំនួយពីកាកបាទក្រហមកម្ពុជា គាត់ទទួលបានអង្ករ ៥០គីឡូក្រាម តាមរយៈការរៃអង្គាសក្នុងភូមិ ។ ជំនួយទាំងនេះ បានជួយឱ្យគាត់ និងកូនៗ អាចរស់រានបាន ២-៣ខែដែរ ប៉ុន្តែស្ថានភាពគាត់នៅតែលំបាកខ្លាំង ពីព្រោះពុំមានការងារធ្វើទៀត នៅក្នុងភូមិប៉ៃលហេល និងភូមិជិតខាង។ កូនស្រីគាត់អាយុ ១៣ឆ្នាំ បានបោះបង់ការសិក្សាអស់ ៣ឆ្នាំមកហើយ ហើយបានចូលធ្វើការក្នុងក្រុមកម្មករសំណង់ចល័តមួយ កាលពីមួយខែមុនពេលប្រមូលទិន្នន័យនេះ ។

ច្រើនជាករណីដោយឡែកដូចជា : ជំងឺ/មរណភាពរបស់សមាជិកគ្រួសារ, ការខូចខាតផលដំណាំ ឬការស្លាប់សត្វចិញ្ចឹម, ការលែងលះ ឬចែកផ្លូវគ្នា ។ ទោះជាយ៉ាងនេះក្តី វិបត្តិសេដ្ឋកិច្ចបានធ្វើឱ្យមានការប៉ះទង្គិចកាន់តែធ្ងន់ធ្ងរឡើង ដោយសារឱកាសរកចំណូលបានថយចុះ ហើយភាពងាយរងគ្រោះបានកើនឡើង ។ ករណី អ្នកស្រី មាស សំបូរ បានបង្ហាញពីបទពិសោធន៍ជាទូទៅនៃស្ត្រីមេម៉ាយដែលត្រូវរងទុកលំបាក ក្រោយពេលបានបាត់បង់ អ្នករកចំណូលចំបងគេនៅក្នុងគ្រួសារ ។ ស្ត្រីមេម៉ាយជួបការពិបាកច្រើន ក្នុងការរកចំណូលឱ្យបានគ្រប់គ្រាន់សំរាប់ដោះស្រាយអាហារក្នុងអំឡុងពេល ៦ខែ និង ១២ខែមុន ។ ពួកគេផ្ញើក្តីសង្ឃឹមច្រើនណាស់លើកូនៗ ហើយស្ត្រីមេម៉ាយដែលពុំមានកូនធំៗពេញវ័យ កាន់តែងាយរងគ្រោះថែមទៀត ។

ការពុំមានប្រព័ន្ធសុវត្ថិភាពសង្គមផ្លូវការ ធ្វើឱ្យប្រជាជនក្រីក្រភាគច្រើន ជាពិសេសគ្រួសារមានស្ត្រីគ្មានប្តីជាមេគ្រួ មនុស្សចាស់ជរា ជនពិការ ស្ត្រី និងកុមារ បានធ្លាក់កាន់តែជ្រៅក្នុងភាពក្រីក្រ ដោយសារផលប៉ះពាល់ថ្មីៗនៃហានិភ័យបែបសំបូរ ដូចជា ការធ្លាក់ចុះឱកាសការងារ និងប្រាក់ចំណូលផុសចេញពីការឡើងថ្លៃម្ហូបអាហារយ៉ាងខ្ពស់ ក្នុងអំឡុងខែមករា និង តុលា ឆ្នាំ២០០៨ និងវិបត្តិសេដ្ឋកិច្ចសកលដែលផ្ទុះឡើង ជាបន្តមកទៀត ។ អ្នកដែលមិនមានក្រុមគ្រួសារជិតស្និទ្ធគ្នា កាន់តែងាយរងគ្រោះឡើង ពីព្រោះពុំមានមធ្យោបាយរកបានជំនួយគាំទ្រនៅក្នុងសហគមន៍ នៅពេលជួបបញ្ហាលំបាកទ្រង់ទ្រាយធំ ។ អ្នកមានបញ្ហាចោទច្រើនជាងគេ ដូចជា មេគ្រួសារជាស្ត្រីដែលមានកូន ឬសមាជិកគ្រួសារមិនទាន់ធំពេញវ័យ គឺកាន់តែងាយធ្លាក់ចូលកាន់តែជ្រៅទៅក្នុងភាពក្រីក្រ ។

ការប៉ះទង្គិចទៅលើកុមារ វាហុចផលភ្លាមៗ និងធ្ងន់ធ្ងរ ។ ដើម្បីមានប្រាក់គ្រប់គ្រាន់សំរាប់ចាយវាយប្រចាំថ្ងៃ និងសងបំណុល គ្រួសារក្រីក្រជាច្រើន បានដកកូនចៅពីសាលារៀន ដើម្បីឱ្យទៅធ្វើការទោះជានៅវ័យក្មេងៗក៏ដោយ ។ ការវាយតំលៃនេះបានបង្ហាញថា កុមារក្រីក្រជាច្រើន ( ភាគច្រើនកុមារី) ត្រូវបានបង្ខំឱ្យឈប់រៀនដើម្បីជួយឪពុកម្តាយរកលុយ ។ វិធានការដ៏តឹងតែងបែបនេះ អាចជួយគ្រួសារក្រីក្រឱ្យរស់រានបាន ប៉ុន្តែវាហុចផលមិនល្អទេក្នុងរយៈពេលវែង ចំពោះធនធានមនុស្សក្នុងគ្រួសារ និងសមត្ថភាពរកចំណូលឱ្យបានច្រើនថែមទៀត ។ម្យ៉ាងទៀត គ្រួសារនៅតែមានស្ថានភាពផុយស្រួយ ដើម្បីទប់ទល់នឹងការប៉ះទង្គិចនៅថ្ងៃអនាគត ។ បញ្ហានេះមិនមែនថ្មីៗទេ ប៉ុន្តែនៅតែជាចំណុចព្រួយបារម្ភធ្ងន់ធ្ងរ ដែលត្រូវមានការធ្វើអន្តរាគមន៍យ៉ាងសមស្រប ។

ប្រជាជនក្រីក្រភាគច្រើនដែលរងការប៉ះទង្គិចខាងសេដ្ឋកិច្ច ឬសង្គមកិច្ចបែបណាមួយ បានធ្លាក់ខ្លួនជំពាក់បំណុលគេកាន់តែធ្ងន់ធ្ងរឡើង ។ ស្ថានភាពនេះអាចមើលឃើញតាម ការលក់ដោះទ័លនូវទ្រព្យផលិតកម្ម និងកំណើនភាពគ្មានដីធ្លី និងគ្មានលំនៅដ្ឋាន សំរាប់អ្នកដែលមិនអាចសងបំណុលបាន ។ និន្នាការនេះទំនងកើតមានបន្តទៀត ប្រសិនបើឱកាសមានការងារធ្វើនៅតែមិនទៀងទាត់ទៀត ក្នុងរយៈពេល ៦ខែ ឬ ១២ខែ ខាងមុខនេះ ។

### ៣.៣ ការគ្រប់គ្រងហានិភ័យ និងការអនុវត្តប្រព័ន្ធសុវត្ថិភាពក្រៅផ្លូវការ

ការវាយតំលៃនេះ បានគាំទ្រដល់ការសន្និដ្ឋានថា ការជួយគ្នាទៅវិញទៅមកជាប្រពៃណីក្នុងទំរង់ជាការផ្តល់ម្ហូបអាហារ និងកំចីគ្មានការប្រាក់ ក្នុងចំណោមសាច់ញាតិ ក្រុមគ្រួសារធំ និងខ្សែរយៈក្រៅផ្លូវការក្នុងក្រុមមានអាជីពដូចគ្នា នៅតែមានជារូបរាងក្នុងពេលចាំបាច់ ។ រឿងនេះក៏មានការគាំទ្រពីការសិក្សា

ជាច្រើនទៀត ដូចមានសង្ខេបក្នុងតារាង១ ។ ប៉ុន្តែ ដោយសារសេដ្ឋកិច្ចប្រើប្រាក់កាស របៀបរបបបែបប្រពៃណីទាំងនេះ បានផ្លាស់ប្ដូរទ្រង់ទ្រាយក្លាយទៅជារបៀបរបបផ្ដល់ឥណទាន ឬរបៀបរបបធ្វើអាជីវកម្មមានកិច្ចសន្យាវិញ ។ ក្នុងករណីរបៀបរបបជាប្រពៃណីនៅកើតមាន វាតែងកើតមានរវាងសមាជិកគ្រួសារ និងសាច់ញាតិ ជិតស្និទ្ធគ្នាប៉ុណ្ណោះ ដោយសារអ្នកណាក៏មានមិនគ្រប់សំរាប់ចែករំលែកជាមួយគ្រួសារឯទៀតៗ នៅពេលលំបាកតឹងតែងនោះដែរ ។ ប្រជាជនកាន់តែបុគ្គលនិយមយករួចខ្លួនឡើង ឬក៏កាន់តែប្រុងប្រយ័ត្នក្នុងការជួយជ្រោមជ្រែងអ្នកដទៃ ក្នុងអំឡុងពេល១២ខែកន្លងទៅ ដោយសារភាពមិនទៀងទាត់ នៅក្នុងការងារ និងប្រាក់ចំណូល ។ សាច់ញាតិជាអ្នកធូរធារ ក៏អាចសន្សំប្រាក់មិនបានច្រើនដូចមុនទេ ដោយសារវិបត្តិ

**តារាង ១: យុទ្ធសាស្ត្រដោះស្រាយ និងជំនួយទទួលដោយគ្រួសារជួបការលំបាក ក្នុងអង្កេតទាំង ៣ របស់ CDRI**[៥]

| | % នៃ ៦៩៩គ្រួសារ MOPs ២០០៤-២០០៥* | % នៃ ៤៥០គ្រួសារក្រីក្រ និងក្រីក្របំផុត ពីឆ្នាំ២០០៧ ដល់ខែតុលា ២០០៨** | % នៃ ៤៨១ គ្រួសារជួបការលំបាក ដែលបានទទួលជំនួយក្នុង៦ខែ មុនពេលធ្វើអង្កេត នៅខែមិថុនា ២០០៨*** |
|---|---|---|---|
| យុទ្ធសាស្ត្រដោះស្រាយរបស់គ្រួសារ | | | |
| ប្រើប្រាក់សន្សំ | 68 | 18,4 | |
| ខ្ចីបំណុល | 31 | 78,9 | 53 |
| សមាជិកគ្រួសារធ្វើចំណាកស្រុក ទៅរកការងារធ្វើ | 15 | 1,8 | |
| លក់សត្វចិញ្ចឹម | 11 | 2,2 | |
| កាត់បន្ថយចំណាយប្រើប្រាស់ | 14 | 3,3 | |
| ប្រើពលកម្មកុមារ | 8 | 1,6 | |
| លក់ផលិតផលកសិកម្ម | 3 | 1,1 | |
| លក់ដីកសិកម្ម | | 0,9 | |
| ធ្វើការកាន់តែខ្លាំង | | 1 | |
| លក់ទ្រព្យរូបវ័ន្ត | | 1 | |
| ជួលដី | | 1 | |
| ជំនួយ និងការគាំទ្រ បានទទួល | | | |
| ការគាំទ្រពីមិត្តភ័ក្រ/សាច់ញាតិ | 15 | 12,2 | 36 |
| ជំនួយពី NGOs | 1 | 2,4 | 36 |
| មីក្រូឥណទាន | | | 12 |
| របបអាហារឥតគិតថ្លៃដល់គ្រួសារ | | | 12 |
| អាហារសំរាប់កុមារ | | | 9 |
| ស្បៀងពលកម្ម | | | 6 |
| គ្រាប់ពូជ, ជី | | | 5 |
| សេវាបសុពេទ្យ | | | 5 |
| ចំណីសត្វ | | | 4 |
| ឧបករណ៍កសិកម្ម | | | 3 |
| អាហារសំរាប់កុមារតូចៗ/ខ្វះជីវជាតិ ឬស្ត្រីបំបៅកូន | | | |
| ការផ្ទេរប្រាក់ពីកម្មវិធីជំនួយខាង សង្គមកិច្ច | | | 23 |
| ផ្សេងៗ | 12 | | |

៥ ទោះបីអង្កេតទាំង ៣ បានធ្វើឡើងក្នុងគោលដៅខុសគ្នា និងក្នុងពេលខុសគ្នាក្ដី ប៉ុន្តែបានសួរសំនួរដូចគ្នាពីវិធីដោះស្រាយរបស់ អ្នកឆ្លើយសម្ភាសន៍ នៅពេលជួបការលំបាក និងការប៉ះទង្គិចផ្សេងៗ ។

ប្រភព: *Fitzgerald and so (2007); **Koy and Em (2009);***CDRI (2008) ។

នាពេលថ្មីៗ (ទំនិញឡើងថ្លៃខ្ពស់ បន្ទាប់មកសេដ្ឋកិច្ចក៏ធ្លាក់ចុះ) ។ ក្នុងនេះ អ្នកងាយរងគ្រោះជាងគេ គឺមនុស្សចាស់ចរា និងជនក្រីក្រដែលគ្មានសាច់ញាតិ និងគ្មានទំនាក់ទំនង ឬខ្សែរយៈក្នុងសង្គមសព្វថ្ងៃ ។ ពួកគេអាចត្រូវផាត់ចេញពីប្រព័ន្ធជួយឧបត្ថម្ភក្រៅផ្លូវការផ្សេងៗ ហើយទុកឱ្យនៅតែឯង និងកាន់តែងាយរងគ្រោះថែមទៀត ។

រូបភាពក្រៅផ្លូវការខ្លះនៃ ការចែករំលែកនិងគ្រប់គ្រងហានិភ័យ ឬ ការជួយគ្នាទៅវិញទៅមក នៅតែរឹងប៉ឹងនៅឡើយនៅក្នុងសហគមន៍ ទោះក្នុងក្រុមសង្គមប្រជាជនបែបណាក៏ដោយ ដូចជា ក្នុងការជួយរៀបចំពិធីបុណ្យសព ឬមង្គលការ ឬ ការជួយជ្រោមជ្រែងដល់អ្នកជួបគ្រោះថ្នាក់ អគ្គីភ័យ ខ្យល់ព្យុះ និង រន្ទះបាញ់ ជាដើម ។ ប៉ុន្តែប្រពៃណីនេះកាន់តែមានតិចហើយ ។

នៅកម្ពុជា សព្វថ្ងៃនៅមានការដោះដូរកំលាំងពលកម្ម និងសត្វចិញ្ចឹម នៅក្នុងក្រុមគ្រួសារធំ និងខ្សែរយៈសង្គមក្រៅផ្លូវការ ដោយឈរលើទំនុកចិត្ត និងកិច្ចសហប្រតិបត្តិការមានផលប្រយោជន៍ទៅវិញទៅមក ។ ប៉ុន្តែបច្ចុប្បន្ននេះ ការដោះដូរពលកម្មដូចជាក្នុងការដាំដុះជាដើម កំពុងតែជំនួសដោយប្រព័ន្ធជួលកំលាំងពលកម្មវិញ ។ រឿងនេះបានបង្កើតការងារដល់ជនក្រីក្រដែលគ្មានដីធ្លី ប៉ុន្តែក៏បានបង្កបញ្ហាជាច្រើនសំរាប់គ្រួសារមានមេគ្រួជាស្ត្រីគ្មានប្ដីដែលខ្វះខាតសត្វអូសទាញ និងពលកម្មបុរស និងដែលឥឡូវនេះគ្មានទទួលបានជំនួយអ្វីសោះក្នុងការងារភ្ជួររាស់ដី ហើយទីបំផុត ក៏ត្រូវលក់ដីនោះទៅ ។

ក្រុមជួយខ្លួនឯង ដូចជា ក្រុមសន្សំប្រាក់ ធនាគារស្រូវ និងធនាគារគោ ជាដើម សព្វថ្ងៃមានដំណើរការជាក់ស្ដែង និងជំរុញឡើងដោយ កម្មវិធីអភិវឌ្ឍន៍ជួយអ្នកក្រដំណើរការដោយ NGOs ដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការ និងទំនុកចិត្តក្នុងសហគមន៍ ។ ប៉ុន្តែសមាជិកក្រុមទាំងនេះ មិនមែនសុទ្ធតែជាជនក្រីក្រ ឬក្រីក្រខ្លាំងនោះទេ ពីព្រោះអ្នកក្រីក្រ ឬក្រីក្រខ្លាំងអាចពុំមានលទ្ធភាពបង់ប្រាក់កំរៃសមាជិកភាពបាន ។ មេគ្រួសារជាស្ត្រីគ្មានប្ដី ជនពិការ និង ជនចាស់ជរា (លើកលែងតែនៅក្នុងភូមិក្រសាំង ដែលមានអង្គការ HelpAge international ជួយដល់ក្រុមជនពិការ និងចាស់ជរានេះតែម្ដង) និងអ្នកក្រក្រខ្លាំងដែលបានឆ្លើយសម្ភាសន៍ ពួកគេមិនទាន់បានទទួលផលប្រយោជន៍អ្វីពីការផ្ដួចផ្ដើមគំនិតទាំងនេះទេ ។ សកម្មភាពជួយខ្លួនឯងក៏ងាយដួលរលំដែរក្នុងពេលបច្ចុប្បន្ន ពីព្រោះមានសមាជិកជាច្រើន មិនអាចសងបំណុលបាន ។ ធនាគារគោកំពុងដំណើរការទៅមុខ ប៉ុន្តែយឺតយ៉ាវក្នុងការឃោងឱ្យដល់អ្នកក្រ ។

ជនចាស់ជរា និងជនក្រីក្រខ្លាំង ជួនកាលអាចទទួលបានសេវាឧបត្ថម្ភនៅតាមវត្ត និងព្រះវិហារគ្រិះដែរ ប៉ុន្តែសេវានេះជួយបានតិចនាក់ណាស់ (ឧ. អ្នករស់នៅជិតវត្ត ឬគ្រិះបរិស័ទ្ធ) ។

ក្នុងពេលថ្មីៗនេះ ជំនួយឧបត្ថម្ភផ្នែកមនុស្សធម៌ រួមមាន ជំនួយសង្គ្រោះបន្ទាន់ពីកាកបាទក្រហមកម្ពុជា (CRC) និង គណបក្សនយោបាយផ្សេងៗ ដល់គ្រួសារអ្នករងគ្រោះមហន្តរាយដោយសារធម្មជាតិ ឬអ្វីផ្សេងៗ ហើយនិងអំណោយជាប្រាក់ ឬជាសំភារៈពីគណបក្សនយោបាយ ។ ជំនួយនេះវាយោងតាមកង្វះខាត ហើយពលករក្រីក្រ និងងាយរងគ្រោះដែលស្ថិតក្នុងការវាយតំលៃនេះ គឺធ្លាប់ទទួលបានជាក់ស្ដែង ។ ប៉ុន្តែជំនួយបែបនេះអាចមានផ្ដល់សំរាប់តែជួយសង្គ្រោះបន្ទាន់ប៉ុណ្ណោះ ដូច្នេះវាជាប្រភពសន្តិសុខមួយ មិនអាចទុកចិត្តបានទេ ហើយអាចជាជំនួយមានចំណងខាងនយោបាយ និង/ឬ មិនគ្រប់គ្រាន់សំរាប់ស្ដារស្ថានភាពឡើងវិញឱ្យបានទាំងស្រុង ។ម្យ៉ាងទៀត ជំនួយបែប នេះកាន់តែកំរឡើងហើយ ក្នុង ៦ខែកន្លងទៅនេះ ។

## ៤. ការសន្និដ្ឋាន

សរុបមក ក្រុមក្រីក្រទាំងអស់ កាន់តែងាយចុះក្រខ្លាំងថែមទៀតដោយសារវិបត្តិសេដ្ឋកិច្ចបច្ចុប្បន្ន ហើយអ្នកងាយរងគ្រោះខ្លាំងជាងគេ គឺជនគ្មានក្រុមគ្រួសារ/សាច់ញាតិជិតស្និទ្ធ មេគ្រួសារជាស្ត្រីគ្មានប្ដី ជនចាស់ជរា ជនពិការ អ្នករស់នៅឆ្ងាយពីវត្តអារាម និង កុមារ ។ បើសិនគ្មានអន្តរាគមន៍សមរម្យជួយឧបត្ថម្ភគាំទ្រដល់ជនក្រីក្រទេ ពួកគេមានសមត្ថភាពតិចតួចណាស់ដើម្បីទប់ទល់នឹងការប៉ះទង្គិចផ្សេងៗលើប្រាក់ចំណូល និងដើម្បីដកខ្លួនឱ្យផុតពីភាពក្រីក្រ ៕

## ឯកសារយោង


American Friends Service Committee (2000), *Socio-Cultural Vulnerability and Coping Strategies Research Project* (Phnom Penh: AFSC)

Ballard B., Sloth, C., Wharton, D., Fitzgerald, I., Murshid, K., Hansen, K., Phim R. & Lim S. (2007), *We Are Living with Worry All the Time: A Participatory Poverty Assessment of Tonle Sap* (Phnom Penh: CDRI)

Cambodia Development Resource Institute (2008), *Impact of High Food Prices in Cambodia* (Phnom Penh: CDRI)

Cambodia Development Resource Institute (2009), *Annual Development Review 2008-2009* (Phnom Penh: CDRI)

Devereux, S. (2001) “Livelihood Insecurity and Social Protection: A Re-emerging Issue in Rural Development”, *Development Policy Review,* 19(4), pp. 507-519

Fitzgerald, I. & So S. (2007) *Moving Out of Poverty? Trends in Community Well-being and Household Mobility in Nine Cambodian Villages* (Phnom Penh: CDRI_

Godfrey, M., Chan S., Kato T., Vou P., Dorina P., Saravy T. & So S. (2000), “Technical Assistance and Capacity Development in an Aid-dependent Economy: Experience of Cambodia”, *World Development* 30(3), pp. 355-373.

Kim S. (2001), “Reciprocity: Informal Patterns of Social Interactions in a Cambodian Village”, masters thesis (Northern Illinois University, Department of Anthropology)

Koy R. & Em S. (2009) “Building Community Capacity for Poverty Reduction Initiatives”, baseline survey for ADB and JFPR

Krishnamurthy, V. (1999), *The Impact of Armed Conflict on Social Capital: A Study of Two Villages in Cambodia* (Phnom Penh: World Bank)

McAndrew, J. (1998), *Independence in Household Livelihood Strategies in Two Cambodian Villages,* Working Paper 7 (Phnom Penh: CDRI)

Murshid, K. (1998), *Food Security in an Asian Transitional Economy: The Cambodian Experience* (Phnom Penh: CDRI)

Phlong P. (2009), “Informal Credit System{s?} in Cambodia”, masters thesis (Northern Illinois University De Kalb, Illinois)

World Bank (2006), *Halving Poverty by 2015? Poverty Assessment 2006* (Phnom Penh: World Bank)

World Bank, (2007), *Sharing Growth: Equity and Development Report 2007* (Phnom Penh: World Bank)

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីនិន្នាការសេដ្ឋកិច្ចនៃប្រទេសមានសេដ្ឋកិច្ចជឿនលឿនមួយចំនួនក្នុងពិភពលោក និង ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅអាស៊ីខាងកើត នៅត្រីមាសទី១ ឆ្នាំ២០០៩ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០០៩ កំណើន ផសស ពិតប្រចាំឆ្នាំរបស់សហរដ្ឋអាមេរិក មានកំរិត -២,៦% ធៀបនឹង ២,៥% នៅត្រីមាសដូចគ្នា ឆ្នាំ២០០៨ ។ ការធ្លាក់ចុះកំណើនយ៉ាងខ្លាំងនេះ បណ្ដាលជាសំខាន់មកពីការរួមចំណែកជាអវិជ្ជមាននៃការនាំចេញ វិនិយោគលើស្ដុកទំនិញឯកជន បរិក្ខារនិងសូហ្វវែរ សំណង់មិនសំរាប់ស្នាក់នៅ និង វិនិយោគជាប់លាប់លើសំណង់សំរាប់ស្នាក់នៅ ប៉ុន្ដែវាត្រូវបានប៉ះប៉ូវខ្លះៗវិញដោយការរួមចំណែកជាវិជ្ជមាន ពីចំណាយប្រើប្រាស់របស់បុគ្គល ។ ទិន្នន័យស្ដីពីកំណើន ផសស ពិត របស់សហភាពអឺរ៉ុប នៅត្រីមាសទី១ ឆ្នាំ២០០៩ បង្ហាញពីវិបត្ដិសេដ្ឋកិច្ចក្នុងតំបន់ វិវត្ដកាន់តែធ្ងន់ធ្ងរឡើង ។ ការធ្លាក់ចុះយ៉ាងខ្លាំងនៃតំរូវការ ជាពិសេសសំរាប់ការនាំចេញ និងវិនិយោគ គឺជាមូលហេតុចំបងបង្កការធ្លាក់ចុះដ៏ធំសម្បើម នៃកំណើន ផសស នេះ ។ ក្នុងពេលជាមួយគ្នា ផសស ពិត របស់ជប៉ុន បន្ដរួមចុះយ៉ាងខ្លាំង ដោយសារជាចំបង ការធ្លាក់ចុះយ៉ាងគំហុកនៃការនាំចេញទំនិញ និងសេវាកម្ម ក៏ដូចជា ចំណាយជាមូលធនរបស់ក្រុមហ៊ុន ។

កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំនៅប្រទេសចិន បានធ្លាក់ចុះពី ៦,៨% នៅត្រីមាសទី៤ ឆ្នាំ២០០៨ មកត្រឹម ៦,១% នៅត្រីមាសទី១ ឆ្នាំ២០០៩ ដែលជាតួលេខកំណើនប្រចាំត្រីមាសទាបបំផុត ក្នុងរយៈពេល ២០ឆ្នាំកន្លង មក ។ ការធ្លាក់ចុះនេះ បណ្ដាលពីការរួមចំណែកអវិជ្ជមានយ៉ាងតូចមួយនៃការនាំចេញសុទ្ធ ដែលមានការប៉ះប៉ូវមកវិញ ដោយកំណើនគួរឱ្យកត់សម្គាល់នៃចំណាយប្រើប្រាស់ក្នុងស្រុក ។ នៅត្រីមាសទី១ នេះដែរ ផសស របស់កូរ៉េខាងត្បូង បានរួមចុះថែមទៀត ដោយសារការធ្លាក់ចុះតំរូវការ នៅតាមទីផ្សារនាំចេញសំខាន់ៗភាគច្រើនរបស់ប្រទេសនេះ ។ សកម្មភាពសេដ្ឋកិច្ចនៅហុងកុង និងតៃវ៉ាន់ បន្ដធ្លាក់ចុះ ហើយ ផសស របស់ប្រទេសទាំងពីរនេះបន្ដរួមចុះថែមទៀត ។ ការធ្លាក់ចុះកំណើនសេដ្ឋកិច្ចនៅហុងកុង ផុសចេញពីការស្រុតចុះខ្លាំងនៃ ចំណាយប្រើប្រាស់ឯកជន និងការនាំចេញទំនិញនិងសេវាកម្ម ។ នៅតៃវ៉ាន់ ឯណោះវិញ មានការរួមចុះសេដ្ឋកិច្ចប្រចាំត្រីមាសធ្ងន់ធ្ងរបំផុត គិតចាប់ពីឆ្នាំ ១៩៦១មក ហើយស្ថានភាពនេះ បង្កឡើងពីការថយចុះយ៉ាងខ្លាំងនៃការនាំចេញទំនិញនិងសេវាកម្ម (២៧,២% ក្នុងរយៈពេលមួយឆ្នាំ) និង ការធ្លាក់ចុះចំណាយប្រើប្រាស់ឯកជន និងចំណាយរដ្ឋាភិបាល ។

នៅត្រីមាសទី១ ឆ្នាំ២០០៩ ផសស ពិតនៅម៉ាឡេស៊ី បានរួមចុះ ៦,២% ដែលជាស្ថានភាពអាក្រក់បំផុត គិតចាប់ពីត្រីមាសទី៤ ឆ្នាំ១៩៩៨ មក ។ ការរួមចុះនេះ បណ្ដាលមកពីការថយចុះយ៉ាងខ្លាំងនូវតំរូវការផលិតផលពីសំណាក់អតិថិជនខាងក្រៅប្រទេស (១៥,២% គិតក្នុងរយៈពេលមួយឆ្នាំ) និងការធ្លាក់ចុះនូវការបង្កើតទ្រព្យមូលធនជាប់លាប់ដុលប្រចាំឆ្នាំ (១០,៨%) ។ នៅសិង្ហបុរី ផសស ពិត មានសភាពកាន់តែអាក្រក់ ដោយមានអត្រារួមចុះពីមួយឆ្នាំដល់មួយឆ្នាំដល់ ១០,១% ដែលជាការធ្លាក់ចុះខ្លាំងបំផុត គិតចាប់ពីពាក់កណ្ដាលទសវត្សរ៍១៩៧០ មក ។ ការបាក់ស្រុតតំរូវការទំនិញនាំចេញរបស់សិង្ហបុរី គឺជាមូលហេតុចំបងនៃការរួមចុះ ផសស នេះ ។ ចំពោះប្រទេសថៃវិញ ផសស ពិត បានរួមចុះថែមទៀត ដែលឆ្លុះបញ្ចាំងពីការធ្លាក់ចុះកាន់តែខ្លាំងនៃសេដ្ឋកិច្ច ។ នៅត្រីមាសទី១ នេះ ផសស ពិត របស់ថៃ មានអត្រារួមចុះ ពីមួយឆ្នាំទៅមួយឆ្នាំ ដល់ ៧,១% ដែលបង្កឡើងដោយកត្ដាសំខាន់ពីរ គឺផលប៉ះពាល់នៃវិបត្ដិសេដ្ឋកិច្ចពិភពលោក ទៅលើសេដ្ឋកិច្ចថៃដែលមានលក្ខណៈពឹងផ្អែកខ្លាំងលើការនាំចេញ និងឥទ្ធិពលនៃអស្ថិរភាពនយោបាយ ទៅលើទំនុកចិត្ដរបស់វិនិយោគិន និងអ្នកប្រើប្រាស់ ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី១ ឆ្នាំ២០០៩ អតិផរណាថ្លៃទំនិញប្រើប្រាស់សរុបពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិក មានតួលេខអវិជ្ជមាន (-0,២%) ហើយកត្ដាសំខាន់ គឺកង្វះខាតយ៉ាងខ្លាំងនូវតំរូវការដែលបង្កឡើងដោយសារវិបត្ដិសេដ្ឋកិច្ច ។ ក្នុងពេលជាមួយគ្នានេះ អតិផរណានៅតំបន់អឺរ៉ូ បានធ្លាក់មកត្រឹម ១,0% ធៀបនឹងកំរិត ២,៣%នៅត្រីមាសមុន ហើយមូលហេតុនៅពីក្រោយការថយល្បឿនឡើងថ្លៃនេះ គឺការធ្លាក់ថ្លៃនៃប្រេង និងទំនិញប្រើប្រាស់ផ្សេងៗទៀត ។ ជប៉ុន បានជួបប្រទះឡើងវិញនូវបរិវត្ដបរមា (-0,១%) នៅពេលមានការរួមចុះសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរ នៅត្រីមាសទី១ នេះ ។ ការធ្លាក់ចុះយ៉ាងគំហុកនៃថ្លៃទំនិញប្រើប្រាស់ផ្សេងៗ និងថ្លៃប្រេងនៅលើពិភពលោក នៅឆមាសទី២ ឆ្នាំ២០០៨ និងប៉ុន្មានខែដើមឆ្នាំ២០០៩ បាននាំឱ្យទំនិញប្រើប្រាស់នៅជប៉ុន ធ្លាក់ថ្លៃយ៉ាងខ្លាំងបែបនេះ ។

នៅត្រីមាសទី១ ឆ្នាំ២០០៩ ប្រាក់ដុល្លារUS នៅថេរ បើធៀបនឹងប្រាក់យ៉ាន់ចិន ដុល្លារហុងកុង និងដុល្លារសិង្ហបុរី ប៉ុន្ដែបានឡើងថ្លៃ បើធៀបនឹងប្រាក់វ៉ុនកូរ៉េខាងត្បូង (៣,៣%) និងដុល្លារតៃវ៉ាន់ (៣,0%) ។ ដុល្លារUS ធ្លាក់ថ្លៃ ទល់នឹងប្រាក់អឺរ៉ូ និងប្រាក់យ៉េនជប៉ុន ដោយប្ដូរបាន 0,៧៦អឺរ៉ូ/ដុល្លារUS និង ៩៣,៧២យ៉េន/ដុល្លារUS ។ ភាពរឹងមាំនៃប្រាក់អឺរ៉ូ និងប្រាក់យ៉េននេះ បានធ្វើឱ្យផលិតផលរបស់តំបន់អឺរ៉ុប និងប្រទេសជប៉ុន កាន់តែមានថ្លៃខ្ពស់ បើគិតជាប្រាក់ដុល្លារUS ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០០៩ នេះ ទោះបីមានការរួមចុះសេដ្ឋកិច្ចជាទូទៅនៅលើពិភពលោកក្ដី ក៏ទំនិញកសិកម្មមួយចំនួន បានឡើងថ្លៃយ៉ាងច្បាស់នៅលើទីផ្សារអន្ដរជាតិ ។ ដោយឡែក ប្រេងឆា និង សណ្ដែកសៀង បានឡើងថ្លៃ ១២,៨% និង ១៣,៥% ធៀបនឹងត្រីមាសទី៤ ឆ្នាំមុន ហើយ ពោត (US No.2) និង អង្ករ (ថៃ ១០០%B) ក៏បានឡើងថ្លៃ ១% និង 0,៥% ដែរ ។ ផ្ទុយទៅវិញ ទំនិញថាមពលមួយចំនួន បានចុះថ្លៃគួរឱ្យកត់សម្គាល់ ក្នុងនេះ ប្រេងឆៅ សាំង និងម៉ាស៊ូត បានធ្លាក់ថ្លៃអស់ ២៣,៣% ៧,៤% និង ២៧,៣% បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០០៨ ៕

*រៀបរៀងដោយ សាំង ច័ន្ទហង្ស*

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-០៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | | | | 2009 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7.7 | 13.4 | 10.6 | 10.2 | 6.8 | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.1 | 5.6 | 5.4 | 6.3 | 6.1 | 6.3 | 6.4 | 6.1 | 5.2 | 4.4 |
| ម៉ាឡេស៊ី | 7 | 5.2 | 5.9 | 6.3 | 4.6 | 7.1 | 6.3 | 4.7 | 0.1 | -6.2 |
| សិង្ហបុរី | 8.5 | 5.7 | 7.7 | 7.7 | 1.1 | 7.2 | 1.9 | -0.6 | -4.2 | -10.1 |
| ថៃ | 6 | 4.5 | 4.8 | 4.9 | 2.6 | 6.0 | 5.3 | 3.9 | -4.3 | -7.1 |
| វៀតណាម | 7.5 | 8.4 | 8.1 | 8.5 | 6.2 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 9.5 | 9.6 | 10.5 | 11.9 | 9.0 | 10.6 | 10.1 | 9.0 | 6.8 | 6.1 |
| ហុងកុង | 8.3 | 6.5 | 6.6 | 6.4 | 2.4 | 6.8 | 4.2 | 1.7 | -2.5 | -7.8 |
| កូរ៉េខាងត្បូង | 4.7 | 4.7 | 5.0 | 4.9 | 2.2 | 5.7 | 4.8 | 3.8 | -3.6 | -4.4 |
| តៃវ៉ាន់ | 5.7 | 4.1 | 4.6 | 5.2 | 0.1 | 6.4 | 4.3 | -1.0 | -8.4 | -10.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 1.8 | 1.5 | 2.7 | 2.9 | 0.9 | 2.2 | 1.4 | 0.6 | -1.3 | -2.5 |
| ជប៉ុន | 3.4 | 2.5 | 2.1 | 2.0 | -0.7 | 1.3 | 1.0 | -0.5 | -4.6 | -9.1 |
| សហរដ្ឋអាមេរិក | 4.4 | 3.7 | 3.3 | 2.2 | 1.1 | 2.5 | 2.8 | -0.5 | -6.3 | -2.6 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០០៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | | | | 2009 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 4.0 | 5.8 | 4.7 | 10.5 | 19.7 | 16.5 | 24.9 | 21.7 | 15.7 | 4.3 |
| ឥណ្ឌូនេស៊ី | 8.3 | 10.5 | 13.4 | 6.4 | 10.1 | 7.6 | 10.1 | 11.9 | 11.4 | 8.5 |
| ម៉ាឡេស៊ី | 1.6 | 3.1 | 3.7 | 2.0 | 5.3 | 2.6 | 4.8 | 8.4 | 5.9 | 3.7 |
| សិង្ហបុរី | 1.7 | 0.5 | 1.0 | 2.1 | 6.5 | 6.6 | 7.5 | 6.5 | 5.5 | 2.1 |
| ថៃ | 2.7 | 4.5 | 4.7 | 2.2 | 5.5 | 5.0 | 7.7 | 7.2 | 2.2 | -0.2 |
| វៀតណាម | 7.8 | 8.2 | 7.7 | 8.3 | 23.3 | 16.4 | 24.4 | 29.0 | 23.6 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 3.9 | 1.8 | 1.5 | 4.8 | 5.9 | 8.0 | 7.8 | 5.3 | 2.5 | -0.6 |
| ហុងកុង | -0.4 | 1.1 | 2.2 | 2.0 | 4.3 | 4.6 | 5.7 | 4.6 | 2.3 | 1.7 |
| កូរ៉េខាងត្បូង | 3.5 | 2.8 | 2.4 | 2.5 | 4.6 | 3.7 | 4.8 | 5.5 | 4.5 | 3.9 |
| តៃវ៉ាន់ | 1.6 | 2.3 | 0.6 | 1.8 | 3.2 | 2.3 | 4.2 | 4.5 | 1.9 | 0.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.2 | 2.1 | 2.1 | 3.3 | 3.4 | 3.8 | 3.8 | 2.3 | 1.0 |
| ជប៉ុន | Nil | -0.3 | 0.5 | 0.1 | 1.4 | 1.0 | 1.4 | 2.2 | 1.0 | -0.1 |
| សហរដ្ឋអាមេរិក | 2.7 | 3.4 | 3.2 | 2.9 | 3.8 | 4.1 | 4.4 | 5.3 | 1.5 | -0.2 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០០៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | | | | 2009 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 4016.3 | 4092.5 | 4103.2 | 4062.7 | 4054.2 | 3995.3 | 4030.3 | 4117.4 | 4089.8 | 4108.0 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8938 | 9705 | 9134 | 9419 | 9699.0 | 9248.2 | 9265.3 | 9216.3 | 11,060 | 11630.8 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.79 | 3.67 | 3.31 | 3.34 | 3.22 | 3.21 | 3.37 | 3.56 | 3.63 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.69 | 1.66 | 1.59 | 1.51 | 4.58 | 1.41 | 1.37 | 1.43 | 1.49 | 1.51 |
| ថៃ (បាត) | 40.2 | 40.2 | 37.9 | 32.22 | 33.36 | 32.37 | 32.25 | 34.0 | 34.83 | 35.29 |
| វៀតណាម (ដុង) | 15,777 | 15,859 | 15,994 | 16,030 | 16,382 | 15,896 | 16,881 | 16,517 | 16,537 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.19 | 7.97 | 8.03 | 6.94 | 7.16 | 6.96 | 6.82 | 6.83 | 6.84 |
| ហុងកុង (ដុល្លារហុងកុង) | 7.79 | 7.78 | 7.77 | 7.8 | 7.78 | 7.79 | 7.80 | 7.77 | 7.75 | 7.75 |
| កូរ៉េខាងត្បូង (វ៉ុន) | 1145 | 1024 | 955 | 929.04 | 1137.23 | 955.89 | 1018.84 | 1207.0 | 1367.2 | 1412.5 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.6 | 32.1 | 32.5 | 32.85 | 31.54 | 31.52 | 30.45 | 31.20 | 33.0 | 34.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.80 | 0.80 | 0.7 | 0.84 | 0.7 | 0.64 | 0.71 | 1.32 | 0.76 |
| ជប៉ុន (យ៉េន) | 108.2 | 110.2 | 116.4 | 117.8 | 102.46 | 105.2 | 104.53 | 104.03 | 96.1 | 93.72 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៤-២០០៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | | | | 2009 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No. 2) - US ($/តោន) | 110.65 | 89.19 | 111.04 | 149.08 | 218.15 | 198.39 | 238.03 | 254.99 | 181.22 | 183.12 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 427.47 | 381.32 | 433.85 | 707.68 | 912.23 | 1048.49 | 1086.89 | 949.03 | 564.50 | 636.53 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 221.67 | 262.88 | 282.00 | 305.36 | 615.32 | 444.43 | 839.58 | 657.88 | 519.41 | 522.13 |
| សណ្តែកសៀង (US No. 1) - US ($/តោន) | 262.03 | 224.25 | 213.88 | 294.59 | 460.41 | 449.64 | 479.97 | 529.30 | 382.72 | 434.40 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 33.5 | 50.14 | 61.58 | 69.25 | 95.44 | 93.77 | 117.48 | 115.30 | 55.23 | 42.34 |
| សាំង - US Gulf Coast (សេន/លីត្រ) | 30.9 | 42.19 | 47.70 | 53.58 | 62.22 | 64.21 | 80.90 | 81.27 | 34.52 | 31.97 |
| ម៉ាស៊ូត (ស្តង់ដ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 29.48 | 44.35 | 51.35 | 55.51 | 76.2 | 73.99 | 95.37 | 88.46 | 46.98 | 34.17 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី១ ឆ្នាំ២០០៩ អនុមតិវិនិយោគបានធ្លាក់ចុះអស់ ៤៦% ធៀបនឹងត្រីមាសមុនមកត្រឹម ៩២៨,៦លានដុល្លារអាមេរិក ប៉ុន្តែបានកើនឡើងមួយជាបីធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ ការប្រែប្រួលពី ត្រីមាសមុនផុសចេញពីការធ្លាក់ចុះក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម នៅខណៈពេលដែលអនុមតិខាងកសិកម្មបានកើនឡើងគួរឱ្យកត់សំគាល់ពី៤,៤លានដុល្លារបស ដល់ ១៧៥,៣លានដុល្លារបស ។ អនុមតិខាងឧស្សាហកម្មធ្លាក់ចុះ ៤៧% មកត្រឹម ២៥៧,៧លានដុល្លារបស ក្នុងនេះ ខាងកាត់ដេរ មានចំណែក ៦,៤% រ៉ែ ១,២% ថាមពល ៤៦% និង ហេដ្ឋារចនាសម្ព័ន្ធ ៣៥% ។ គំរោងខាងហេដ្ឋារចនាសម្ព័ន្ធ និងវិស័យថាមពល មានការទាក់ទាញចំណាប់អារម្មណ៍ជាពិសេស ដោយមានសំណើសុំការអនុម័តគំរោងខ្សែកាបបញ្ជូនអគ្គិសនី និងបណ្តាញចែកចាយចំនួន ១១៨,៥លានដុល្លារបស នៅត្រីមាសទី១ ។ អនុមតិវិស័យសេវាកម្មធ្លាក់ចុះ យ៉ាងលឿនអស់ ៦៣% មកត្រឹម ២៥៤,១លានដុល្លារបស ក្នុងនេះ អនុមតិសណ្ឋាគារធ្លាក់ចុះពី ៣២៣,៨លានដុល្លារបស នៅត្រីមាសមុនដល់កំរិតសូន្យ ហើយវិស័យទេសចរណ៍ធ្លាក់ចុះ ៧០% មកត្រឹម ២៥៤,១លានដុល្លារបស ។ ខាងសេវាកម្ម អនុមតិគំរោងទូរគមនាគមន៍មានចំណែកធំដោយមានចំនួនដល់ ២៣៤,៧លានដុល្លារបស ។ គំរោងបានអនុម័តសំរាប់វិស័យទាំងបីនឹងផ្តល់ការងារសរុប ២៤.៣០៣ការងារ ក្នុងនេះ ២៤%នៅខាងកសិកម្ម ៥៦% នៅខាងឧស្សាហកម្ម និង ២០%ខាងសេវាកម្ម ។

ទីផ្សារអចលនទ្រព្យនៅកម្ពុជាកំពុងតែតស៊ូពុះពារឧបសគ្គបង្កដោយវិបត្តិសេដ្ឋកិច្ចសកល ។ ជាលទ្ធផល សំណង់មួយចំនួនបានឈប់ដំណើរការបណ្តោះអាសន្ន ។ នៅត្រីមាសទី១ អនុមតិវិស័យសំណង់នៅក្រុងភ្នំពេញធ្លាក់ចុះអស់ ៤៩% ធៀបនឹងត្រីមាសមុនមកត្រឹម ១៨១,១លានដុល្លារបស ។ អនុមតិគំរោងសាងសង់ផ្ទះ និងវីឡាធ្លាក់ចុះ ១៩% មកត្រឹម ៣២,១លានដុល្លារបស ប៉ុន្តែមានការប៉ះប៉ូវវិញដោយសំណង់ផ្ទះល្វែង កើនយ៉ាងខ្លាំងបាន ៥៩% រហូតដល់ ៩៥,២លានដុល្លារបស ។ ទោះជាយ៉ាងណាក៏ដោយ អនុមតិសរុបមានកំរិត ៣២% ខ្ពស់ជាងកាលពីត្រីមាសដូចគ្នាឆ្នាំមុន ។ អនុមតិគំរោងសាងសង់នៅត្រីមាសទី១ បានធ្លាក់ចុះក៏ពិតមែន ប៉ុន្តែការអនុវត្តគំរោងអនុម័តតាំងពីមុនសំរាប់សំណង់ក្នុងក្រុងភ្នំពេញ ឬនៅជាយក្រុង កំពុងដំណើរការតាមផែនការ ដូចជា ការសាងសង់ជាបន្តនៅទីក្រុងរណបមានអាគារចំរុះក្នុងទឹកប្រាក់ ៥០,០លានដុល្លារបស នៅតំបន់ជ្រោយចង្វារ ជាដើម ។

នៅត្រីមាសទី១ ឆ្នាំ២០០៩ ភ្ញៀវចូលមកកម្ពុជាមានសរុប ៦២២.២៨៨នាក់ ឬកើនឡើង ៧,៧% ធៀបនឹងត្រីមាសមុន ក្នុងនេះ ភ្ញៀវមកលំហែកំសាន្តមាន ៨៨% មកធ្វើពាណិជ្ជកម្មមាន ៥,៤% និង ផ្សេងៗទៀត ៦,៦% ។ ដោយឡែកព្រលានយន្តហោះទទួលអ្នកដំណើរបាន ៣៣៥.២១៣នាក់ ឬកើនឡើង ៦,០% ធៀបនឹងត្រីមាសមុន ។ ក្នុងតួលេខនេះមាន ៤៣% ចូលមកតាមអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ៥៧% តាមអាកាសយានដ្ឋានខេត្តសៀមរាប ។ ភ្ញៀវចូលមកតាមផ្លូវទឹកកើន ៧២% ដល់ ១៩.៣១៤នាក់ និងតាមផ្លូវគោកកើន ៤,៩% ដល់ ២៤២.០៥៣នាក់ ។ ក្នុងចំណោមភ្ញៀវបរទេសចូលមក នៅត្រីមាសទី១ ភ្ញៀវវៀតណាមមានច្រើនជាងគេ (៧២.៣២៤នាក់) បន្ទាប់មកគឺ កូរ៉េខាងត្បូង (៦៣.៩៣៩នាក់) និងសហរដ្ឋអាមេរិក (៤៧.៨២៤នាក់) ។

នៅត្រីមាសទី១ ឆ្នាំ២០០៩ តំលៃនៃការនាំចេញធ្លាក់ចុះបន្តិចបន្តួច រីឯការនាំចូលកើនឡើងបន្តិច បើធៀបនឹងត្រីមាសមុន ។ ជាលទ្ធផល ឱនភាពពាណិជ្ជកម្មបានថយចុះពី ១៨៧,៧លានដុល្លារបស នៅត្រីមាសមុនមកត្រឹមតែ ១៥៧,៦លានដុល្លារបស ។ ការនាំចេញសរុបធ្លាក់ចុះអស់ ០,៩% ដល់ត្រឹម ៧២១,៤លានដុល្លារបស ដោយសារការធ្លាក់ចុះខាងវិស័យកាត់ដេរអស់ ១១% មកត្រឹម ៦០៦,៩លានដុល្លារបស ទោះបីការនាំចេញកៅស៊ូ បានកើនឡើងមួយជាពីរ ការនាំចេញឈើកើនពីសូន្យ ដល់ ០,១លានដុល្លារបស និងការនាំចេញត្រីកើន ៥០% ក្តី ។

ការនាំចូលកើន ៧,៨% ធៀបនឹងត្រីមាសមុន ដល់ ៩៨៧,៧លានដុល្លារបស ។ ការនាំចូលសំភារៈសំណង់ និងប្រេងឥន្ធនៈ កើន ២៦% ដល់ ២,៧លានដុល្លារបស និង ៧,០% ដល់ ៦៧,៣លានដុល្លារបស ។ ក្នុងការនាំចូលសំភារៈសំណង់សរុប ស៊ីម៉ង់ត៍មានចំណែក ២៦% និង ដែក ៥៣% ។ ដោយសារកំណើនសំណង់ហេដ្ឋារចនាសម្ព័ន្ធ តំរូវការសំភារៈសំណង់ក៏កើនឡើងដែរ ដែលធ្វើអោយការនាំចូលកើនឡើង ។ ការនាំចូលវាយនភ័ណ្ឌកើនឡើងយ៉ាងខ្លាំងពី ១៤,៩លានដុល្លារបស នៅត្រីមាសមុន រហូតដល់ ៥៣,៥លានដុល្លារបស ។

## ហិរញ្ញវត្ថុសាធារណៈ

បន្ទាប់ពីមានអតិរេកនៅត្រីមាសទី១ឆ្នាំមុន ថវិកាជាតិក៏មានឱនភាពវិញនៅត្រីមាសបន្តបន្ទាប់មកទៀត ។ នៅត្រីមាសទី១ ឆ្នាំ២០០៩ ឱនភាពថវិកាកើនដល់ ៥៤៨,៩ពាន់លានរៀល ធៀបនឹង ៤៩៥,៩ពាន់លានរៀល នៅត្រីមាសមុន ។ ទាំងការប្រមូលចំណូលសរុប និងទាំងការចំណាយ បានធ្លាក់ចុះ ។ ចំណូលសរុបធ្លាក់ចុះ ១៨% ដល់ ១១០១,៧ពាន់លានរៀល ។ ក្នុងនោះចំណូលពន្ធធ្លាក់ចុះ ១៤% ដល់ ៩៤៧,៤ពាន់លានរៀល និង ចំណូលមិនមែនពន្ធធ្លាក់ចុះ ១៧% ដល់ ១៥០,៣ពាន់លានរៀល ។ ក្នុងចំណូលពន្ធសរុប ពន្ធក្នុងស្រុក ដែលមានចំណែក ៧៥% និងរួមមាន ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណេញ ពន្ធលើតំលៃលើស អាករលើផលរបរ និងអាករលើតំលៃបន្ថែម បានធ្លាក់ចុះ ១១% ហើយ ពន្ធលើការនាំចេញ-នាំចូល ដែលមានចំណែកប្រមាណ ២៥% បានធ្លាក់ចុះអស់ ២៤% ។ ក្នុងចំណូលមិនមែនពន្ធ ប្រាក់ចំណូលពីការលក់ទំនិញនិងសេវាផ្សេងៗ ប្រាក់កំរៃលើការបើកអាជីវកម្ម កំរៃរដ្ឋបាល និង ពន្ធព្រលានយន្តហោះ បានធ្លាក់ចុះ ១៥% មកត្រឹម ៩៣,៥ពាន់លានរៀល ឯប្រាក់ចំណូលបានមកពីការជួលដី និងសហគ្រាសសាធារណៈ កើន ២៩% ដល់ ១៣,១ពាន់លានរៀល ។ ដោយឡែក ចំណូលជាមូលធន ធ្លាក់ចុះ ៩២% មកត្រឹម ៤,០ពាន់លានរៀល ។

ចំណាយសរុប ធ្លាក់ចុះ ៩,៩% ធៀបនឹងត្រីមាសមុន មកត្រឹម ១៦៥០,៦ពាន់លានរៀល ។ រឿងនេះបណ្តាលពីការធ្លាក់ចុះ ៣៤% ក្នុងចំណាយចរន្ត និង ២១% ក្នុងចំណាយជាមូលធន ។ ចំណាយលើបៀវត្សរ៍ដែលតែងធ្លាក់ចុះនៅត្រីមាសទី១ រៀងរាល់ឆ្នាំ បានធ្លាក់ចុះអស់ ២១% មកត្រឹម ៣២៧,៤ពាន់លានរៀល ។ ប្រាក់ឧបត្ថម្ភខាងសង្គមកិច្ច ធ្លាក់ចុះ ៤៤% មកត្រឹម ២១៧,៣ពាន់លានរៀល ។ ចំណាយរបស់ រដ្ឋាភិបាលលើការទិញសំភារៈផ្គត់ផ្គង់ការិយាល័យ ស្បៀងអាហារនិងផលិតផលកសិកម្ម ផលិតផលខាងអនាម័យ និងថែទាំសុខភាព ទឹកនិងថាមពល និងសំភារៈផ្សេងទៀត មានចំណែក ៥,២% នៃចំណាយសរុប រីឯ ចំណាយបង់ការប្រាក់ មាន

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

១.៤% ។ ចំណាយជាមូលធន មាន ៦៩៣,៦ពាន់លានរៀល ក្នុងនេះ ៣០% ប្រើហិរញ្ញប្បទានក្នុងស្រុក និង ៧០% ទៀតប្រើហិរញ្ញប្បទានពីខាងក្រៅ ។

## អតិផរណា និងអត្រាប្តូរប្រាក់

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្រុងភ្នំពេញ បានកើនឡើង ៤,៣% នៅត្រីមាសទី១ ឆ្នាំ២០០៩ បើធៀបនឹងកាលពីមួយឆ្នាំមុន ។ កំរិតថ្លៃផ្នែកថែទាំសុខភាព បានកើនឡើង ២,៦% ចំណីអាហារនិងភេសជ្ជៈ កើន ៦,០% ហើយ សំលៀកបំពាក់និងស្បែកជើង កើន ៦,១% ។ កំរិតថ្លៃក៏បានកើនឡើង ២២,៦% សំរាប់ខាងអប់រំ ៦,៣៦% សំរាប់ចំណាយប្រចាំថ្ងៃតាមគ្រួសារ និង ៣,០% សំរាប់ខាងលំហែកំសាន្ត និងវប្បធម៌ ។ ប៉ុន្តែសន្ទស្សន៍ថ្លៃបានធ្លាក់ចុះ ១៣,០% សំរាប់ការដឹកជញ្ជូន ៩,៦% សំរាប់ទូរគមនាគមន៍ និង ១,៩% សំរាប់ការស្នាក់នៅ ។ កំណើនសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុបទំនងជាត្រូវចុះទាបនៅត្រីមាសខាងមុខ បើសិនថ្លៃប្រេងឥន្ធនៈ ព្រមទាំងចំណាយសាធារណៈ នៅតែបន្តធ្លាក់ចុះ ។

នៅត្រីមាសទី១ ឆ្នាំ២០០៩ ប្រាក់រៀលចុះថ្លៃ ០,៥% ទល់នឹងប្រាក់ដុល្លារ US បើធៀបនឹងត្រីមាសមុន ដោយប្តូរបានជាមធ្យម ៤១១១,៦រៀល/ដុល្លារអាមេរិក ។ ប្រាក់រៀលក៏ឡើងថ្លៃ ០,៩% ទល់នឹងប្រាក់បាតថៃដែរ ដោយប្តូរបាន ១១៦,៦រៀល/បាត ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀលឡើងថ្លៃ ២,៨% ដោយប្តូរបាន ២៣,៦រៀល/១០០ដុង ។

## ការវិវត្តរូបិយវត្ថុ

នៅខែមីនា ២០០៩ អត្រាកំណើនប្រចាំឆ្នាំនៃរូបិយវត្ថុទូទៅ (M2) មានកំរិត ៤៨% ហើយអត្រាកំណើនសំរាប់ រូបិយវត្ថុ (M1) គឺ ៥២% ។ រូបិយវត្ថុទូទៅ មានចំនួន ១២.៤៨៧,៦ពាន់លានរៀល ឬកើនឡើង ៣,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ ប្រាក់រៀលចរាចរកើន ៦,១% ដល់ ២៤៦៤,៦ពាន់លានរៀល ប្រាក់បញ្ញើជារៀលកើន ៤៣% ដល់ ២៧៣,៦ពាន់លានរៀល ហើយប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើន ២,៣% ដល់ ៩៧៤៩,៤ ពាន់លានរៀល ។

ក្នុងប្រតិបត្តិការរូបិយវត្ថុ ទ្រព្យសកម្មបរទេសសុទ្ធ កើនដល់ ១១.២២១,៦ពាន់លានរៀលនៅខែមីនា ២០០៩ ឬកើន ២,៨% ធៀបនឹងខែមីនា ២០០៨។ ទ្រព្យសកម្មបរទេសសរុប ស្ទុះឡើងដល់ ១១៦២,៤ពាន់លានរៀល ដោយសារកំណើន ១៤៩៥,៩ពាន់លានរៀល ក្នុងទ្រព្យសកម្មបរទេសនៅធនាគារជាតិ និងការធ្លាក់ចុះ ៣៣៣,៥ពាន់លានរៀលក្នុងទ្រព្យសកម្មបរទេសនៅតាមបណ្តាធនាគារពាណិជ្ជ ។ បំណុលបរទេសមានកំរិត ៨៥១,៦ពាន់លានរៀលខ្ពស់ជាងខែដូចគ្នាឆ្នាំមុន ដោយសារកំណើនបំណុលបរទេសរបស់ធនាគារពាណិជ្ជ ។ ឥណទានដល់វិស័យឯកជន បានកើន ២២% ដល់ ៩៨១៤,៣ពាន់លានរៀល ចំណែកឯ ឥណទានលើរដ្ឋាភិបាល ធ្លាក់ចុះ ៨,៨% មកត្រឹម ២៧០,៤ពាន់លានរៀល ។ ប្រាក់បញ្ញើរដ្ឋាភិបាលកើនឡើង ២៣% ដល់ ៣៣១៨,៨ពាន់លានរៀល ខណៈពេលដែលបំណុលដទៃទៀតបានកើនឡើង ២២% ដល់ ៩៤៩៩,៩ពាន់លានរៀល ។

## ស្ថានភាពភាពក្រីក្រ

អង្កេតលើពលករងាយរងគ្រោះក្នុងខែឧសភា ២០០៩ បានបង្ហាញថា ប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យម របស់ពលករងាយរងគ្រោះទាំង ១០ក្រុម គ្មានការផ្លាស់ប្តូរទេធៀបនឹងខែកុម្ភៈ ២០០៩ ប៉ុន្តែបានធ្លាក់ចុះ ១៤,៦% ធៀបនឹងខែវិច្ឆិកា ២០០៨ (មើល តារាង៨) ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូធ្លាក់ចុះពី ៨៥០៦រៀលនៅខែកុម្ភៈ ២០០៩ មកត្រឹម ៧៨៨៤រៀលនៅ ខែឧសភា និងធ្លាក់ចុះអស់ ៣៧,៦% បើធៀបនឹងខែវិច្ឆិកា ២០០៨ ។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មាន ៨៥% បានរាយការណ៍ថា ប្រាក់ចំណូលរបស់ខ្លួនមិនអាចផ្គត់ផ្គង់គ្រួសារទាំងមូលបានទេ និងមាន ៤២,៥% បានត្អូញត្អែរពីការជំពាក់បំណុលគេ ដោយសារប្រាក់ចំណូលមានមិនគ្រប់គ្រាន់សំរាប់ចំណាយលើម្ហូបអាហារ ។

ប្រាក់ចំណូលរបស់អ្នកលីសែងធ្លាក់ចុះ ១២,៤% មកត្រឹម ១០.៤៤២ រៀលក្នុងមួយថ្ងៃ នៅខែកុម្ភៈ និង ៩១៤៤រៀលក្នុងមួយថ្ងៃ នៅខែឧសភា ដោយសារកំណើនចំនួនអ្នកលីសែង និងការធ្លាក់ចុះសកម្មភាពលីសែង បើយោងតាម ៨៧,៥%នៃអ្នកឆ្លើយសម្ភាសន៍ ។ អ្នកលីសែងភាគច្រើននៅលីវ និងអាយុក្រោម ២៥ឆ្នាំ ។ ពួកគេភាគច្រើន (៧៥%) មិនសង្ឃឹមថា ប្រាក់ចំណូលរបស់គេនឹងកើនឡើង ក្នុងពីរបីខែខាងមុខទេ ដោយសារការធ្លាក់ចុះនាពេលថ្មីៗក្នុងសកម្មភាពសំណង់ បានជំរុញឱ្យកម្មករសំណង់ជាច្រើននាក់ចាប់ការងារជាអ្នកលីសែងវិញ ។

នៅខែឧសភា ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះមកត្រឹម ១១.៦១៣រៀល ឬធ្លាក់ចុះ ៧,៣% ធៀបនឹងខែកុម្ភៈ ។ អ្នកឆ្លើយសម្ភាសន៍បានត្អូញត្អែរដូចក្រុមផ្សេងទៀតដែរថា ប្រាក់ចំណូលរបស់ខ្លួនពិបាកដោះស្រាយចំណាយឱ្យបានគ្រប់ណាស់ ដូច្នេះត្រូវតែទៅខ្ចីបំណុលគេ ។

ប្រាក់ចំណូលរបស់កម្មកររោងចក្រកាត់ដេរធ្លាក់ចុះ ១១,៩% យោងតាមអង្កេតចុងក្រោយនេះ មកត្រឹម ៥៩២៩រៀលក្នុងមួយថ្ងៃ ដោយសារមិនសូវមានការងារបន្ថែមម៉ោង បើយោងតាម ៥៧% នៃអ្នកឆ្លើយសម្ភាសន៍ ។ កម្មកររោងចក្រកាត់ដេរភាគច្រើនមកពីជនបទជាមួយមិត្តភ័ក្តិ ។ កម្មករ ២៣% មិនមានដីធ្លីទេ ហើយ ៧៧% មានដីកសិកម្មតិចជាងមួយហិកតា ។ ទោះបីប្រាក់ចំណូលបានធ្លាក់ចុះក៏ដោយ ក៏ពលករត្រូវផ្ញើប្រាក់ខ្លះទៅផ្ទះដើម្បីជួយផ្គត់ផ្គង់សមាជិកគ្រួសារដែលមិនអាចដោះស្រាយជីវភាពបានដោយសារពុំមានការងារធ្វើច្រើនគ្រប់គ្រាន់ នៅស្រែចំការ ។

ប្រាក់ចំណូលរបស់កម្មករសំណង់មានជំនាញកើន ៣,៤% ដល់ ១២.១២៩រៀល ក្នុងមួយថ្ងៃ ប៉ុន្តែបានធ្លាក់ចុះ ៤,៦% បើធៀបនឹងខែវិច្ឆិកា ២០០៨ ។ ជីវភាពរស់នៅគឺលំបាកតឹងតែង បន្ទាប់ពីសកម្មភាពសំណង់បានធ្លាក់ចុះ ។ ការប្រកួតប្រជែងដណ្តើមការងារធ្វើ បានកើនឡើងក្នុងអំឡុងពេលសេដ្ឋកិច្ចធ្លាក់ចុះ ហើយមានមនុស្សកាន់តែច្រើន កំពុងស្វែងរកការងារក្នុងផ្នែកនេះ បន្ទាប់ពីពួកគេត្រូវបានបញ្ឈប់ពីការងារ ដូចជា ការងារកម្មកររោងចក្រកាត់ដេរ ជាដើម ។

នៅខែឧសភា អីវ៉ាន់អេតចាយបានឡើងថ្លៃខ្ពស់ជាងកាលពីអង្កេតលើកមុន ដែលធ្វើឱ្យប្រាក់ចំណូលរបស់ អ្នករើសអេតចាយ កើនឡើង ១៤,១% ។ ទោះយ៉ាងនេះក្តី លទ្ធភាពរកចំណូលរបស់ពួកគេទំនងត្រូវធ្លាក់ចុះ ប្រសិនបើពុំមានការអនុញ្ញាតឱ្យពួកគេរើសសំរាមនៅកន្លែងចាស់តទៅទៀត ៕

*រៀបចំដោយ*

*ផាន់ ដាលីស និង ប៊ុន ដូរីណា*

# តាមដានសេដ្ឋកិច្ច ‑ ស្ថានភាពក្នុងប្រទេស

## តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | | | 2008 | | | | 2009 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | |
| កសិកម្ម | 3.7 | 12.3 | 26.8 | 498.0 | 2.1 | 12.0 | 102.4 | 52.3 | 16.7 | 18.6 | 4.4 | 175.3 |
| ឧស្សាហកម្ម | 137.2 | 187.9 | 914.6 | 365.3 | 51.2 | 187.2 | 328.0 | 52.9 | 95.0 | 91.6 | 485.4 | 257.7 |
| *កាត់ដេរ* | *68.1* | *132.6* | *174.4* | *89.4* | *24.3* | *40.7* | *69.1* | *42.3* | *47.8* | *31.3* | *21.4* | *16.4* |
| សេវាកម្ម | 168.4 | 91.8 | 155.5 | 2939.1 | 138.0 | 957.7 | 311.1 | 148.2 | 4064.9 | 4450.5 | 1339.6 | 495.6 |
| *សណ្ឋាគារ និងទេសចរណ៍* | *124.1* | *55.9* | *102.6* | *345.0* | *55.0* | *653.8* | *199.2* | *93.7* | *4015.0* | *3481.3* | *1168.1* | *254.1* |
| សរុប | 309.3 | 292.0 | 1096.9 | 3802.4 | 191.3 | 1156.9 | 741.5 | 253.4 | 4176.5 | 4560.7 | 1580.3 | 928.6 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | -61.6 | 504.7 | -35.9 | -78.1 | 1548.2 | 9.2 | -65.3 | -41.2 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 22.1 | -5.6 | 275.6 | 246.6 | 91.8 | 334.6 | -23.7 | -49.1 | 2083.2 | 294.2 | 113.1 | 266.5 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | | | 2008 | | | | 2009 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | លានដុល្លារ | | | | | | |
| ភូមិគ្រឹះ និង ផ្ទះ | 20.0 | 30.3 | 45.5 | 33.1 | 22.8 | 21.7 | 20.2 | 45.3 | 17.6 | 52.1 | 39.7 | 32.1 |
| ផ្ទះល្វែង | 91.6 | 167.6 | 204.2 | 213.3 | 33.2 | 117.5 | 57.6 | 40.9 | 55.1 | 65.6 | 60.0 | 95.2 |
| ផ្សេងៗ | 87.3 | 65.6 | 109.1 | 76.8 | 88.8 | 40.6 | 94.3 | 51.2 | 68.2 | 369.3 | 252.2 | 53.7 |
| សរុប | 198.9 | 263.5 | 358.8 | 323.3 | 144.7 | 179.7 | 172.2 | 137.3 | 140.9 | 486.9 | 351.9 | 181.1 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | 3.9 | 24.2 | -4.2 | -1.4 | 2.6 | 245.6 | -27.7 | -48.5 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | -9.5 | 32.5 | 36.2 | -9.9 | 76.0 | 88.2 | 120.2 | -1.4 | -2.6 | 170.9 | 104.4 | 31.9 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | | | 2008 | | | | 2009 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | |
| តាមផ្លូវអាកាស | 456.0 | 626.1 | 856.5 | 1029.0 | 275.6 | 278.5 | 368.8 | 402.0 | 262.0 | 259.2 | 316.2 | 335.2 |
| តាមផ្លូវគោក និងទឹក | 245.0 | 428.9 | 565.1 | 672.9 | 148.9 | 153.3 | 239.2 | 242.2 | 192.0 | 186.3 | 261.4 | 287.1 |
| សរុប | 701.1 | 1055.0 | 1421.6 | 1701.9 | 424.5 | 431.8 | 608.0 | 644.2 | 454.0 | 445.5 | 577.6 | 622.3 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | -22.9 | 1.7 | 40.8 | 6.0 | -29.5 | -1.9 | 29.6 | 7.7 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | -10.9 | 50.5 | 34.7 | 19.7 | 19.2 | 16.5 | 17.8 | 17.0 | 6.9 | 3.2 | -5.0 | -3.4 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | | | 2008 | 2008 | | | 2009 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | លានដុល្លារ | | | | | | |
| ការនាំចេញសរុប | 1708.1 | 2108.1 | 2352.8 | 2799.9 | 705.0 | 890.8 | 793.4 | 803.1 | 539.6 | 928.7 | 728.6 | 721.4 |
| រួមមាន: សំលៀកបំពាក់ | 1628.4 | 2027 | 2253.3 | 2698.9 | 688.2 | 846.1 | 727.1 | 773.4 | 463.8 | 868.8 | 678.8 | 606.9 |
| កៅស៊ូ | 35.1 | 38.3 | 36.7 | 41.4 | 6.9 | 11.7 | 14.6 | 7.0 | 11.0 | 12.9 | 5.2 | 11.8 |
| ឈើ | 10.2 | 11.1 | 10.3 | 8.6 | 2.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.1 |
| ត្រី | 2.8 | 10.6 | 10.1 | 5.9 | 0.4 | 1.2 | 0.9 | 0.7 | 0.3 | 0.6 | 0.6 | 0.9 |
| ការនាំចូលសរុប | 1824.9 | 2149.0 | 2513.0 | 3057.0 | 911.6 | 924.5 | 982.7 | 983.8 | 1178.5 | 1027.1 | 916.3 | 987.7 |
| រួមមាន: ផលិតផលប្រេងកាត | 191.6 | 187.0 | 184.8 | 238.5 | 68.5 | 71.0 | 58.9 | 60.0 | 64.6 | 68.3 | 62.9 | 67.3 |
| សំភារៈសំណង់ | 80.8 | 95.3 | 134.7 | 154.4 | 31.6 | 34.9 | 32.5 | 39.7 | 40.7 | 35.6 | 29.9 | 41.4 |
| ផ្សេងៗ | 1601.3 | 1914.0 | 2245.0 | 2731.0 | 807.5 | 818.6 | 891.3 | 884.1 | 1073.2 | 923.2 | 823.5 | 879.0 |
| ជញ្ជីងពាណិជ្ជកម្ម | -116.8 | -40.9 | -160.1 | -257.1 | -208.1 | -30.7 | -189.3 | -180.7 | -638.9 | -98.4 | -187.7 | -157.6 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | 1.6 | 22.9 | -14.1 | 6.4 | -40.0 | 87.3 | -21.9 | -10.5 |
| ការនាំចេញសរុប | - | - | - | - | 0.4 | 26.4 | -10.9 | 1.2 | -32.8 | 72.1 | -21.5 | -0.9 |
| ការនាំចូលសរុប | - | - | - | - | 15.3 | 1.4 | 6.3 | 0.1 | 19.8 | -12.8 | -10.8 | 7.8 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | -54.1 | -64.9 | 291.4 | 19.8 | 8.8 | 8.2 | 1.6 | 14.2 | -32.6 | 2.7 | -6.6 | -21.5 |
| ការនាំចេញសរុប | 17.5 | 23.4 | 11.6 | 19.0 | 8.0 | 10.3 | 7.7 | 13.5 | -23.5 | 4.3 | -8.2 | -10.2 |
| ការនាំចូលសរុប | 6.9 | 17.8 | 16.9 | 21.6 | 17.6 | 17.9 | 21.7 | 24.4 | 29.3 | 11.1 | -6.8 | 0.4 |

*Import data include tax-exempt imports. Sources: Customs and Excise Department, cited by National Bank of Cambodia*

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០៣-០៩ (ពាន់លានរៀល)

| | 2003 | 2004 | 2005 | 2006 | 2007 | | | 2008 | | | | 2009 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ចំណូលសរុប | 1764 | 2126 | 2625 | 3259.2 | 1016.8 | 1031.4 | 1146.1 | 1194.1 | 1463.6 | 1297.0 | 1335.3 | 1101.7 |
| ចំណូលចរន្ត | 1733 | 2107 | 2474 | 2881.8 | 1012.4 | 1031.4 | 1141.6 | 1189.4 | 1447.0 | 1288.3 | 1286.0 | 1097.7 |
| ចំណូលពន្ធ | 1220 | 1577 | 1911 | 2270.9 | 887.7 | 844.6 | 965.2 | 978.0 | 1255.0 | 1071.2 | 1105.7 | 947.4 |
| ពន្ធក្នុងស្រុក | - | - | - | - | 642.1 | 584.8 | 661.8 | 719.9 | 955.5 | 776.7 | 796.3 | 712.0 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | 245.6 | 259.8 | 303.5 | 258.1 | 299.5 | 294.5 | 309.4 | 235.4 |
| ចំណូលមិនមែនពន្ធ | 513 | 530 | 563 | 610.9 | 124.7 | 186.9 | 176.4 | 211.4 | 192.1 | 217.1 | 180.2 | 150.3 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | - | - | 15.5 | 14.8 | 13.6 | 2.9 | 53.9 | 11.0 | 10.2 | 13.1 |
| លក់ទំនិញ និងសេវា | - | - | - | - | 93.0 | 100.1 | 124.3 | 118.9 | 96.3 | 99.7 | 109.8 | 93.5 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | - | - | 16.2 | 72.0 | 38.5 | 89.6 | 41.9 | 106.4 | 60.3 | 43.7 |
| ចំណូលជាមូលធន | 31 | 19 | 152 | 377.4 | 4.5 | 0.0 | 4.5 | 4.8 | 16.5 | 8.7 | 49.3 | 4.0 |
| ចំណាយសរុប | 2757 | 2932 | 3295 | 4174.7 | 1098.7 | 1126.1 | 1689.7 | 1059.1 | 1744.7 | 1662.8 | 1831.2 | 1650.6 |
| ចំណាយជាមូលធន | 1171 | 1163 | 1328 | 1638.1 | 408.1 | 355.1 | 807.4 | 411.0 | 648.2 | 641.2 | 874.0 | 693.6 |
| ចំណាយចរន្ត | 1586 | 1769 | 1967 | 2536.8 | 681.6 | 771.0 | 882.3 | 648.1 | 1096.5 | 918.0 | 1146.4 | 752.4 |
| បៀវត្សរ៍ | 615 | 640 | 711 | 822.0 | 242.7 | 253.4 | 362.6 | 250.7 | 367.0 | 363.6 | 415.7 | 327.4 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | - | - | 184.0 | 115.0 | 194.2 | 104.3 | 325.7 | 111.9 | 385.2 | 217.3 |
| ចំណាយចរន្តផ្សេងទៀត | - | - | - | - | 254.9 | 402.6 | 325.5 | 193.1 | 403.8 | 442.6 | 345.4 | 207.7 |
| សមតុល្យជាទូទៅ | -993 | -806 | -706 | -915.6 | -81.9 | -78.7 | -543.6 | 135.0 | -281.1 | -365.8 | -495.9 | -548.9 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 886 | 864 | 1127 | 1360.7 | 313.9 | 290.3 | 741.5 | 299.2 | 615.8 | 435.0 | 705.1 | 533.2 |
| ហិរញ្ញប្បទានក្នុងស្រុក | 106 | 148 | -396 | -445.1 | -213.0 | -148.0 | -185.8 | -294.1 | -236.5 | 234.7 | 168.9 | -335.3 |

*Source: MEF web site*

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០០៣-០៩

| | 2004 | 2005 | 2006 | 2007 | | | | 2008 | | | | 2009 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| (ខែតុលា-ធ្នូ ២០០០:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 3.9 | 5.8 | 4.7 | 3.0 | 4.6 | 6.0 | 9.7 | 16.5 | 24.9 | 21.7 | 15.7 | - |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 6.4 | 8.6 | 6.4 | 3.0 | 7.2 | 11.3 | 18.1 | 27.6 | 43.5 | 35.2 | 26.1 | - |
| - ដឹកជញ្ជូន | 9.7 | 11.4 | 9.1 | 5.2 | 5.0 | 3.1 | 9.9 | 18.8 | 25.3 | 25.4 | 8.0 | - |
| (ខែតុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | - | - | - | - | - | - | - | - | - | - | - | 4.3 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | - | - | - | - | - | - | - | - | - | - | - | 6.1 |
| - ដឹកជញ្ជូន | - | - | - | - | - | - | - | - | - | - | - | -13.0 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4016.3 | 4119.7 | 4119.0 | 4063.0 | 4075.4 | 4082.3 | 4030.1 | 3995.3 | 4030.2 | 4117.5 | 4089.8 | 4111.6 |
| រៀលក្នុង ១ បាតថៃ | 99.9 | 102.6 | 108.7 | 113.7 | 118.0 | 130.0 | 129.3 | 129.1 | 125.4 | 121.9 | 117.7 | 116.6 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.5 | 25.8 | 25.1 | 24.6 | 24.7 | 25.3 | 25.2 | 25.2 | 24.9 | 24.8 | 24.3 | 23.6 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 46.3 | 54.0 | 70.6 | 77.7 | 79.8 | 80.8 | 94.4 | 111.6 | 107.7 | 106.0 | 98.2 | 105.6 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 2088 | 2633 | 3140 | 3067 | 3100 | 3203 | 3679 | 3982 | 4975 | 5495 | 3768.9 | 2873.7 |
| ថ្លៃសាំង (រៀល/លីត្រ) | 2833 | 3442 | 4004 | 3750 | 3900 | 4002 | 4368 | 4580 | 5171 | 5391 | 3861.3 | 3112.6 |

*Sources: NIS, NBC & CDRI*

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៣-០៩ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | | | 2008 | | | | 2009 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 4,027 | 4,797 | 5,475 | 7,224 | 9,048 | 9,768 | 10,735 | 10,911 | 11,353 | 10,809 | 10,345 | 11,222 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -698 | -467 | -450 | -282 | -172 | 140 | 576 | 1,136 | 1,345 | 1,748 | 15,13.3 | 1,266 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -128 | -209 | -421 | -953 | -1,403 | -1,547 | -1,816 | -2,400 | -2,678 | -2,653 | -2,987 | -3,048 |
| ឥណទានដល់ផ្នែកឯកជន | 1,337 | 1,817 | 2,394 | 3,630 | 4,537 | 5,376 | 6,386 | 8,050 | 9,206 | 9,781 | 9,894 | 9,814 |
| រូបិយវត្ថុទូទៅ M2 | 3,329 | 4,330 | 5,025 | 6,942 | 8,876 | 9,908 | 11,311 | 12,047 | 12,698 | 12,557 | 11,858 | 12,488 |
| រូបិយវត្ថុ M1 | 937 | 1,153 | 1,323 | 1,658 | 1,748 | 1,750 | 2,052 | 2,389 | 2,467 | 2,335 | 2,399 | 2,545 |
| រូបិយវត្ថុផ្សេងៗ | 2,392 | 3,177 | 3,702 | 5,285 | 7,128 | 8,158 | 9,259 | 9,658 | 10,231 | 10,223 | 9,459 | 9,942 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 15.2 | 30.0 | 16.1 | 38.1 | 46.8 | 53.4 | 62.9 | 54.5 | 43.1 | 26.7 | 4.8 | 3.7 |
| រូបិយវត្ថុ M1 | 15.3 | 23.0 | 14.7 | 25.3 | 15.7 | 12.0 | 23.8 | 33.2 | 41.1 | 33.4 | 16.9 | 6.5 |
| រូបិយវត្ថុផ្សេងៗ | 15.2 | 32.8 | 16.6 | 42.8 | 57.3 | 66.5 | 75.2 | 61.0 | 43.5 | 25.3 | 2.2 | 2.9 |

*Source: National Bank of Cambodia*

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2003 | 2004 | 2005 | 2006 | 2007 | 2007 | 2008 | 2009 | | 2008 | 2009 | |
| | | | | | | វិច្ឆិកា | វិច្ឆិកា | កុម្ភៈ | ឧសភា | វិច្ឆិកា | កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 9,196 | 7,618 | 8,085 | 7,469 | 8,075 | 9,675 | 12,628 | 8,506 | 7,884 | 34.4 | -32.6 | -7.3 |
| អ្នកលីសែង | 7,096 | 6,925 | 6,734 | 6,545 | 8,588 | 9,119 | 9,005 | 10,442 | 9,144 | 1.7 | 16.0 | -12.4 |
| អ្នកលក់បន្លែតូចតាច | 6,634 | 6,953 | 7,739 | 6,390 | 8,220 | 8,552 | 9,926 | 7,589 | 8,652 | 19.5 | -23.5 | 14.0 |
| អ្នករើសអេតចាយ | 3,945 | 4,456 | 5,167 | 4,416 | 5,422 | 5,727 | 4,652 | 5,153 | 5,881 | -16.3 | 10.8 | 14.1 |
| អ្នកបំរើតុភោជនីយដ្ឋាន* | 4,343 | 4,439 | 4,344 | 4,412 | 4,482 | 4,643 | 4,327 | 4,268 | 3,851 | -4.0 | -1.4 | -9.8 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4,114 | 4,233 | 4,370 | 5,306 | 5,516 | 6,426 | 8,697 | 7,021 | 6,315 | 39.4 | -19.3 | -10.0 |
| កម្មកររោងចក្រកាត់ដេរ | 8,447 | 8,048 | 7,359 | 7,649 | 7,568 | 7,240 | 6,554 | 6,732 | 5,929 | -6.8 | 2.7 | -11.9 |
| អ្នករត់ម៉ូតូឌុប | 10,228 | 9,259 | 10,595 | 8,201 | 10,634 | 11,872 | 15,691 | 11,613 | 10,765 | 36.1 | -26.0 | -7.3 |
| កម្មករសំណង់គ្មានជំនាញ | 6,573 | 6,391 | 6,712 | 5,918 | 6,155 | 7,777 | 8,779 | 6,095 | 8,823 | 16.3 | -30.6 | 44.7 |
| កម្មករសំណង់មានជំនាញ | 13,435 | 12,691 | 12,049 | 10,316 | 11,154 | 11,286 | 12,710 | 11,732 | 12,129 | 16.0 | -7.7 | 3.4 |

* *Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

*តពីទំព័រ ២៤* **ព័ត៌មានថ្មីពី ...**

(Urban Institute) បានដាក់ស្នើ ឡើងហើយនូវឯកសារព្រាងទី៤ នៃកម្មវិធីថ្នាក់ជាតិ ។ សំណើគំរោង "ការយល់ដឹងពីការពាក់ព័ន្ធរបស់អង្គនីតិបញ្ញត្តិជាមួយសង្គមស៊ីវិលនៅកម្ពុជា" ត្រូវបានដាក់ជូនទាន់ពេលដល់វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (Overseas Development Institute) ។ ចំពោះការងារផ្ទៃក្នុងកម្មវិធីវិញ ទីប្រឹក្សាខាងស្រាវជ្រាវកំពុងជួយសម្រួល និងផ្តល់យោបល់ផ្សេងៗ ។គំរោង "បរិបទរដ្ឋកម្ពុជា: អំណោយផលដល់ការអភិវឌ្ឍ?" ទើបចាប់ផ្តើមឡើង ដោយមានការចូលរួមពីក្រុមអ្នកស្រាវជ្រាវមកពីកម្មវិធីពីរផ្សេងទៀត គឺ កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ និងកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ ។

នៅថ្ងៃទី ២៤ កក្កដា ២០០៩ នៅបណ្ណាល័យ CDRI បានដំណើរការប្រកបដោយជោគជ័យនូវពិធីផ្សព្វផ្សាយ សៀវភៅដែលមានចំណងជើងថា ក្រោយពីលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា: ការស្ថាបនានយោបាយឡើងវិញនៅក្នុងសង្គមក្រោយបញ្ចប់ជំលោះ ដោយ Joakim Ojendal និង Mona Lilja (NIAS Press, 2009) ។ សំរាប់សៀវភៅនេះ ក៏មានអ្នកស្រាវជ្រាវខ្មែរ និងបរទេសចំរុះគ្នាជាច្រើននាក់បានចូលរួមចំណែកដែរ ក្នុងនេះ អ្នកស្រាវជ្រាវម្នាក់នៅ CDRI បានចូលរួមតាក់តែងជំពូកមួយស្តីពី "វិមជ្ឈការជាយុទ្ធសាស្ត្រមួយសំរាប់ការកសាងស្ថាប័នរដ្ឋ នៅកម្ពុជា" ។ ឯកសារនេះ គឺជាការសិក្សាតាមពិសោធន៍ជាក់ស្តែងដើម្បីធ្វើការវាយតំលៃស៊ីជំរៅ និងជាប្រព័ន្ធលើការធ្វើប្រជាធិបតេយ្យភាវូបនីយកម្មក្រោយពេលបញ្ចប់ទំនាស់នៅកម្ពុជា ។ ពិធីផ្សព្វផ្សាយសៀវភៅ បានទាក់ទាញភ្ញៀវចូលរួមចំនួន ៨០នាក់ មាន ជាអាទិ អ្នកកសាងគោលនយោបាយ សង្គមស៊ីវិល អ្នកស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល (NGOs) អ្នកផ្តល់ជំនួយ និងអ្នកអនុវត្តការងារអភិវឌ្ឍន៍ ។

**កម្មវិធីអភិវឌ្ឍន៍សង្គម** (SD): ការសិក្សាជាមូលដ្ឋានពីអ្នកគ្រប់គ្រងគន្លឹះសំរាប់កម្មវិធីទ្រទ្រង់វិស័យសុខាភិបាល កំពុងដំណើរការក្រោមកិច្ចសន្យាជាមួយនាយកដ្ឋានសំរាប់ការអភិវឌ្ឍអន្តរជាតិ (DFID) ។ ដោយមានការជួយជ្រោមជ្រែងពីវិទ្យាស្ថានគោលនយោបាយអ៊ុកស្វដ (OPI) បញ្ជីសំនួរមួយត្រូវបានបង្កើតឡើង និងយកទៅប្រើប្រាស់សាកល្បងនៅតាមមន្ទីរពេទ្យ និងស្រុកប្រតិបត្តិពីរៗ ក្នុងខេត្តកណ្តាល និងក្រុងភ្នំពេញ កាលពីថ្ងៃទី ៣០ កក្កដា ២០០៩ ហើយអង្កេតដល់កន្លែង នឹងត្រូវធ្វើឡើងនៅអំឡុងខែសីហា-កញ្ញា ២០០៩ ។ ការងាររៀបចំសន្និសីទថ្នាក់តំបន់ កំពុងបន្តទៅមុខ ដោយបានប្រើបណ្តាញអ៊ីមែលដើម្បីប្រកាសអញ្ជើញជាលើកទី២ ដល់ពួកអ្នកមានចំណាប់អារម្មណ៍ ឱ្យដាក់ស្នើឡើងនូវឯកសារសំរាប់ការចូលរួមក្នុងសន្និសីទ ។ ការពិភាក្សាជាមួយ អង្គការ UN Habitat ស្តីពី "ការសិក្សាពីការិតសុវត្ថិភាពសំរាប់ជនក្រីក្រនៅក្រុងភ្នំពេញ" កំពុងដំណើរការទៅមុខ ។ ក្នុងអំឡុងពេលដដែល ក្រុមបណ្តុះបណ្តាល បានដំណើរការវគ្គបណ្តុះបណ្តាល ស្តីពី "ការកសាងសន្តិភាព" សំរាប់ពួកអ្នកបណ្តុះបណ្តាល អ្នកអនុវត្តជាក់ស្តែង និង NGOs នៅខេត្តកំពង់ស្ពឺ (ថ្ងៃទី ១៣-១៧ កក្កដា ២០០៩) និង វគ្គពិសេសមួយនៅខេត្តពោធិ៍សាត់ (ថ្ងៃទី ១៨-៣១ កក្កដា ២០០៩) ។

**កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់** (ETRC): ក្រុមអនុវត្តគម្រោង "ការសិក្សាពីឌីណាមិកនៃភាពក្រីក្រ" កំពុងធ្វើការវិភាគលើទិន្នន័យជាក្រុមស្តីពី ទិដ្ឋភាពផ្សេងៗនៃបញ្ហាភាពក្រីក្រ ដូចជា ការកំណត់ពីលក្ខណៈញឹកញាប់នៃភាពក្រីក្រ, ភាពក្រីក្រមួយរយៈ និងភាពក្រីក្រយូរអង្វែង ព្រមទាំងកត្តានានាដែលបង្កភាពក្រីក្រទាំងពីរបែប ។ គម្រោងនេះត្រូវបានពន្យារពេលប៉ុន្មានខែទៀត ដើម្បីលៃពេលធ្វើ "ការវាយតម្លៃរហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចទៅលើគ្រួសារនៅកម្ពុជា" ។ ដោយឡែកការសិក្សាពី "វិនិយោគចិននៅកម្ពុជា" បានទទួលមតិយោបល់សព្វគ្រប់ហើយពីដៃគូក្នុងការសិក្សា ហើយរបាយការណ៍កំពុងត្រូវបានកែសម្រួល ក្នុងនេះមានទាំងករណីសិក្សាទាំង ៦ ផង ។ ឯកសារព្រាងទី១ នៃរបាយការណ៍ស្តីពី "ការទាញប្រយោជន៍ឱ្យបានប្រសើរបំផុតពីវិនិយោគរបស់ចិនទៅលើធនធានធម្មជាតិនៅកម្ពុជា" បានបញ្ជូនទៅអ្នកផ្តល់ជំនួយរួចហើយ ហើយនឹងត្រូវបញ្ចប់ក្រោយពេលទទួលបានមតិយោបល់មកវិញ ។ "ការវាយតំលៃរហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចទៅលើគ្រួសារនៅកម្ពុជា" ដែលជាគំរោងស្រាវជ្រាវរួមគ្នាមួយ ជាមួយ PARD បានដាក់ជូនធនាគារពិភពលោករួចហើយ នូវរបាយការណ៍ចុងក្រោយសំរាប់សមាសភាគទី១ និង របាយការណ៍ព្រាងទី១ សំរាប់សមាសភាគទី៤ ។ សំរាប់ "ការវាយតម្លៃពីឥទ្ធិពលខាងសេដ្ឋកិច្ច-សង្គមកិច្ច នៃគម្រោងនានារបស់GMS" ដែលជាគម្រោងស្រាវជ្រាវរួមគ្នាជាមួយ PARD និង SD បានចាប់ផ្តើមពិនិត្យឡើងវិញពីវិធីសាស្ត្រស្រាវជ្រាវ និងករណីសិក្សា នៅតាមប្រទេសផ្សេងៗ ហើយបច្ចុប្បន្នបានជឿនលឿនការងារទៅមុខច្រើន ។ នៅចុងខែកក្កដា កម្មវិធីនេះ បានព្រមព្រៀងជាមួយ គណៈកម្មការសេដ្ឋកិច្ចនិងសង្គមកិច្ចនៃសហប្រជាជាតិសំរាប់អាស៊ី-ប៉ាស៊ីហ្វិក (UNESCAP) លើការបង្កើត អត្ថបទសង្ខេបគោលនយោបាយមួយស្តីពី "ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល ទៅលើកម្មករកាត់ដេរ និងប្រាក់ផ្ញើទៅផ្ទះ : ករណីនៅកម្ពុជា" ។

**កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន** (NRE) : វគ្គបណ្តុះបណ្តាលមួយ ហៅថា "ទិន្នន័យសេដ្ឋកិច្ចមាត្រសាស្ត្រ ជាក្រុម (Panel Data Econometrics)" បានធ្វើឡើងសំរាប់កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក (WRMRCDP) ។ ចំពោះគម្រោងស្តីពី "ព្រៃត្រូពិកសំរាប់កាត់បន្ថយភាពក្រីក្រ – ការវិភាគទិន្នន័យតាំងពីការិតគ្រួសារ ដល់ការិតសាកល" បច្ចុប្បន្នកំពុងបន្តការសំអាតទិន្នន័យ ដោយសហការជាមួយ មជ្ឈមណ្ឌលសំរាប់ការស្រាវជ្រាវព្រៃឈើអន្តរជាតិ (CIFOR) ។អ្នកអនុវត្តគម្រោងស្តីពី "ការកសាងសមត្ថភាពសហគមន៍សំរាប់ការផ្តួចផ្តើមគំនិតកាត់បន្ថយភាពក្រីក្រនៅអាងទន្លេសាប" បានជួបប្រជុំជាមួយ គណៈកម្មាធិការសំរាប់កសិកម្ម និងអភិវឌ្ឍន៍ជនបទ ដើម្បីពិភាក្សាពីលទ្ធផលផ្សេងៗ ក្រោយពេលធនាគារអភិវឌ្ឍន៍អាស៊ីបានពិនិត្យរួចហើយ ។ ដោយឡែក គម្រោងរយៈពេលមួយឆ្នាំ ស្តីពី "មាគ៌ាដ៏មានចីរភាពដើម្បីសំរេចបានតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍" ដែលទទួលបានមូលនិធិពីវិទ្យាស្ថាន Stockholm Environment Institute កំពុងស្ថិតក្នុងដំណាក់កាលសំអាតទិន្នន័យ ។

**កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ** (PARD)៖ គំរោងការសិក្សាពីឌីណាមិកនៃភាពក្រីក្រ (PDS) កំពុងធ្វើការវិភាគទិន្នន័យបែបបរិមាណ ។ កម្មវិធីនេះ ហើយនិង កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ កំពុងកំណត់ចេញនូវសន្ទស្សន៍ទ្រព្យធន ដោយប្រើប្រាស់អនុសាសន៍របស់បណ្ឌិត Jose Ramon G. Albert ជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៅ វិទ្យាស្ថានហ្វីលីពីនសំរាប់ការសិក្សាពីអភិវឌ្ឍន៍ (Philippines Institute for Developmwnt Studies) ។ របាយការណ៍ព្រាងចុងក្រោយនៃគម្រោងស្ដីពី ការវាយតម្លៃរហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចទៅលើគ្រួសារនៅកម្ពុជា បានចប់សព្វគ្រប់ និងបញ្ជូនទៅឱ្យ ធនាគារពិភពលោករួចរាល់ហើយ ។ អត្ថបទស្រាវជ្រាវចំនួន ២ ត្រូវបានតាក់តែងឡើងសំរាប់ចុះផ្សាយក្នុង ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា លេខ៣ ឆ្នាំ២០០៩ ។ គម្រោង "ការកសាងភាពធន់ទ្រាំនៃ សហគមន៍នេសាទនៅបឹងទន្លេសាបៈ សកម្មភាពជាសមូហភាព និងសមត្ថភាពគ្រប់គ្រងការប្រជែងគ្នាលើធនធាន" គ្រោងចាប់អនុវត្តនៅថ្ងៃទី១ កញ្ញា ២០០៩ ។ គម្រោងនេះ គឺ អង្គការ WorldFish បានចុះកិច្ចសន្យាឱ្យអនុវត្ត និងទទួលបានជំនួយពី ក្រុមពិគ្រោះពីការស្រាវជ្រាវកសិកម្មអន្តរជាតិ (CGIAR) ។ ចំពោះគំរោង "ការវាយតំលៃពីឥទ្ធិពលសេដ្ឋកិច្ច-សង្គមកិច្ចនៃគំរោង GMS " ដែលទទួលមូលនិធិពី ADB គឺ កម្មវិធី PARD ទទួលខុសត្រូវលើ "អង្កេតមូលដ្ឋានពីការដឹកជញ្ជូន" ហើយសូចនាករផ្សេងៗនៃការវាយតម្លៃមូលដ្ឋាន ក៏បានកំណត់ឡើងក្នុងពេលធ្វើទស្សនកិច្ចលើកដំបូង ទៅតំបន់អនុវត្តគម្រោង (ខេត្តកំពត) នៅចុងខែសីហា ២០០៩ ។ សំរាប់គំរោងជាសក្ដានុពលមួយទៀត ស្ដីពី "ការស្វែងយល់ពីអន្តរកាលកសិកម្មនាពេលខាងមុខនៅអាស៊ី" PARD បានកសាងរួចហើយនូវឯកសារគោលគំនិត សំរាប់ដាក់ជូន អ្នកផ្ដល់មូលនិធិ ។

តាំងពីឆ្នាំ២០០៧ មក CDRI បានរៀបចំយ៉ាងទៀងទាត់ក្នុងពីរខែម្ដងនូវសិក្ខាសាលាស្រាវជ្រាវមួយខ្សែ ស្ដីពីបញ្ហាផ្សេងៗខាងអភិវឌ្ឍន៍ ក្នុងគោលដៅចែករំលែកលទ្ធផលស្រាវជ្រាវ ពង្រឹងគុណភាពស្រាវជ្រាវ កែលំអវិធីសាស្ត្រស្រាវជ្រាវ កសាងនូវគោលគំនិត និងធ្វើវិភាគលើប្រធានបទនៃការស្រាវជ្រាវ ។ អ្នកធ្វើបទបង្ហាញក្នុងសិក្សាសាលានេះ មានមកពី CDRI ព្រមទាំងស្ថាប័ន និង NGOs នានានៅក្រុងភ្នំពេញ ។ សំរាប់សិក្ខាសាលានៅខែកក្កដា ២០០៩ នេះ អ្នកធ្វើបទបង្ហាញរបស់ CDRI មានរួមបញ្ចូលទាំងបណ្ឌិត អ៊ុន ឃៀង ជាជំនួយការសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ Northern Illinois University និងជាទីប្រឹក្សាស្រាវជ្រាវនៃកម្មវិធីអភិបាលកិច្ច ។ ប្រធានបទនៃបទបង្ហាញ គឺ "ការស្វែងយល់ពីរដ្ឋកម្ពុជា ក្នុងលក្ខណៈជារដ្ឋធ្វើអភិវឌ្ឍន៍ៈ ការស្វែងរកកម្មវិធីស្រាវជ្រាវ" ៕


## Cambodia Development Review—2009 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to:
Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❒Mr ❒Ms ❒Dr ❒ Other ..........

First name: .......... Last name: .......... Position: ..........

Organisation / Company: ..........

Address (CCC Box if applicable): ..........

City / Province: .......... Country: ..........

Telephone: .......... Fax: ..........

e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Do not send cash through the post.
Please inform the Publishing Department at CDRI if your contact details change.

# ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

ក្នុងការប្រជុំពាក់កណ្ដាលឆ្នាំ នៅខែសីហា ២០០៩ ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានស្វាគមន៍សមាជិកថ្មីចំនួន ៣នាក់ គឺ លោកជំទាវ នាវ ច័ន្ទថាណា អនុប្រធានធនាគារជាតិនៃកម្ពុជា, ឯ.ឧ. បណ្ឌិត ទា ផលា អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង បណ្ឌិត ហួត ពុំ សេដ្ឋវិទូ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងអគ្គនាយករងនៃគណៈកម្មការមូលប័ត្រកម្ពុជា ។ ក្រុមប្រឹក្សាភិបាលក៏បានអនុម័តគំរោងរៀបចំព្រឹត្តិការណ៍មួយចំនួននៅឆ្នាំ២០១០ ដើម្បីអបអរសាទរខួបឆ្នាំទី២០ នៃការបង្កើតវិទ្យាស្ថាន CDRI ព្រមទាំងការចូលរួមចំណែកក្នុងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ និងធនធានមនុស្សនៅកម្ពុជា ។

តំណាង CDRI និងវិទ្យាស្ថានដៃគូនានា ក្នុងបណ្ដាញវិភាគអភិវឌ្ឍន៍ (DAN) ដែលមកពីប្រទេសឡាវ ថៃ វៀតណាម និងខេត្តយុនណាន់ ប្រទេសចិន បានថយទៅសំរាកពិចារណានៅថ្ងៃទី៤ សីហា ២០០៩ ចំនួន ១ថ្ងៃ នៅឯទីក្រុងលួងប្រាបាង ក្នុងក្របខ័ណ្ឌនៃគំរោងស្រាវជ្រាវ DAN8 ដែលជាគំរោងចុងក្រោយទទួលថវិកាពីមូលនិធិ Rockefeller និងដែលត្រូវបញ្ចប់នៅខែមិថុនា ២០១០ ។ ការថយទៅសំរាកពិចារណានេះ មានគោលដៅធ្វើការពិនិត្យឡើងវិញពី តួនាទី តំលៃ លទ្ធផល ចំណុចខ្លាំង និងចំណុចខ្សោយនៃ DAN ព្រមទាំងពិភាក្សាពីវិធីរក្សា និងពង្រឹង DAN ក្នុងលក្ខណៈជាបណ្ដាញសហការស្រាវជ្រាវខាងគោលនយោបាយដ៏មានប្រសិទ្ធភាពនៅ មហាអនុតំបន់មេគង្គ (GMS) ។ សំណើមួយស្ដីពីការងារ DAN និងពួកដៃគូផ្ដល់ជំនួយហិរញ្ញវត្ថុទៅអនាគត ត្រូវបានរៀបចំឡើងសំរាប់ដាក់ជូនបណ្ដាញ DAN អនុម័តនៅពេលប្រជុំលើកក្រោយ នៅខែមករា ២០១០ ។

របាយការណ៍ប្រចាំឆ្នាំ២០០៨-០៩ របស់ CDRI បានបោះពុម្ពផ្សាយ និងដាក់ក្នុងវេបសាយរបស់ CDRI រួចហើយ ក៏ដូចជាឯកសារសង្ខេបចក្ខុវិស័យប្រទេសកម្ពុជា ចំនួន ៦លេខ ជាភាសាខ្មែរ និងអង់គ្លេស ដែលផ្អែកលើលទ្ធផលនៃសន្និសីទចក្ខុវិស័យស្ដីពីប្រទេសកម្ពុជាឆ្នាំ២០០៩ក្រោមប្រធានបទផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាកល ទៅលើប្រទេសកម្ពុជា ។

## ផ្នែកស្រាវជ្រាវ

ពីខែកក្កដា ដល់ កញ្ញា ២០០៩ នៅតាមកម្មវិធីនានា នៃ CDRI បានអនុវត្តសកម្មភាពស្រាវជ្រាវមួយចំនួន ដែលមានជាសង្ខេបដូចតទៅ:

**កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទំរង់វិស័យសាធារណៈ** (DGPSR): ឯកសារព្រាងទី២ នៃរបាយការណ៍ស្ដីពីការដឹកនាំនៅថ្នាក់ភូមិ/ឃុំ កំពុងរង់ចាំការជួយមតិយោបល់ផ្សេងៗ រីឯ ឯកសារព្រាងទី១ បានបញ្ចប់រួចរាល់ និងកំពុងរង់ចាំយោបល់ខ្លះៗពីទីប្រឹក្សាខាងស្រាវជ្រាវ ។ គំរោងមួយទៀត គឺ សមត្ថភាពស្រាវជ្រាវនៃសាកលវិទ្យាល័យនៅកម្ពុជា បានបញ្ចប់ដំណាក់កាលទី១ នៃការចុះធ្វើសម្ភាសន៍ជាមួយ ពួកអ្នកផ្ដល់ព័ត៌មានគន្លឹះ ហើយរបាយការណ៍សំរេចនឹងត្រូវធ្វើឡើងនៅខែសីហា ។ ចំពោះគំរោង "អភិបាលកិច្ចថ្នាក់មូលដ្ឋានលើធនធានរួមៈ ករណីធារាសាស្ត្រនៅកម្ពុជា" អ្នកស្រី ជា ជូ បានជួបជាមួយ សាស្ត្រាចារ្យ Joakim Ojendal ដើម្បីសុំយោបល់ខ្លះៗ ទាក់ទងនឹង ជំពូកចំនួន ៤ ដែលបានសរសេរចប់សព្វគ្រប់ រីឯ ជំពូកទី៤ នៃរបាយការណ៍នេះ កំពុងកែសម្រួលជាចុងក្រោយ ហើយគ្រោងបញ្ចប់នៅពាក់កណ្ដាលខែសីហា ។ គំរោងផ្ដល់យោបល់ពិគ្រោះ ដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៃក្រសួងមហាផ្ទៃ ដែលទទួលមូលនិធិពីវិទ្យាស្ថានសិក្សាពីទីក្រុង

(តទៅទំព័រ ២២)

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៣ លេខ៣ ខែកក្កដា-កញ្ញា ឆ្នាំ២០០៩

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdrimail@online.com.kh

website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ

គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ

កែសំរួលផលិតកម្ម: គឹម ចិត្រ្តា និង អ៊ុំ ចាន់ថា

ជំនួយការកែសំរួល: ខេង សេង

រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០០៨ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ឱ្យដោយឥតគិតថ្លៃតាមរយៈវេបសាយ: http://www.cdri.org.kh